ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

**កំណត់ហេតុជាលាយលក្ខណ៍អក្សរ**

**នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"**

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩**

**សវនាការលើអង្គសេចក្តី (លើកទី៨)**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា (បម្រុង)

លោកស្រី ក្លូឌា ហ្វេនស៍ (បម្រុង)

*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម សួយហុង

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា ណាថាក់ វិចស៊ែល

*(Ms. Natacha Wexels-Riser)*

លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក តាន់ សេណារ៉ុង

លោក អាឡិចសាន់ឌឺ ប៊េត

*(Mr. Alexander Bates)*

លោក ពេជ្រ សម្បត្តិ

លោក ស្ទួអាត ហ្វដ *(Mr.stuart FORD)*

លោក ប៉ាក ចាន់លីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms.Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គឹមសួន

លោក គង់ ពិសី

លោក យុង ផានិត

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោក ហ្វីលីព កាណុន

*(Mr. Philippe Cannone)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖ KW-៣១ : លោក ចាន់ វឿន**

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ....................................ទំព័រ ១
សួរដោយ ចៅក្រម **ហ្សង់ម៉ាក ឡាវ៉ែន៍** ផ្តើមពី....................................ទំព័រ ៦
សួរដោយ ចៅក្រម **ស៊ីលយ៉ា ខាតរ៉ាយថ៍** ផ្តើមពី ....................................ទំព័រ ២២
សួរដោយ ចៅក្រម **យ៉េច ចរិយា** ផ្តើមពី....................................ទំព័រ ៣៦
សួរដោយ ចៅក្រម **អាឡិចសាន់ឌឺ ប៊ែត** ផ្តើមពី ....................................ទំព័រ ៣៨
សួរដោយ លោក **អាឡាំង វ៉ែនណឺ** ផ្តើមពី ....................................ទំព័រ ៤៥
សួរដោយ លោក **គីម ម៉េងឃី** ផ្តើមពី....................................ទំព័រ ៤៧
សួរដោយ លោក **ហ្វីលីព កាណុន** ផ្តើមពី....................................ទំព័រ ៤៧
សួរដោយ លោក **ហុង គីមសួន** ផ្តើមពី ....................................ទំព័រ ៤៩
សួរដោយ លោក **ហ្វ្រង់ស្វ័រ រូ** ផ្តើមពី....................................ទំព័រ ៥១

**សាក្សី ៖ KW-៣២ : លោក ចាន់ ខន**

សួរដោយ ប្រធាបអង្គជំនុំ ផ្តើមពី....................................ទំព័រ ៦៣
សួរដោយ ចៅក្រម **ហ្សង់ម៉ាក ឡាវ៉ែន៍** ផ្តើមពី....................................ទំព័រ ៦៥

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក ចាន់ ខន (សាក្សី) | ខ្មែរ |
| លោក ចាន់ វឿន (សាក្សី) | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក អាឡិចសាន់ឌឺ ប៊េត | អង់គ្លេស |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធាអង្គជំនុំជម្រះ) | ខ្មែរ |
| លោក ហ្វីលីព កាណុន | បារាំង |
| លោក អាឡាំង វ៉ែនណឺ | បារាំង |
| លោក យ៉េត ចរិយា | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:១០:០៥]

**ប្រធានអង្គជំនុំ៖**

នៅព្រឹកនេះ អង្គជំនុំជម្រះសាលាដំបូងប្រកាសបន្តដំណើរការសវនាការ រឿងក្តីលេខ០០១ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ ជាបន្តទៅទៀត ។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី ព្រមទាំងសាក្សីដែលត្រូវបានកោះហៅឲ្យចូលមកផ្តល់ចម្លើយនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន! ភាគីដែលចូលរួមក្នុងដំណើរការនីតិវិធីថ្ងៃនេះមានវត្តមានគ្រប់ចំនួនអស់ហើយ ចំណែកឯសាក្សីក៏មានវត្តមានគ្រប់ចំនួនដែរ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីរៀបចំចាត់បញ្ចូលស្ថានភាពវត្តមាន អវត្តមានភាគីនិងសាក្សីថ្ងៃនេះទៅក្នុងប្រតិចារឹក។

ជាកិច្ចបន្តសូម-- បង្គាប់ឲ្យមន្ត្រីតុលាការនាំសាក្សី KW៣១ ចូលមកកាន់បន្ទប់សវនាការ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បងឈ្មោះ ចាន់ វឿន អ៊ីចឹងមែនទេ?

**សាក្សី KW-31៖**

**ឆ៖** បាទ, ឈ្មោះ ចាន់ វឿន ។

**ស៖** ឆ្នាំនេះបងអាយុប៉ុន្មានហើយ?

**ឆ៖** អាយុ ៥៦ ។

**ស៖** សព្វថ្ងៃនេះបងមានទីលំនៅ នៅកន្លែងណាដែរ?

**ឆ៖** នៅឃុំអមលាំង ។

**ស៖** បងមានមុខរបរអ្វីដែរសព្វថ្ងៃ?

**ឆ៖** មុខរបរធ្វើស្រែចម្ការ ។

**ស៖** យោងតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថា លោកមិនមានជាប់ចំណងញាតិលោហិត ញាតិពន្ធ ឬក៏សហព័ទ្ធ និងភាគីក្នុងរឿងក្តីនេះទេ មែនទេ?

**ឆ៖** មានមែន ។

**ស៖** បងមានជាប់បងប្អូនជាមួយតា ឌុច ជាមួយនឹងភាគីផ្សេងៗនៅក្នុងរឿងក្តីហ្នឹងទេ?

**ឆ៖** មានបាទ ។

**ស៖** បងប្អូនអ្នកណាគេ?

**ឆ៖** ស្តាប់អត់ច្បាស់ទេ ។

**ស៖** បងមានៗជាប់បងប្អូនជាមួយនឹងភាគីផ្សេងៗនៅក្នុងរឿងក្តីនេះទេ?

**ឆ៖** មានបងមាន ។

**ស៖** បងប្អូនឯណាគេ?

**ឆ៖** ពូខ្ញុំបង្កើត ។

**ស៖** ឈ្មោះអី?

**ឆ៖** សយ ។

**ស៖** គាត់នៅឯណា គាត់ហ្នឹង?

[០៩:១៥:០០]

**ឆ៖** នៅភូមិពាម ។

**ស៖** ហើយគាត់ធ្វើសព្វថ្ងៃ?

**ឆ៖** បាទ?

**ស៖** គាត់ធ្វើអី?

**ឆ៖** គាត់អត់មានធ្វើអីទេ នៅឯចម្ការហ្នឹង ។

**ស៖** គាត់មានធ្លាប់ចូលរួមនៅក្នុងសវនាការនេះទេ?

**ឆ៖** អត់ អត់ទេ បង ។

**ស៖** អ៊ីចឹងគឺដូចរបាយការណ៍របស់ក្រឡាបញ្ជី បានបញ្ជាក់ថា បងមិនមានជាប់ចំណងលោហិតញាតិពន្ធ ឬក៏សហព័ទ្ធ ជាមួយនឹងភាគីក្នុងរឿងក្តីនេះទេ ។

នៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះបានអញ្ជើញបងមកធ្វើជាសាក្សីនៅក្នុងរឿងក្ដី ហើយក្នុងនាមជាសាក្សី អង្គជំនុំជម្រះតម្រូវឲ្យបងស្បថជាមុន មុននឹងផ្ដល់សក្ខីកម្ម ។ តើបងបានស្បថរួចហើយឬនៅ?

**ឆ៖** បានស្បថរួចហើយ ។

**ស៖** នៅក្នុងរឿងក្ដីនេះ អង្គជំនុំជម្រះអញ្ជើញបងមកផ្ដល់សក្ខីកម្មនូវអ្វីដែលបងបានដឹង បានឮ បានឃើញ ពាក់ព័ន្ធទៅនឹងអង្គហេតុមន្ទីរសន្តិសុខម-១៣ ដែលមានទីតាំងឋិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ក្នុងអំឡុងពេលទសវត្សរ៍ឆ្នាំចិតសិប១ គឺពីឆ្នាំ១៩៧១ ដល់ខែមេសា ឆ្នាំ១៩៧៥ នេះគ្រាន់តែជម្រាបឲ្យបងបានដឹងអំពីគោលបំណងនៃការកោះហៅបងមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការនាពេលនេះ បងយល់ទេ?

**ឆ៖** យល់ ។

**ស៖** ជាបន្តនេះ គឺអង្គជំនុំជម្រះសូមប្រាប់អំពីសិទ្ធិក្នុងនាមជាសាក្សី ។ សាក្សីអាចបដិសេធក្នុងការឆ្លើយទៅនឹងសំណួរ ដែលបានសួរ ឬក៏ធ្វើសេចក្ដីថ្លែងការណ៍ណាមួយដែលនាំឲ្យមានពិរុទ្ធភាពលើខ្លួនឯង ។ បងយល់ទេនូវសិទ្ធិនេះ?

[០៩:១៧:៣៧]

**ឆ៖** អត់សូវយល់ដែរបង ។

**ស៖** បានសេចក្ដីថា ប្រសិនបើនៅក្នុងចម្លើយរបស់បងមានការពាក់ព័ន្ធទៅនឹងអំពើផ្សេងៗដែលកើតមានឡើង ប្រព្រឹត្តដោយខ្លួនឯង បងអាចមិនឆ្លើយនឹងសំណួរ ឬក៏ធ្វើសេចក្ដីថ្លែងការណ៍អំពីបញ្ហានេះទេ ។ ប៉ុន្តែ បងអាចលើកអំពីហេតុផលផ្សេងៗទៀត ទិដ្ឋភាពផ្សេងទៀត ដែលបងបានឃើញបានដឹង បានឮ ក្រៅពីអំពើរបស់ខ្លួនឯង នេះជាសិទ្ធិដែលមិនធ្វើសក្ខីកម្មដាក់ពិរុទ្ធភាពលើខ្លួនឯង ។ បងយល់ឬនៅ?

**ឆ៖** យល់ហើយបង ។

**ស៖** បងអាចប្រាប់ដល់អង្គសវនាការបានទេ ថាបងបានស្គាល់មន្ទីរសន្តិសុខម-១៣ ដែលមានទីតាំងឋិតនៅអមលាំង ក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលមានអត្ថិភាពនៅក្នុងអំឡុងឆ្នាំ១៩៧១ ដល់ឆ្នាំ១៩៧៥ ។ បងពិតជាស្គាល់ទេ ឬក៏មិនស្គាល់ទេ?

**ឆ៖** ពិតជាស្គាល់ ។

**សះ** ហើយមូលហេតុអីទៅ ដែលនាំឲ្យបងបានទៅស្គាល់នៅកន្លែងនោះ?

**ឆះ** មូលហេតុ ខ្ញុំធ្លាប់នៅជាមួយគាត់ដែរ ។

**សះ** អ៊ីចឹងកាលណោះ បងក៏ជាបុគ្គលិកនៃមន្ទីរសន្តិសុខនៅទីនោះដែរមែនទេ?

**ឆះ** បាទ ។

**សះ** បងនៅក្នុង-- រស់នៅក្នុងមន្ទីរសន្តិសុខម-១៣ ដែលមានទីតាំងស្ថិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ នោះក្នុងរយៈពេលប៉ុន្មាន? ប្រហែលជាពីថ្ងៃខែឆ្នាំណា រហូតដល់ថ្ងៃខែឆ្នាំណាដែរ?

**ឆះ** ខ្ញុំអត់សូវបានចាំ តែនៅបានមួយឆ្នាំជាមួយគាត់ ។

**សះ** នៅមួយឆ្នាំប្រហែលជា? បងគិតមើលប្រហែលជាចន្លោះពីឆ្នាំណា? ឧបមាថា១៩៧១ ចូល ១៩៧២ ឬ ១៩៧២ ទៅ ១៩៧៣ ឬក៏ក្នុងឆ្នាំ១៩៧៣ ឬ១៩៧៤?

**ឆះ** ប្រហែល១៩៧៤ ណាបង ។ ១៩៧៥ ខ្ញុំចេញ ។

**សះ** ឥឡូវនេះបងអាចនិទាន រៀបរាប់ឡើងវិញអំពីទិដ្ឋភាពទាំងឡាយអំឡុងពេលដែលបងទៅរស់នៅក្នុងម-១៣ ក្នុងអំឡុងពេលរយៈពេល១ឆ្នាំនោះ តើបងបានឃើញ បានជួបប្រទះ បានដឹង បានឮនូវបញ្ហាអ្វីខ្លះនៅទីនោះ? សូមបងអាចរៀបរាប់ប្រាប់ និយាយប្រាប់បញ្ហានេះដល់អង្គជំនុំជម្រះបានដែរឬទេ?

[០៩:២០:៣៩]

**ឆះ** បានបងបាន ។ ខ្ញុំចូលមកនៅជាមួយគាត់ហ្នឹង ក៏ឃើញគាត់ធ្វើសកម្មភាពផ្ទាល់ភ្នែកតែម្តងបង ។ ខ្ញុំចូលមកដល់លើកទី១ ខ្ញុំមុនដំបូង ខ្ញុំនៅអង្គភាពទ័ពទេ ដល់ខ្ញុំរ៉ៃបាក់ទ័ពនឹងគេមក ខ្ញុំបាក់ស្បាតរត់មក គេបញ្ជូនមកអង្គភាពតា ឌុច ហ្នឹង ។ ដល់ៗខ្ញុំចូលមកដល់ ខ្ញុំអត់ដែលឃើញអ៊ីចឹងសោះ ឃើញគាត់ចងអ្នកទោសហ្នឹងព្យួរ សាបអីហ្នឹង គឺឃើញពិតអ៊ីចឹង។ ធ្វើបាបអ្នកទោសហ្នឹង គាត់ចងព្យួរអ៊ីចឹងទៅ គាត់វ៉ៃសួរចម្លើយ សួរអីហ្នឹង ខ្ញុំឃើញទាំងអស់ ហ្នឹងចំពោះមន្ទីរតា ឌុច ហ្នឹង ។

រួចខ្ញុំនេះ ក៏អត់សូវបាននៅកន្លែងដែរ គាត់ចាត់តាំងខ្ញុំឲ្យនៅខាងសេដ្ឋកិច្ចឯណោះ ដើររកស្រូវអង្ករឲ្យអ្នកទោសហ្នឹងហូប ។ យូរៗមួយខែ ឬកន្លះខែ ខ្ញុំមកចូលមន្ទីរហ្នឹងម្តង ។ ម្លោះហើយខ្ញុំអត់បានដឹង គេសង្កេតគាត់ម៉េចទេ ។ ថ្ងៃណាដែលខ្ញុំមកដល់កន្លែងមន្ទីរហ្នឹង ឃើញតែគាត់ធ្វើបាប អ្នកទោស ទារុណកម្ម ហ្នឹងហ្នង ខ្ញុំអត់ដែលបាននៅជាប់ទេ ដូចដើរមួយខែ ឬមួយអាទិត្យហ្នឹង អ៊ីចឹងចូលម្តងមក ។ ចូលថ្ងៃណាក៏គាត់ធ្វើអ៊ីចឹង ហើយខ្លួន ខ្ញុំបាទនេះនៅជាមួយគាត់ហ្នឹង ក៏មានរឿងមួយគាត់

ហ្នឹងទៀត ធ្វើបាបដល់រូបខ្ញុំហ្នឹងទៀត ។ ខ្ញុំសូមអស់យោបល់ប៉ុណ្ណឹង ។

**ស៖** បកាលនោះបងអាយុប៉ុន្មាន?

**ឆ៖** កាលនោះ ខ្ញុំអាយុប្រហែលជាម្ភៃជាងទេ ។

**ស៖** ហើយនៅទីនោះសរុបទាំងអស់ ទាំងឈ្មោះ ឌុច ហើយនិងអ្នកក្រោមបង្គាប់របស់គាត់ រហូតដល់កងការពារ និយាយពីរឿងបុគ្គលិកសម្រាប់មន្ទីរហ្នឹង មានចំនួនប្រហែលប៉ុន្មាននាក់ទៅតាមបងដឹង?

**ឆ៖** វានេះច្រើនដែរ ប៉ុន្តែខ្ញុំភ្លេចឈ្មោះខ្លះ ចាំខ្លះ ។ វាច្រើនដែរ ប្រហែល១០នាក់ជាងឯណោះបង ។

**ស៖** អ៊ីចឹង បងទទួលបន្ទុកផ្នែកខាងរកស្បៀង ខាងសេដ្ឋកិច្ច យើងហៅសេដ្ឋកិច្ចជំនាន់ហ្នឹងនែ៎ ហើយទទួលបន្ទុករក ដើររកស្បៀង រកស្រូវអង្ករផ្សេងៗមកផ្គត់ផ្គង់នៃមន្ទីរ ។ អ៊ីចឹង បងមានដែលបានធ្វើជាកងការពារ ឬក៏ជាអ្នកសួរចម្លើយអីផ្សេងៗទេ?

**ឆ៖** ខ្ញុំអត់បានសួរចម្លើយអ្នកទោសទេ ព្រោះខ្ញុំនៅខាងសេដ្ឋកិច្ចហ្នឹង ។ បើកងការពារ កាលណាខ្ញុំមកពីរកស្រូវអង្ករអ៊ីចឹងទៅ ពេលណាអត់មានកម្លាំង គាត់ប្រើខ្ញុំម្តងៗដែរ ។ ឲ្យជួយការពារហ្នឹងបានមួយថ្ងៃពីរថ្ងៃអ៊ីចឹងទៅ ខ្ញុំចេញទៅបាត់ទៀត ទៅរកស្រូវ រកអង្ករហ្នឹង ។

[០៩:២៣:៥៨]

**ស៖** ក្នុងកាលៈទេសៈ ដែលបងបានឃើញនៅក្នុងអំឡុងពេលហ្នឹង ជាមួយថ្ងៃ ជាមធ្យមមានមនុស្ស ដែលត្រូវជាប់ឃុំឃាំងហ្នឹងប៉ុន្មាននាក់ទៅ ប្រហែលជាប៉ុន្មាននាក់ទៅ?

**ឆ៖** ខ្ញុំបានឃើញ ជួនកាល១០នាក់អ៊ីចឹង ដល់ខ្ញុំចេញទៅក្រៅយូរៗ មកទៅឃើញអត់ដល់ ១០នាក់ផង ។ មិនដឹងជាមនុស្សហ្នឹងទៅខាងណាខ្លះ ខ្ញុំអត់បានដឹងនៅកន្លែងហ្នឹង ។ បើខ្ញុំនៅជាប់អ៊ីចឹង ទៅអត់អីទេ បើខ្ញុំចេញទៅក្រៅបាត់កន្លះខែ ឬមួយអាទិត្យមក ១០នាក់ហ្នឹងនៅសល់ប្រហែលជា៥នាក់ ៦នាក់ទេ មិនដឹងទៅខាងណា ខាងណី មិនដឹងគាត់បញ្ជូនទៅខាងណា ខ្ញុំអត់បានដឹងដែរ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ បើមានសូមអញ្ជើញ ។ សូមអញ្ជើញចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** តើយើងអាចសុំឱ្យជនជាប់ចោទក្រោកឈរ ។ តើសាក្សីអាចមើលជនជាប់ចោទ ថាតើលោកអាចស្គាល់ជនជាប់ចោទទេ?

**សាក្សី KW-31៖**

**ឆ៖** បាទ, ស្គាល់ ។

**ស៖** លោកបានបញ្ជាក់ថាលោកបាននៅទីនោះ នៅម-១៣ នៅប្រហែលជាមួយឆ្នាំ ។ តើលោកអាចប្រាប់យើងបានទេ ថាអ្នកណាជាអ្នកដែលត្រូវជាប់ឃុំនៅកន្លែងនោះ មានបុរសស្ត្រី មានកុមារ? តើលោកអាចប្រាប់បន្ថែមទៀតបានទេ ពីរឿងហ្នឹង?

**ឆ៖** បាទ, បាន ។ រឿងជាប់ហ្នឹង វាមានទាំងពីកូនក្មេងឡើងទៅ មកទាំងប្តី ទាំងប្រពន្ធអីចឹងនៅក្នុងមន្ទីរហ្នឹង ។ និយាយមែនទែន ឃុំអមលាំងខ្ញុំហ្នឹង ចាប់ស្មើរទាំងអស់ភូមិពាមហ្នឹង ។ មកដាក់មន្ទីរគាត់ហ្នឹង ចាប់ទាំងបងប្អូនខ្ញុំមកពីរនាក់ទៀត មានទាំងក្មេងតូច ទាំងមនុស្សចាស់ ទាំងមនុស្សប្រុស ទាំងមនុស្សស្រី ។

**ស៖** តើកុមារទាំងអស់នោះច្រើនមានអាយុប៉ុនណាដែរ?

**ឆ៖** កុមារហ្នឹងប្រហែលអាយុ៤ឆ្នាំអីហ្នឹង ៣ឆ្នាំប៉ុណ្ណឹង តូចៗដែរទេ ។

**ស៖** ថាតើមានអ្នកល្មើយសឹកដែរទេ ឬក៏ជាអ្នកដែលគេបញ្ជូនចេញមកពីសម័យសាធារណរដ្ឋនោះ ជាទ័ពរបស់សម័យសាធារណរដ្ឋមានទេ?

**ឆ៖** ខ្ញុំដឹងតែបញ្ជូនទៅឃុំអមលាំង ឃុំខ្ញុំហ្នឹងអ្នកទោស ក្រៅពីហ្នឹងខ្ញុំអត់បានដឹងផង។ ឃើញអ្នកទោសអមលាំង បានខ្ញុំដឹង ។

[០៩:២៨:២៧]

**ស៖** តើមានអ្នកទោស ដែលមិន-- អ្នកដែលមកពីអមលាំងហ្នឹង លោកមិនបានឃើញអ្នកណាផ្សេង ក្រៅពីអ្នកដែលគេបញ្ជូនមកពីអមលាំងហ្នឹង អីចឹងមែនឬទេ?

**ឆ៖** បាទពិត អត់បានឃើញមែន ។ ខ្ញុំស្គាល់សុទ្ធតែអ្នកអមលាំងហ្នឹងហ្មង ។

**ស៖** ថាតើលោកដឹងទេ ថាហេតុអីបានជាគេយកអ្នកទាំងអស់នោះមកឃុំនៅ ម-១៣ នោះ?

**ឆ៖** យកមក ខ្ញុំអត់សូវបានដឹងទេ ប៉ុន្តែយកមកសុទ្ធតែអ្នកទោស អ្នកគិញហ្នឹង បានចាប់មកមន្ទីរម-១៣ ហ្នឹង ។

**ស៖** ថាតើអ្នកជាប់ឃុំទាំងអស់នោះ ត្រូវទទួលរងការប្រព្រឹត្តលើដូចគ្នា ឬក៏គេបែងចែកខុសៗគ្នា ទៅតាមប្រភេទរបស់គេ?

**ឆ៖** អត់សូវស្តាប់បានទេបង មិញ ។

[០៩:៣០:០៧]

ស៖ តើអ្នកជាប់ អ្នកទោសទាំងអស់ត្រូវទទួលរងការរៀបចំដូចគ្នា ឬក៏ទទួលរងអំពើដូចគ្នា? ថាតើអ្នកទោសណាត្រូវបានគេអនុញ្ញាតឲ្យចេញទៅក្រៅធ្វើការទេ ឬក៏អ្នកខ្លះមិនត្រូវបានគេអនុញ្ញាតឲ្យចេញទៅធ្វើការទេ?

**សាក្សី KW-31៖**

**ឆ៖** បាទ,មាន ។ អ្នកទោសខ្លះក៏បានចេញទៅក្រៅ អ្នកទោសខ្លះក៏អត់បានចេញទៅទេបងបានទៅតិចណាស់ ។ ខ្ញុំថាបានតិច ព្រោះឃើញដូចឃុំអមលាំងខ្ញុំអ៊ីចឹង ឃើញច្រើនណាស់ ហេតុអីបានបាត់អស់ មិនដឹងចេញទៅណា? ។ រាល់ថ្ងៃនេះនៅរស់តែ៣នាក់ទេ ។ ឃើញជាក់ស្តែងរាល់ថ្ងៃនេះនៅក្នុងមន្ទីរ១៣ នេះ ខ្ញុំឃើញរស់តែអាអូន អាបង ហើយនឹងតាស៊ន បីនាក់ហ្នឹងទេ ហើយនិងមួយឃុំអមលាំងចិតសិបនាក់ជាង បាត់អស់ មិនដឹងជាបាត់ទៅណា ។ ខ្ញុំបានអត់បានដឹងដែរទេ ប៉ុន្តែអត់ដឹងគាត់យកទៅកន្លែងណាអីកន្លែងណា ។ ប៉ុន្តែ ចិតសិបនាក់ជាង នៅឃើញរស់តែបីនាក់គត់ នៅឃុំអមលាំងខ្ញុំហ្នឹង ។

[០៩:៣១:៤១]

**ស៖** អ្វីដែលលោកបានប្រាប់យើងនោះ គឺក្នុងឆ្នាំដែលលោកធ្វើការនៅម-១៣ នោះ ខ្លួនលោកផ្ទាល់បានសង្កេតឃើញប្រហែលជាមានអ្នកទោស៧០នាក់ ត្រូវបានបាត់ខ្លួនចេញពីហ្នឹង តើអ៊ីចឹងមែនឬទេ?

**ឆ៖** ពិតអ៊ីចឹងមែនណាបង អត់បានឃើញ ។ ដាច់បាត់អស់រលីង ឃើញតែបីនាក់នៅរស់សព្វថ្ងៃនេះ បានគាត់ដោះលែង ហើយអត់ដោះលែងហ្នឹងមិនដឹងទៅខាងណាអស់ ។

**ស៖** តើលោកអាចប្រាប់យើងបានទេ ថាអ្វីលក្ខខណ្ឌនៃការឃុំខ្លួននៅទីនោះដូចម្តេចដែរ? ថាតើអ្នកឃុំខ្លួនគេដាក់កន្លែងណាខ្លះ? គេដាក់ច្រវាក់ តើគេស្លៀកពាក់អ្វីនៅកន្លែងឃុំខ្លួននោះ?

**ឆ៖** ខ្ញុំនិយាយការពិតរឿងកន្លែងឃុំខ្លួន គឺមានរណ្តៅគុកជីកក្នុងដី ។ មានគុកនោះ បីកន្លែងជាប់ៗគ្នា អ៊ីចឹង ។ ពេលដាក់អ្នកទោសអ៊ីចឹង ដាក់ជើង ដាក់ដៃ ដាក់កងច្រវាក់អ៊ីចឹងនៅក្នុងដី ។ ពេល

បញ្ចេញអ៊ីចឹងមកដាក់ច្រវាក់ ចាក់ច្រវាក់អ៊ីចឹងចេញមកក្រៅ ហ្នឹងខ្ញុំដឹងពិត ឃើញពិត ។ ខ្ញុំមកដូចខាងសេដ្ឋកិច្ចម្តងៗអ៊ីចឹង ខ្ញុំមកក្នុងមន្ទីរហ្នឹងឃើញដាក់ច្រវាក់ពិតតែហ្មង ដាក់អ្នកទោសនោះ បញ្ចេញធ្វើការទាក់ច្រវាក់ក ។

[០៩:៣៣:៣៦]

**ស៖** លោកបាននិយាយថា មានអ្នកទោសបីនាក់ តើលោកអាចរៀបរាប់បានទេ? ថាតើពួកគេនោះជានរណាខ្លះ?

**ឆ៖** អ្នកទោសដែលនៅរស់ទុំង? នៅរស់ដូចខ្ញុំរៀបរាប់មិញអ៊ីចឹង ដែលមានឃើញសព្វថ្ងៃនៅតែ១)ឈ្មោះ អូន ២) ឈ្មោះ បង ៣) ឈ្មោះ ស៊ន ដែលជាប់មន្ទីរគាត់ហ្នឹង គាត់ដោះលែង ។ ឃើញនៅរស់បីហ្នឹង ។

**ស៖** តើអ្នកទាំងអស់នេះត្រូវបានឃុំខ្លួននៅក្នុងផ្ទះ នៅក្នុងរណ្តៅ តើលោកអាចរៀបរាប់កន្លែងដែលអ្នកទាំងបីនាក់ហ្នឹង ដែលថាត្រូវឃុំខ្លួននោះ ឃុំកន្លែងណា?

**ឆ៖** អ្នកទាំងបីមុនដំបូង គាត់ជាប់ គាត់ដោះលែងសម្រាលនៅក្រៅៗគុកវិញ ។

**ស៖** តើលោកអាចប្រាប់យើងបានទេ ថាតើអ្នកទោសទាំងអស់ហ្នឹងគឺថា មានចំណីអាហារហូបគ្រប់គ្រាន់ដែរ ឬទេ?

**ឆ៖** រឿងចំណីអាហារហូបមិនសូវបានគ្រប់គ្រាន់ទេ ហូបតែបបរហ្នឹង ដាក់ក្នុងបំពង់ឲ្យ ដូចអ្នកទោសអ៊ីចឹង មិនបាច់ថា អ្នកទោសទេ គ្រាន់តែកងការពារដូចចំពោះរូបខ្ញុំហ្នឹង ក៏គាត់ឲ្យបបរហូបបន្តិចៗអ៊ីចឹង ធ្វើការងារអីអត់ចង់កើតផង ទម្រាំដល់អ្នកទោសទៀតគ្នាល្វីងល្វន់ដូចឆ្កែអត់បាយអ៊ីចឹងដែលគាត់ធ្វើបាប ។

**ស៖** តើលោកបានសង្កេតឃើញថា តើទោសទាំងអស់នោះបានរបបអាហារដូចគ្នា ដូចជាបុគ្គលិកអ្នកនៅ ម-១៣ ទេ ឬក៏ទាំងអស់គ្នាហូបអាហារបបរដូចគ្នានោះ?

**ឆ៖** អ្នកទោសក៏ហូបបបរ អ្នកកងការពារហ្នឹងក៏បបរដូចគ្នា ។ ប៉ុន្តែ គ្រាន់បបរខុស អ្នកទោសបបររាវ កងការពារបបរខាប់ ។

[០៩:៣៦:៥៣]

**ស៖** តើលោកបានឃើញអ្នកណាស្លាប់ដោយសារអត់អាហារដែរទេ នៅទីនោះ?

**ឆ៖** បាទ, អត់បានឃើញទេ ។

**ស៖** តើលោកបានឃើញអ្នកទោសស្លាប់ដោយសារមានជំងឺទេ?

**ឆ៖** បាទ, អត់ដែរ ។

**ស៖** តើលោកបានសង្កេតឃើញនូវចំណុចណាមួយ នៅពេលដែលមានភ្លៀងធ្លាក់ខ្លាំងនៅថ្ងៃមួយ តើលោកបានសង្កេតឃើញថា តើអាចមានបញ្ហាទេ? ដោយសារភ្លៀងធ្លាក់ខ្លាំងនោះ មានបញ្ហាអ្វី?

[០៩:៣៧:៥៥]

**ឆ៖** បាទ, កាលភ្លៀងធ្លាក់ខ្លាំងនុ៎ង មានទឹកជន់ ។ មន្ទីរហ្នឹងនៅៗម្ខាងស្ទឹង មាត់ស្ទឹងហ្នឹងតែម្តង ម្លោះហើយទឹកស្ទឹងជន់រឹបអ៊ីចឹងមក មិនថាអ្នកទោស អ្នកកងការពារទេ រឹបមកគឺថាគ្រាន់តែកងការពារឡើងសុទ្ធចុងឈើអត់ចង់សឹងទាន់ផង លឿននោះលឿន មហាសែនលឿនទឹក ។ នៅក្នុងពេលហ្នឹង ក្នុងរណ្តៅហ្នឹងមានដោះរួចខ្លះ មិនរួចខ្លះដែរ ឃើញស្លាប់ដែរហ្នឹងនៅក្នុងគុកហ្នឹង ប៉ុន្តែមិនច្រើនប៉ុន្មានទេ ព្រោះអ្នកទោសវានៅតិច ។ ខ្ញុំឃើញលិចទឹកមានមែន ។

**ស៖** អ្វីដែលលោកបានប្រាប់យើងនោះ គឺថាអ្នកទោសខ្លះត្រូវបានជាប់ខ្នោះនៅក្នុងរណ្តៅ អ្នកខ្លះត្រូវបានលង់ទឹកស្លាប់នៅក្នុងរណ្តៅនោះ តើពិតដូចដែលចម្លើយនោះទេ?

**ឆ៖** ការពិត ។

**ស៖** នេះជាអ្វីដែលលោកបានឃើញដោយផ្ទាល់ភ្នែករបស់ខ្លួនផ្ទាល់?

**ឆ៖** បាទ, បានឃើញ ។

**ស៖** លោកបានប្រាប់យើងថា នៅក្នុងម-១៣នោះ គឺថាអ្នកទោសត្រូវបានគេចង ហើយគេបានសួរចម្លើយអ្នកនោះ តើលោកអាចប្រាប់យើងឲ្យច្បាស់ជាងហ្នឹងបានទេ? អ្វីខ្លះដែលលោកបានឃើញទាក់ទងទៅនឹងការសួរចម្លើយ? តើគេប្រើវិធីអ្វីខ្លះក្នុងការសួរចម្លើយអ្នកទោសហ្នឹង?

**ឆ៖** បើតាមខ្ញុំបានឃើញ គឺសួរចម្លើយ ស្រាតខោ ស្រាតអាវអ៊ីចឹង រើសួរចម្លើយអ្នកទោសហ្នឹងខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំបាទ ។

[០៩:៤០:១៧]

**ស៖** ហើយនរណាជាអ្នកសួរចម្លើយនោះ?

**ឆ៖** គឺតា ឌុច ហ្នឹងតែម្តង ។

**ស៖** តើលោកបានឃើញអ្នកណាផ្សេងទៀតជាអ្នកសួរចម្លើយទេ ឬក៏មានតែជនជាប់ចោទម្នាក់ដែលជាអ្នកសួរចម្លើយនៅទីនោះ?

**ធ៖** ក្នុងនោះមានគ្នាគាត់ពីរនាក់ ឈ្មោះ ចាន់ មួយ ដែលអាចសួរចម្លើយអ្នកទោសហ្នឹងមានតែពីរនាក់ទេ ។

**ស៖** គឺថាមានតែពីរនាក់ ។ អ៊ីចឹងមានតែពីរនាក់ មានតែ ឌុច ហើយនិងម្នាក់ទៀតទេ អ៊ីចឹង ឬម៉េច?

**ធ៖** បាទពិត ។ មានតែតា ឌុច ហើយនឹងតា ចាន់ ហ្នឹងទេ ។

[០៩:៤១:៤៧]

**ស៖** តាមដែលខ្ញុំយល់ច្បាស់ពីលោកនោះ គឺថាលោកបានឃើញ ឌុច វាយអ្នកទោស តើអ៊ីចឹងពិតទេ?

**ធ៖** បាទ, ពិត ។

**ស៖** តើគាត់បានប្រើអ្វីដើម្បីវាយអ្នកទោសនោះ?

**ធ៖** ប្រើ ជួនកាលដំបងយើងហ្នឹងធម្មតាហ្នឹងវ៉ៃអ្នកទោសសួរអ៊ីចឹង រួចបើម្នាក់ទៀតនោះ ខ្ញុំឃើញគាត់រហូតដល់ដុតទាំងរស់ទៀតនុះ ចាប់ព្យួរ ចងព្យួរដុតទៀតនុះ ហ្នឹងត្រូវជាមីងខ្ញុំទៀត ខ្ញុំអត់ហ៊ានមាត់ទេកាលនុំង ។ កាលណាមាត់ទៅគេថា យើងនឹងខ្សែរយៈអី ខ្ញុំខ្លាចដែរ ។ ខ្ញុំដែលឃើញគាត់ធ្វើទារុណកម្មពិត ច្បាស់នៅភ្នែកខ្ញុំហ្នឹង ចងមានដាក់ប្រេង ដាក់អីដុតគ្នាដោះអាវអស់មនុស្សស្រី ។

**ស៖** នៅពេលដែលលោកបានឃើញថា អ្នកនោះ អ្នកដែល-- តើជាបុរសស្ត្រី ឬក៏គ្រាន់តែជាមនុស្សធម្មតា អាចសម្គាល់បានទេ ពេលនោះ?

**ធ៖** ត្រង់ហ្នឹងស្តាប់អត់បានទេបង មិនដឹងថាម៉េច?

**ស៖** ខ្ញុំបញ្ជាក់ឡើងវិញ លោកបាននិយាយថា លោកបានឃើញ ឌុច វាយទៅលើអ្នកទោស តើអ្នកទោសទាំងហ្នឹង ដែល ឌុច បានវាយនោះ គឺវាយតែបុរសអ្នកទោសប្រុស ឬក៏ស្រីក៏គាត់វាយដែរ?

**ធ៖** ក្នុងហ្នឹងមាន ដែលខ្ញុំមានប្រសាសន៍មិញអ៊ីចឹង គឺថាមានទាំងប្រុស មានទាំងស្រី ។ស្រីដល់ទៅដុតទៀតឯនោះ បើត្រឹមតែប្រុស ត្រឹមតែវាយទេ មនុស្សស្រីដោះអាវដោះអីដុតទាំងដោះគ្នាទៀតនោះ ហ្នឹងខ្ញុំឃើញពិតតែម្តង ពិសេសក្មួយខ្ញុំនៅពាមហ្នឹងតែម្តង ។

[០៩:៤៤:៥១]

**ស៖** ដូច្នេះលោកផ្ទាល់បានឃើញ ឌុច គឺយកភ្លើងទៅអុចទ្រូង ឬក៏ដោះស្ត្រី ដើម្បីជាធ្វើទារុណកម្ម តើពិតមែនទេ? ឃើញផ្ទាល់ភ្នែក?

**ឆ៖** បាទ, ឃើញពិតផ្ទាល់ភ្នែក ។ ឃើញឌុត រុំប្រែងយើង ប្រែងកាតហ្នឹងជាប់នឹងឈើ រុញទៅចំដោះគ្នាហ្នឹង ឌុតទាំងរស់ហ្នង ។ ឃើញពិត ការពិតហើយហ្នឹង ។ ខ្ញុំបានឈរមើលទៀត ។

**ស៖** តើហេតុការណ៍នោះកើតឡើងជាញឹកញាប់ ឬក៏កើតឡើងតែម្តងទេ?

**ឆ៖** បាទ, កើតម្តងហ្នឹង ខ្ញុំឃើញម្តង ឌុតមនុស្សស្រី ខ្ញុំឃើញម្តង ឃើញម្នាក់ហ្នឹងទេ និយាយចំ ឃើញម្នាក់ ។

**ស៖** តើលោកនៅចាំទេ? តើអ្នកទោសនោះត្រូវបានគេសម្រាតនននលគក ឬក៏នៅមានសម្លៀកបំពាក់អ្វីខ្លះដែរ នៅពេលដែលគេធ្វើទារុណកម្មនោះ?

**ឆ៖** អត់ៗ មានស្រោត ដោះតែអាវទេ។ ដោះអាវអស់ហើយ ឌុតដោះ ។

**ស៖** តើលោកបានឃើញអ្នកទោសបានគេចងព្យួរជើងឡើងទេ នៅពេលដែលគេសួរចម្លើយនោះ?

**ឆ៖** បានឃើញ ។ ប៉ុនគ្រាន់តែអត់មានព្យួរជើងឡើងលើ ។ ចងតែដៃ ចងស្ពាបសេកយកព្យួរដើមឈើអ៊ីចឹង ។ ស្រាតខោស្រាតអាវអស់ ចងព្យួរអ៊ីចឹង ។ ខ្ញុំបានឃើញពិត ។

**ស៖** តើលោកបានឃើញអ្នកទោសណាម្នាក់ត្រូវបានគេយកទៅជ្រមុជទឹកនៅក្នុងអូរ ឬក៏ជ្រមុជនៅកន្លែងណា ដើម្បីសួរចម្លើយទេ?

**ឆ៖** ខ្ញុំបានឃើញ ។ ប៉ុន្តែ ខ្ញុំភ្លេចឈ្មោះបាត់ហើយ ស្រីហ្នឹង ។ គេយកទៅជ្រមុជទឹកហ្នឹង ។ ជាន់សួរចម្លើយ ជ្រមុជទឹក ។ គ្នាគាត់មានបីនាក់ នៅខាង“គ”មន្ទីរហ្នឹង ។ ប៉ុន្តែ ខ្ញុំអត់ស្គាល់មនុស្សស្រីហ្នឹងទេ ខ្ញុំឃើញដែរ ។ ពិតជាឃើញហ្នង ។ ជាន់ជ្រមុជទឹកហ្នឹង សួរចម្លើយ សួរមិនឆ្លើយជាន់ពន្លិចទឹក ។ ពិតបានជាឃើញ ។

**ស៖** នៅពេលដែលលោកនិយាយថា ជ្រមុជ ជាន់ជ្រមុជក្នុងទឹក លោកនិយាយថាជ្រមុជគឺថាដងខ្លួនទាំងមូល ឬក៏ជាន់តែក្បាលពន្លិចទេ?

**ឆ៖** ជាន់ពន្លិចទាំងអស់ហ្នឹង គ្នាចប់ដង្ហើម ឃើតខក ខំងើបមកជាន់ទៀត ។

**ស៖** តើកើតមានឡើងជាញឹកញាប់ទេ? ឬក៏ប្រើពេលយូរទេ? ឬក៏គ្រាន់តែកើតម្តងហ្នឹង លើកក្រោយមិនមានទេ?

**ឆ៖** បាទ, ខ្ញុំឃើញម្តងទេ ។ លើកក្រោយអត់មានទៀតទេ ។ ឃើញតែម្តងហ្នឹង ជាន់ពន្លិចក្នុងទឹកហ្នឹង ឃើញម្តងហ្នឹងទេ ។

[០៩:៤៩:៣៨]

**សះ** តើលោកបានឃើញថានៅក្នុងពេលសួរចម្លើយនោះ? តើគេប្រើឧបករណ៍អ្វី? តើលោកបានឃើញ ឬក៏ថាម្ជុលគេយកទៅចាក់នៅក្នុងក្រចក ចាក់ក្រចកអ្នកទោស ទៅលើក្រចកដៃក្រចកជើង ដើម្បីសួរចម្លើយដែរឬទេ?

**ផះ** បាទ, អត់បានឃើញទេ ។

**សះ** ឥឡូវនេះទាក់ទងទៅនឹងជនជាប់ចោទ តើលោកបានឃើញជនជាប់ចោទ បាញ់សម្លាប់អ្នកទោសណាម្នាក់ ឬក៏ច្រើនឬទេ?

**ផះ** ត្រង់ហ្នឹង ខ្ញុំសុំឆ្លើយការពិត ។ បាទ, ឃើញ ។ ពូខ្ញុំបង្កើត តាស៊ីយ ហ្នឹងហ្មង ។ គាត់បានចងជាប់បង្គោលមួយ ចងជាប់បង្គោលហើយ គាត់បាញ់កាំភ្លើងអាកាពីរគ្រាប់ ។ បាញ់មួយគ្រាប់មុនដំបូង ចំពីដៃនេះ ក៏ធ្លាយខាងនេ៎ះ ។ មួយគ្រាប់មកទៀត មកចំដើមទ្រូងនេះ ។ គាត់បានដាច់ខ្យល់ប៉ាត់ ។ ហ្នឹងពូខ្ញុំបង្កើតហើយ ។ ហ្នឹង! តាឌុច ហ្នឹង បាញ់ពូខ្ញុំ សម្លាប់មុខខ្ញុំហ្នឹងហ្មង ។ ខឹងណាស់ខ្ញុំនឹង ។ ខ្ញុំសុំកងការពារ រហូតដល់គាត់ដាក់គុកខ្ញុំទៀតណោះ ។ បាញ់ទាំងពូខ្ញុំស្លាប់នៅបង្គោលទៀត ។ ខ្ញុំនិយាយអួលដើមក ។ ខ្ញុំបានឃើញតែពូខ្ញុំមួយទេគាត់បាញ់ ។

សះ តើលោកបានឃើញហេតុការណ៍ណាមួយ? ឬក៏ឧប្បត្តិហេតុណាមួយ? ដែលឌុច បានសម្លាប់ បាញ់ទៅរកអ្នកទោស ដើម្បីសម្លាប់នោះ?

**ផះ** បាទ, អត់ដឹងផង។ ឃើញគាត់ចងជាប់បង្គោលហ្នឹងហ្មង ដឹងរឿងហេតុអី សួរចម្លើយអត់ដឹង អីដឹងបានគាត់ទៅធ្វើអ៊ីចឹង។ រួចចំពូខ្ញុំបង្កើតទៀត ។

**សះ** តើលោកបានដឹង ហេតុអ្វីបានជាគេបាញ់សម្លាប់ឪពុកមារបស់លោក?

**ផះ** បាទ, ខ្ញុំអត់បានដឹងផង បើឃើញគាត់ទៅនៅក្នុងគុកហ្នឹងស្រេច ស្រាប់តែថ្ងៃមួយពេលព្រឹកហ្នឹង ឃើញគាត់ចងជាប់បង្គោល ស្មានចងវៃសួរចម្លើយ។ ហាត់តែខ្ញុំកំពុងអង្គុយដក់បារី ឮស្នូរផាំង! ខ្ញុំភ្ញាក់ព្រើត! ស្មានតែស្ទុះឆក់កាំភ្លើងបាញ់កងការពារតើ ដល់មើលទៅឃើញពូខ្ញុំហ្នឹង ញ័រទទ្រើតនៅបង្គោលហ្នឹង គាត់ដាក់មួយគ្រាប់ទៀត ដួលមកដល់ដីហ្មង ដឹងជារឿងអី ខ្ញុំអត់បានដឹងដែរ ។ ព្រោះគាត់អ្នកសួរចម្លើយ ។

**សះ** តើលោកនៅខាងក្រោម-១៣ នៅពេលណាមួយ តើលោកបានឃើញអ្វីទេក្នុងករណី គឺថាមានកន្លែងមួយ ដែរថាលោកបានឃើញមានសាកសពមនុស្សច្រើននៅកន្លែងនោះ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបានឃើញ ។ ថ្ងៃមួយ ខ្ញុំបាន ដូចថាស្រុបក់ហ្នឹង ខ្ញុំសល់ចុងឈ្លួសពីអានងអ៊ីចឹង។ រៀបខ្ញុំ និងអ្នកទោសហ្នឹង អ្នកទោសស្រាលៗ ដែលគាត់ដោះលែងនៅក្រៅអ៊ីចឹង ខ្ញុំនេះ ក៏បបួលអ្នកទោសទៅចុង-- ដេញឈ្លួសហ្នឹង ។ ទៅដល់គាត់ហៅខ្ញុំមកថា អាណានាំអ្នកទោសទៅដេញឈ្លួសអ៊ីចឹង ទៅផ្លូវហ្នឹងធ្វើអី ។ ខ្ញុំអត់ដឹង គាត់កន្លែងហ្នឹង ជាសម្លាប់អ្នកទោសទេ អត់ឃើញទេ ។ ដល់អ៊ីចឹងខ្ញុំនែ៎ គាត់ហៅមកក្នុងមន្ទីរវិញ គាត់សួរម៉េចបាននាំអ្នកទោសទៅតាមហ្នឹង មិនដឹងកន្លែងគាត់លាក់ការណ៍ណាបង ។ ថ្ងៃមួយគាត់អត់បាននៅ គាត់ចេញពីមន្ទីរ ខ្ញុំទៅលួចមើលកន្លែងហ្នឹង ខ្ញុំដឹង ។ ទៅដល់បានឃើញរណ្តៅហ្នឹងបីបួនរណ្តៅ សុទ្ធតែសពនៅពេញហ្នឹង នៅខាងត្បូងស្ទឹង ។ ខ្ញុំអត់មានដឹងរលីង បើខ្ញុំអ្នកនៅសេដ្ឋកិច្ច មានបានដើរណា ដល់ពេលនាំអ្នកទោសចូលផ្លូវហ្នឹង កន្លែងលាក់ការគាត់ខ្ញុំមានដឹងណា ។ ទាលគាត់ចេញបាត់ ខ្ញុំលេចទៅស៊ើបមើលកន្លែងហ្នឹងបានដឹង ។ ឃើញពិតមែនប្រហែលប្រាំ ប្រាំមួយរណ្តៅប៉ុណ្ណឹង ។

**ស៖** តើមានអ្វីខ្លះ នៅក្នុងរណ្តៅទាំងនោះ?

**ឆ៖** បាទ, នៅក្នុងរណ្តៅនោះ មានឃើញសពនៅក្នុងហ្នឹង ។

**ស៖** តើមានសាកសពច្រើនទេ? តើមានសាកសពកុមារនៅជាមួយ ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំឃើញអត់មានកុមារទេ ។ ឃើញសុទ្ធតែមនុស្សចាស់ ។

**ស៖** ពីមុនលោកបានបញ្ជាក់ថា លោកបានមានបញ្ហាជាមួយ ឌុច តើអ្វីជាបញ្ហា រឿងដែលមានរឿងជាមួយ ឌុច ជាជនជាប់ចោទ តើលោកអាចពន្យល់យើងបានទេ?

**ឆ៖** បាទ, បាន ។ ខ្ញុំមានរឿងជាមួយគាត់នេះ គាត់ឱ្យខ្ញុំយាមអ្នកទោស ។ ខ្ញុំដូចថាមកពីខាងរកសេដ្ឋកិច្ចឱ្យអ្នកទោសអ៊ីចឹង គាត់ខ្វះកម្លាំងការពារ ក៏ឱ្យខ្ញុំយកបីនាក់ទៅយាមធ្វើទំនប់។ ដល់ធ្វើទំនប់អ៊ីចឹងខ្ញុំបាទវាអស់កម្លាំងពេក ងងុយដេក អ្នកទោសហ្នឹងគាត់ច្រវាក់ដាច់រត់ ។ រត់ទៅ ខ្ញុំនែ៎ក៏បាញ់ឡើងលើពីរគ្រាប់ បាញ់ទៅ កងការពារផ្អើលឆុលទៅ គេថាអ្នកទោសរួចខាងណា គេថារួចខាងឈ្មោះឿន ។ បើអ៊ីចឹង ហៅវាមកនែ៎ បាទទៅដល់ដោះខោដោះអាវ ដកទាំងកាំភ្លើងខ្ញុំមកអស់ទៀតនៅតែខោខ្លីមួយគត់ខ្ញុំ ។ មកដល់មន្ទីរហ្នឹង គេយកទាំងសាក់កាដូទៀត គ្រាន់តែអង្រឹងដេកអត់ឱ្យផង ហើយគាត់បញ្ចូលក្នុងគុក ។ បញ្ចូលខ្ញុំដាក់ក្នុងគុក ។ តាំងពីគាត់ដាក់គុកខ្ញុំទៅ ក៏ខ្ញុំហ្នឹង គាត់បញ្ចេញធ្វើការយាម ក៏គាត់យាមផ្ទាល់ដៃគាត់ដែរ តាឌុច ហ្នឹង កាំភ្លើងអាកាមួយដើម ។ បានថ្ងៃមួយ ខ្ញុំភ័យពេក របងគុកឫស្សី ខ្ញុំហែករត់ទាំងយប់ ម៉ោងពីរដប់យប់ ។ រត់ទៅនៅសហករណ៍គេ ឱ្យសហករណ៍ជួយខ្ញុំ ។

កុំអីខ្ញុំត្រូវស្លាប់នៅមន្ទីរតា ឌុច ហ្នឹងហើយ។ មានគេខ្សឹបប្រាប់ខ្ញុំទៀត អ្អែងបើមិនរត់ងាប់ ។ មិនចាំបាច់ថាអ្នកទោស អ្នកការពារទេ តាហ្នឹងឲ្យថាខុសគាត់បាញ់ហើយ ។ បើគាត់និយាយមុខស្លូតមិនអីទេ ប្រយ័ត្នអាហ៎សៗតិចហ្នឹង អាទ្រង់សើចហ្នឹង ប្រយ័ត្នឲ្យមែនទែន កងការពារហើរជើងឥឡូវហ្នឹង ។ អាក្រក់ក្រីណាស់អាតាហ្នឹង ហ្នឹងខ្ញុំជាប់គុកដោយសារខ្ញុំឲ្យរួចអ្នកទោសហ្នឹងទេ គាត់ដាក់គុកខ្ញុំហ្នឹង ។ ហើយបានខ្ញុំទៅនៅសហករណ៍ សហករណ៍មកធានា បានគាត់លែងខ្ញុំទៅ បានខ្ញុំនៅរស់ដល់រាល់ថ្ងៃហ្នឹង ។ បើថានៅជាមួយគាត់ ស្លាប់បាត់ដូចអ្នកទោសអ៊ីចឹង ។

[០៩:៥៨:២៣]

**ស៖** អ្នកទោសដែលអាចរត់រួចខ្លួន ថាតើមានច្រើន ដែរឬទេ? ចំពោះអ្នកដែលរត់ទាំងអស់ហ្នឹង ថាតើមានចំនួនច្រើន ដែរឬទេ? ដែលអាចរត់គេចខ្លួនបាន ?

**ឆ៖** អ្នកទោសរត់តែបីនាក់ហ្នុង ខ្ញុំយាមតែបីនាក់ហ្នឹង ។ កាត់ច្រវាក់រត់ទៅ ខ្ញុំដេកលក់ បើវាយកភ្លើងបាញ់ងាប់បាត់ ប៉ុន្តែ វាអាណិតខ្ញុំដែរ ។ វាចេះរត់កាត់ច្រវាក់បាន ពូថៅមួយៗម្នាក់ ទៅកាប់ឈើហ្នឹង រត់ទៅរត់តែបីនាក់ហ្នឹងទេ រត់ខាងមុខសញ្ញាខ្ញុំហ្នឹង អត់មានរត់ច្រើនទេ រត់រួចតែបីហ្នឹង ខ្ញុំយាមតែបីនាក់រួចទាំងបីហ្នឹង ។

**ស៖** ថាតើលោកស្គាល់អ្នកទោសទាំងអស់នោះ ដែរឬទេ? ហើយលោកបានជួយពួកគេឲ្យដើម្បីឲ្យរួចខ្លួន ដែរឬទេ?

**ឆ៖** ខ្ញុំស្គាល់ មួយឈ្មោះ ម៉ន ពីរនាក់នោះ ខ្ញុំអត់ស្គាល់ទេ ។

**ស៖** លោកឲ្យរួចខ្លួន ឬក៏លោកជួយពួកគេឲ្យរត់? ឬក៏អ្នកទោសទាំងអស់នោះរត់ដោយខ្លួនឯង?

[០៩:៥៩:៥៣]

**ឆ៖** បាទ, អ្នកទោសនោះសុំខ្ញុំរត់ ខ្ញុំឲ្យកាត់ច្រវាក់ ។ ខ្ញុំយកលេសខ្លាចតាឌុច ហ្នឹងរករឿងខ្ញុំដឹងហើយថា ធ្វើម៉េចបើគេចាប់បានកុំឆ្លើយដាក់ខ្ញុំឲ្យសោះ ។ ប៉ុន្តែ ខ្ញុំអត់មានប៊ានអាចជួយកាត់ច្រវាក់ទេ ព្រោះខ្ញុំមានកាំភ្លើង ។ អ៊ីចឹងហើយ ខ្ញុំបញ្ជាពីចម្ងាយថា ពូថៅបីហ្នឹងធ្វើម៉េច? អាពូថៅកាប់ឈើអាមួយដាក់ខាងក្រោម អាពីរហ្នឹងគឺដំ ។ ដាក់ច្រវាក់អាប៉ុនៗកូនដៃយើងដំទម្រាំតែដាច់អស់-- ឆែបអស់ពូថៅមួយ ។ ខ្ញុំថា ប្រាប់ថាឥឡូវដាច់បានម្នាក់ៗហើយ អាពូថៅមួយទៀតហ្នឹង គឺថាអាឆែបហ្នឹងចោល យកអាពូថៅមួយទៀត យកអាឆែបហ្នឹងមកដំរិញ ដាក់ឲ្យមានមុខដំទៀត ដាច់បានពីរៗនៅម្នាក់ហ្នឹង

ទៀត ។ ខ្ញុំថាឲ្យយកពូថៅពីបាតក្រោម អាបន្ទាប់ពីឈើហ្នឹង ព្រោះអាពីរវាឆែបហើយ យកមកដាច់ទៀតបានដំដាច់អស់ត្រឹមៗកហ្នឹង អត់ប៊ានានេះទេ-- ថាកាត់វែងៗ វាធ្ងន់ច្រវាក់ហ្នឹង ។ ច្រវាក់ហ្នឹងវែងៗណាស់ ។ កាត់ត្រឹមៗសល់ពីកប៉ុណ្ណឹងទេ។ រត់ ។ បានរត់ទៅ មួយសន្ទុះបានខ្ញុំបាញ់ឡើងលើពីរគ្រាប់ ។

**ស៖** នៅពេលដែលអ្នកទោសរត់ថា តើវាកើតឡើងនៅក្រៅ ម-១៣ ឬក៏យ៉ាងម៉េច? ឬក៏វាកើតឡើងនៅក្នុង ម-១៣ នេះតែម្តង ជាកន្លែងដែលពួកគេធ្វើការ ?

**ឆ៖** បាទ, កើតនៅកន្លែង ម-១៣ ផ្អើលឈ្ងូមក ដូចខ្ញុំមានប្រសាសន៍មិញថា អ្នកទោសរួចខាងណា? រួចខាងខ្ញុំ រួចខ្ញុំអត់ប៊ានប្រាប់ត្រង់ទេ ប្រាប់ថាខ្ញុំដេកលក់ អត់ប៊ានប្រាប់ថា ដោះលែងទេ ព្រោះថាដោះលែង គឺខ្ញុំហ្នឹងមុខជាងាប់មុនអ្នកទោសហ្នឹងហើយ ។ អ៊ីចឹង ខ្ញុំប្រាប់ថាធ្វើដេកលក់ ។ ប៉ុន្តែគំនិតខ្ញុំឈ្មោះ ម៉ន ហ្នឹង ពួកម៉ាកខ្ញុំនៅធ្វើសង្គ្រាមវាយ លន់ នល់ ជួបគ្នាគាត់យកមកដាក់គុកហ្នឹង ។ អ៊ីចឹងខ្ញុំអាណិតតើ! ដោះហ្នឹងមួយ អ៊ីចឹងដោះទាំងអស់ ។ កាត់រួចមក គឺវាមានកើតហេតុនៅក្នុងមន្ទីរហ្នឹងហ្នង មកចាប់ខ្ញុំមកដកកាំភ្លើងពីខ្ញុំ ស្រាតខោ ស្រាតអាវខ្ញុំនៅតែខោខ្លីចូលគុកហ្នឹងហ្នង ។ ជាពិសេសបញ្ហា តាឌុច ផ្ទាល់។

**ស៖** ដូច្នេះតើលោកឃើញ ឌុច ម្តងទៀតដែរ ឬទេនៅពេលដែលលោកមក-- លោកឃើញគាត់ម្តងទៀត ឬទេនៅពេលដែលលោករត់ចេញទៅសហាគមន៍ហ្នឹង? តើលោកឃើញគាត់ដែរឬទេ?

**ឆ៖** បាទ ឃើញ ។ ទៅដល់សហករណ៍ហ្នឹង ប្រធានភូមិគេបញ្ជូនមកម្តងទៀត ។ បញ្ជូនមកកន្លែង តាឌុច ហ្នឹង ។

[១០:០៣:០០]

**ស៖** ដូច្នេះនៅពេលនោះ ឌុច ប្រាប់លោកថាម៉េច?

**ឆ៖** ឌុច ប្រាប់ថា ប្រាប់ប្រធានភូមិថា ឥឡូវឲ្យគាត់នៅហ្នឹងមួយរយៈខ្លីសិនទៅ រួចលោកបញ្ជូនទៅតាមសហករណ៍វិញចុះ អត់អីទេ ។ ចាំ ខ្ញុំធ្វើសំបុត្រឲ្យគាត់នៅតាមសហករណ៍ ។

**ស៖** តើលោកដឹងថា នៅពេលណា? ហើយតើមន្ទីរម-១៣ នេះឈប់ដំណើរការតាមរបៀបណាហើយវាឈប់នៅពេលណា? នៅពេលណាដែលលែងមានអ្នកទោសទៀតហើយនៅម-១៣? ហើយវាកើតឡើង ម-១៣ នេះវាបញ្ចប់នៅពេលណា?

**ឆ៖** ពេលនោះខ្ញុំអត់បានដឹងទេ ។ ប៉ុន្តែ ខ្ញុំមកមន្ទីរ ឌុច ហ្នឹង គាត់បញ្ជូនមក គាត់បញ្ជូនខ្ញុំមក

សហករណ៍ ខ្ញុំបាទលែងបានដឹងដំណឹងហើយ ព្រោះខ្ញុំអត់បាននៅជាមួយគាត់ ព្រោះគាត់ដោះលែងខ្ញុំឲ្យទៅនៅតាមសហករណ៍ ខ្ញុំក៏អត់បានដឹងរឿងដឹងអីទេ ខ្ញុំដឹងតែប៉ុណ្ណឹងទ ។ ដឹងតែខ្ញុំនៅជាមួយគាត់រឿងកាប់សម្លាប់ត្រង់ណាៗអីដែលធ្វើបាបអ្នកទាំងប៉ុន្មានខ្ញុំដឹងតែប៉ុណ្ណឹងទេ ។ ក្រៅពីហ្នឹងទៅ ខ្ញុំចេញទៅនៅសហករណ៍ខ្ញុំលែងដឹងហើយ ព្រោះខ្ញុំនៅសហករណ៍បាត់ហើយ ។ ខ្ញុំបានរយៈអត់បានមួយឆ្នាំផង ។

**ស៖** លោកនិយាយអំពីពូរបស់លោក ថាតើមានគ្រួសារ សមាជិកគ្រួសាររបស់លោកត្រូវបានឃុំខ្លួននៅម-១៣ ដែរឬទេ? ឬក៏បុគ្គល ឬក៏មនុស្សផ្សេងៗមកពីគ្រួសាររបស់លោកត្រូវបានជួល បានន័យថា ត្រូវបានយកឲ្យធ្វើការនៅម- ១៣ ដែរឬទេ?

**ឆ៖** (ឮមិនច្បាស់) លើកបងប្អូនហ្អេកបង? ស្តាប់អត់សូវបានទៀតទេ ។

**ស៖** ថាតើមានបងប្អូនរបស់លោកត្រូវបានឃុំខ្លួននៅម-១៣ ដែរឬទេ ក្រៅពីពូរបស់លោក?

**ឆ៖** អត់ទេ មានតែពូហ្នឹងមួយទេ ហើយនិងមីងមួយទេ (ឮមិនច្បាស់) ដែលឃើញតែគាត់ទៅដោះហ្នឹងទេ ។ មានតែពូមួយមីងមួយទេនៅឃុំឃាំងមន្ទីរ-១៣ ហ្នឹងទេ មានតែពីរនាក់ហ្នឹងទេ ។

**ស៖** តើមានបងប្អូនដទៃទៀតរបស់ពូ ដូចជា ក្មួយផ្សេងៗដែលត្រូវបានគេយកទៅធ្វើជាអ្នកយាមនៅម-១៣ ឬក៏ជាបុគ្គលិករបស់ ម-១៣ ដែរឬទេ?

**ឆ៖** បាទ, អត់មានទេ ។

**ស៖** តើមានអ្នកយាមដែលត្រូវបានគេជ្រើសរើសនោះ គាត់មកពីអមលាំង ឬក៏យ៉ាងម៉េច?

[១០:០៦:៤៥]

**ឆ៖** បាទ, អ្នកកងការពារហ្នឹងពីអមលាំង ច្រើនដែរបង ។

**ស៖** តើគាត់ទាំងអស់នោះមានអាយុប៉ុន្មានអ្នកយាមនុ៎ង?

**ឆ៖** នៅកងការពារ ខ្ញុំបាទបានស្គាល់ខ្លះ មិនស្គាល់ខ្លះ ។ មានចំនួនប្រហែលជាដប់នាក់ដែរ ។

**ស៖** ថាតើអ្នកយាមទាំងអស់នោះជាមនុស្សពេញវ័យ ឬក៏អ្នកយាមហ្នឹងជាក្មេងៗតែប៉ុណ្ណោះទេ?

**ឆ៖** មានតូច មានធំ អ៊ីចឹងដែរ លាយគ្នា ។ បាទ កងការពារគាត់មានធំដូចជាខ្ញុំហ្នឹង ដែលប្រាំប្រាំមួយនាក់អ៊ីចឹងទៅ ក្មេងៗកុមារអ៊ីចឹងទៅ ។

**ស៖** នៅពេលដែលលោកនិយាយថាក្មេងៗ តើក្មេងៗនោះប្រហែលអាយុប៉ុន្មាន?

**ឆ៖** ប្រហែលអាយុដប់ជាង ដប់ពីរ ឬដប់បី ប៉ុណ្ណឹង តូចៗទេ ល្មមៗដែរទេ ។

**ស៖** ថាតើលោកឃើញ ឌុច លោកបាននិយាយមុនហ្នឹងថា គាត់បាញ់ពូរបស់លោក ថាតើ

លោកឃើញគាត់ ឌុច ហ្នឹង តើលោកឃើញ ឌុច ហ្នឹង បញ្ជាឲ្យអ្នកយាមបាញ់អ្នកទោស ឬក៏បញ្ជាឲ្យនាំអ្នកទោសទៅឆ្ងាយ ដើម្បីសម្លាប់ចោលដែរឬទេ?

**ឆ៖** នេះខ្ញុំឃើញផ្ទាល់ភ្នែកខ្ញុំ ឮខ្ញុំហ្នឹង អត់មានកងការពារបាញ់ទេ ។ ឲ្យកងការពារចងហើយគាត់បាញ់ខ្លួនគាត់តែម្តង បាញ់ដូចកាំភ្លើង អាកា *(AK)* ។

**ស៖** ប៉ុន្តែ ក្រៅពីឮរបស់លោក តើលោកឃើញ ឌុច បានបញ្ជាអ្នកយាមឲ្យបាញ់អ្នកទោសដែរឬទេ?

**ឆ៖** បាទ, អត់ទេ ឃើញគាត់បាញ់ផ្ទាល់ដៃតែម្តង ។

**ស៖** តើលោកឃើញ ឌុច សរសេររបាយការណ៍ ឬក៏គាត់សរសេរឯកសារដែរឬទេ? តើលោកឃើញគាត់សរសេរ ឬក៏ធ្វើរបាយការណ៍ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំឃើញតែញឹក ឃើញគាត់សរសេរ ប៉ុន្តែ រឿងអីៗ ខ្ញុំអត់បានដឹងទេ ព្រោះខ្ញុំអត់ចេះអក្សរ ព្រោះបានឃើញគាត់សរសេរ ប៉ុន្តែសរសេរពីរឿងអី ។ ឲ្យតែគាត់សួរអ្នកទោសហើយ គាត់សរសេរហើយ ។

**ស៖** តើឯកសារនោះ វាមានពណ៌ខុសៗគ្នា ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ, ខុសៗគ្នាបង មានខៀវ មានស ។ សៀវភៅធំ សៀវភៅតូចអីចឹងដែរ ។

[១០:១០:៤៨]

**ស៖** ថាតើពណ៌ទាំងអស់នោះ វាមានន័យជាក់លាក់របស់វា ឬក៏យ៉ាងម៉េច?

**ឆ៖** ពណ៌របស់វា ដូចខ្ញុំថា មានបី មានខៀវ, ស, ក្រហម មានធំ មានតូច សៀវភៅហ្នឹង ។

**ស៖** ថាតើពណ៌ក្រហមនោះ វាមានន័យជាក់លាក់ដោយសារតែពណ៌ក្រហមហ្នឹងគេប្រើប្រាស់ឬក៏យ៉ាងម៉េច?

**ឆ៖** ពណ៌ក្រហម គឺៗគេប្រើប្រាស់មិនដឹងអីមិនដឹង ខ្ញុំអត់បានដឹង។ ប៉ុន្តែ វាឃើញខៀវ ឃើញក្រហម សៀវភៅមានធំ មានតូច ។ សៀវភៅសួរចម្លើយ ។

**ស៖** បន្ទាប់ពីលោកចាកចេញពីម-១៣ ថា តើលោកមានឱកាសជួប ឌុច ម្តងទៀតដែរឬទេ? បន្ទាប់ពីលោកចេញពី ម-១៣ ហ្នឹង ថាតើលោកបានឃើញ ឌុច ម្តងទៀតដែរឬទេ បន្ទាប់ពីឆ្នាំ១៩៧៩ តើលោកធ្លាប់បានឮ ឬឃើញ ឌុច ដែរ ឬទៀតទេ?

**ឆ៖** ខ្ញុំចេញពីមន្ទីរគាត់ហើយ អត់បានជួបរហូតទើសសព្វថ្ងៃហ្នឹង ។

**ស៖** ខ្ញុំអស់សំណួរ ដើម្បីសួរសាក្សីទៀតហើយ ។ ថាតើមានចំណុចណាសំខាន់ដែលសាក្សីចង់លើកឡើង និងបញ្ជាក់ប្រាប់យើងនៅពេលនេះដែរឬទេ?

**ឆ៖** បាទ, អត់មានទេបង ។ ខ្ញុំដឹងតែប៉ុណ្ណឹង ។

[១០:១៣:២៣]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែរ៍៖**

ខ្ញុំអត់មានសំណួរទៀតទេ ។ ប៉ុន្តែ ខ្ញុំប្រហែលជាមានសំណួរមួយចំនួនចង់សួរទៅកាន់ជនជាប់ចោទ ។ ដូច្នេះ ឌុច លោកបានស្ដាប់នូវសក្ខីកម្មដែលសាក្សីបានលើកឡើង អំពីព្រឹត្តការណ៍មួយចំនួន និងអង្គហេតុមួយចំនួន ។ អង្គហេតុនិងចម្លើយទាំងអស់នេះវាផ្ទុយអ្វី ដែលលោកបានលើកឡើងពីមុន ។

**ស៖** សូមលោកបញ្ជាក់ ឬក៏ធ្វើការចែករំលែក ឬក៏ប្រាប់ថា វាមានចន្លោះប្រហោងយ៉ាងម៉េចចំពោះសក្ខីកម្មទាំងអស់នេះ?

[១០:១៤:១៨]

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រមជាទីគោរព ! ដំបូងខ្ញុំសូមជម្រាបថា ចាន់ វឿន នេះ១ មិនមែនជាបុគ្គលិករបស់មន្ទីរ-១៣ យើងខ្ញុំទេ ។

ខ្ញុំសូមអនុញ្ញាតលើកភស្តុតាងបញ្ជាក់ជូនដូចតទៅ ។ ចាន់ វឿន បានរាយការណ៍ជូនការិយា-ល័យសហព្រះរាជអាជ្ញា នូវឯកសារលេខ D៧៨/១ ។ គាត់ថ្លែងការណ៍ថា មានម្នាក់ទៀតឈ្មោះ ប៊ុន ជាអ្នកសួរចម្លើយដែរ ប៉ុន្តែ ឌុច បានសម្លាប់គាត់បាត់ទៅហើយប្រហែលនៅក្នុងឆ្នាំ១៩៧៤ ។ សេចក្ដីថ្លែងការណ៍នេះនៅទំព័រទីបីនៃឯកសារ D៧៨/១ ។ ហើយដល់នៅទំព័រទី៥ គាត់បញ្ជាក់ជូនអ្នកសួរចម្លើយជំនួសលោកចៅក្រមស៊ើបអង្កេតថា--

**ស៖** នៅពេលនេះ គឺខ្ញុំមិនឲ្យលោកប្រាប់ខ្ញុំនូវចំណុចផ្ទុយគ្នានៅក្នុងសំណៅឯកសារនេះនោះទេ គឺខ្ញុំសុំឲ្យលោកផ្ដល់ការចាប់អារម្មណ៍របស់លោកចំពោះចន្លោះប្រហោងនៃសក្ខីកម្មរបស់សក្សី ប្រសិនបើយើងចង់ពិស្ដារយើងនឹងចូលទៅដល់ខ្លឹមសារ ។ ប៉ុន្តែ ជាដំបូងគឺថា សាក្សីគឺគាត់បាននិយាយថា គាត់ឃើញលោកផ្ទាល់ដៃ ឃើញលោកខ្លួនឯងហ្នឹង គឺប្រព្រឹត្តអំពើហិង្សាក្នុងពេលសួរចម្លើយ ។ ហើយបន្ទាប់មក គឺសាក្សីបានរៀបរាប់ អំពីព្រឹត្តិការណ៍ដែលលោកប្រើប្រាស់ចន្លុះក្នុងការដុតដោះរបស់ស្ត្រី ។ ហើយគឺមានការដុតដោះនិងមានប្រព្រឹត្តអំពើហិង្សា ថាតើលោកមានការយល់យ៉ាងម៉េចទៅលើចម្លើយ

ដែលបានលើកឡើងទៅលើចម្លើយរបស់សាក្សីទាំងអស់នេះ ?

**ឆ៖** ខ្ញុំបញ្ជាក់ថា ចាន់ វឿន មិនមែនជាបុគ្គលិករបស់មន្ទីរ-១៣ នេះជាមូលហេតុ ។ ចំណែកសក្ខីកម្មរបស់គាត់មានរឿងខ្លះគាត់ភរទាំងស្រុង ។ ឯចំណែករឿងខ្លះគាត់ឮតាមគេ ហើយយកមកប្រឌិតថែម ។ ដូច្នេះ វាមានរឿងខ្លះពិត ដូចជារឿងថា មន្ទីរ-១៣ មានរណ្ដៅបីទុកសម្រាប់ឃុំឃាំងអ្នកទោសហ្នឹងពិត ។ ប៉ុន្តែ ដល់គាត់មិនមែនជាបុគ្គលិករបស់មន្ទីរ-១៣ គាត់ឆ្លើយថា គាត់ចេញទៅទាក់ទងសេដ្ឋកិច្ចយូរៗមកម្ដងឃើញ អំពើឃោរឃៅផ្ទាល់ខ្លួនខ្ញុំយ៉ាងនេះមួយយ៉ាងនោះពីរ ។

ខ្ញុំសូមបញ្ជាក់ថា រឿងដែលខ្ញុំបាញ់ជនរងគ្រោះដែលគេជាប់ទោសនៅហ្នុង ខ្ញុំចាំឈ្មោះអ្នកដែលរងគ្រោះដែលខ្ញុំឱ្យគេបាញ់ ដូចខ្ញុំបានរាយការណ៍ជូនមកហើយ មិនមែនឈ្មោះ សយ ទេ គឺឈ្មោះ យឿ។ ហើយអ្នកដែលបាញ់ គ្រាន់តែខ្ញុំសូមបញ្ជាក់ថា មិនមែន បងចាន់ ទេ គឺមិត្តយើងម្នាក់ផ្សេងទៀត។ នេះជារឿងមួយដែលវាមាននៅក្នុងមន្ទីរ-១៣ ។ ក៏ប៉ុន្តែ បុគ្គលនេះប្រែទៅជាថា ឪពុកមាគាត់ ។ ខ្ញុំមិនជឿថាមានអ្នកណាឈ្មោះ សយ, សឿ សយ អីត្រូវខ្ញុំបាញ់ទេ អត់ទេ ។ ឯចំណែករឿងដុតដោះស្ត្រី សាមីខ្លួនមិនប្រាប់ថាចន្ទុះទេ សាមីខ្លួន ចាន់ វឿន អត់និយាយថាចន្ទុះទេ ។ និយាយថា ខ្ញុំយកក្រណាត់ទៅជ្រលក់ប្រេងកាត់ ហើយយកទៅដុតដោះគេ ។

[១០:១៩:៤០]

រឿងដុតនឹងចន្ទុះខ្ញុំបានរាយការណ៍ជូនលោកចៅក្រមច្បាស់ហើយ ។ យប់នោះយើងខ្ញុំនៅបីបួននាក់គ្នាខ្ញុំ នៅពេលដែលមិត្ត ប៉ុន គាត់ឱ្យមិត្ត មាស រៀនសួរចម្លើយ មិត្ត ផល ។ មិត្តផលគាត់ទ្រាំមិនបាន គាត់ច្រឡោត។ ខ្ញុំនៅហ្នឹង ។ ខ្ញុំឃើញ ។ ហើយរឿងដែលគាត់និយាយថា ខ្ញុំយកស្រីម្នាក់ទៅជ្រមុជទឹក គ្នាបីនាក់ ខ្ញុំនៅតែរក្សាថា ខ្ញុំពិតជាទៅជាមួយមិត្ត ប៉ុន យកស្រីម្នាក់ទៅឱ្យមុជហើយងើប មកឈរហាលខ្យល់រងា ខ្យល់រងាឡើងវិញទាល់តែញាក់មាត់ អាហ្នឹងមែន ។ ត្រង់ដូចគាត់និយាយថា ទៅបីនាក់ជ្រមុជទាល់តែទន់ខ្លួនអីឯណា នោះមិនមែន ។ ឯចំណែកឯរឿងគាត់ថា គាត់ទៅដេញល្ហួស ទាក់ល្ហួសខ្ញុំគ្មានអនុញ្ញាតឱ្យកងការពារណាចេញទៅទាក់ល្ហួសទេ ជារឿងភរទេ ។ ឯចំណែករណ្ដៅកប់សាកសពដែលខ្ញុំកម្ទេចនៅម-១៣ មែន នៅម្ខាងជងស្ទឹង ។ រណ្ដៅខ្ញុំបីធំៗ អានោះពិត ។ ឯចំណែកគាត់ ដើម្បីដោះសារថា គាត់បានឃើញរឿងរ៉ាវនៅម-១៣ ហ្នឹងដែរ គាត់ថា គាត់បានទៅធ្វើសេដ្ឋកិច្ច ។ គ្មានទេ ម-១៣ សូមជម្រាបលោកចៅក្រម អត់ចាត់តាំងអ្នកណាទៅធ្វើសេដ្ឋកិច្ចទេ ។ អង្គរខ្ទះហួប គណៈឃុំអមលាំងគេឱ្យ ទាល់ច្រកមែនទែនខ្ញុំឡើងទៅសុំដល់បង ប៉ាល់ លេខាតំបន់៣២ ឬក៏ខ្ញុំឱ្យបង ម៉ម ណៃ ជិះទៅសុំង

ខាង បងសារុន លេខាតំបន់៣១ ឯណោះ ។ អង្ករស្រូវខ្ញុំសុំមកស៊ី ។ សូមបញ្ជាក់ជូនលោកចៅក្រមថា ឆ្នាំ១៩៧៣ គេមិនទាន់ចាត់តាំងសហករណ៍មែន ក៏ប៉ុន្តែផលស្រូវ ផលអង្ករនៅលើដៃប្រធានភូមិ ប្រធានឃុំកាន់កាប់ ។ មន្ទីរ១៣ គ្មានរឿងណាទៅឲ្យឈ្មោះ ចាន់ វឿន នេះដើរទៅដូរទេ ។ យកក្រណាត់ពីណាយកអង្រឹងពីណាទៅឲ្យ ចាន់ វឿន ដើរដូរអត់មានទេ ភរ ។ រួចខ្ញុំចាត់តាំងសេដ្ឋកិច្ចឯណាឈ្មោះ តាសយ ឯណាខ្ញុំគ្មានស្គាល់ តាសយ ណាទេ ។ បុគ្គលិកមន្ទីរ១៣ គ្មានឈ្មោះ ចាន់ វឿន ហើយក៏គ្មានឈ្មោះ តាសយ ដែរ ។

ដូច្នេះ ដោយសារតែគាត់មិនមែនជាបុគ្គលិកមន្ទីរ១៣ នេះហើយបាន ជាគាត់បង្កើតរឿងប្រឌិតច្រើនណាស់ ។ ឯចំណែករឿងដែលខ្ញុំឲ្យគេបាញ់សម្លាប់មនុស្សម្នាក់ អាហ្នឹងពិតជាមានមែន មិនមែនឈ្មោះ សយ ទេ ឈ្មោះ យឿ ។ ហើយរឿងដែលគាត់និយាយថាប្រជាជននៅ ឃុំអមលាំង អស់ចិតសិប ខ្ញុំគិតថា រឿងប្រជាជននៅឃុំអមលាំង ខ្ញុំក្តុកក្តួលចិត្តទាល់ឥឡូវ ។ ខ្ញុំរំឭកឈ្មោះ នៅពេលបច្ចុប្បន្ននេះ ឃើញបានប្រហែលជាម្ភៃប្ដាយអ្នក ។ ខ្ញុំថាយ៉ាងច្រើនចុះហាសិប ខ្ញុំអត់ជជែកជាមួយគាត់ទេ ។ រួចគាត់បាននិយាយបញ្ជាក់ថានៅរស់ពីរនាក់មែន ។ អាពីរនាក់នោះខាងលើមិនឲ្យ ចោទប្រកាន់ទេ ឪពុកវាគេចាប់ មេឃុំ អឿង គេចាប់ ។ អាពីរនាក់ហ្នឹងឈ្មោះ អាបង អាអូន នោះកូន ភ្លោះ ។ ដល់ក្រោយមកពេលឡានទៅពោធិ៍សាត់ខ្ញុំឲ្យទៅទាំងម្ដាយផង ឲ្យទៅទាំងអាពីរនាក់កូនភ្លោះនោះផង ហើយប្រហែលជាដោយទាំងបង ស៊ន ទៅទៀត ។ នេះជារឿងពិត ។ ដូច្នេះ ក្រឡុកកាផារឿងពិតនិងរឿងមិនពិត ព្រោះគាត់តាមពិតមិនមែនជាបុគ្គលិករបស់មន្ទីរ១៣ ។

[១០:២៣:៣៣]

**ស៖** ដូច្នេះ ប្រសិនបើខ្ញុំយល់ទៅលើសក្ខីកម្មនេះត្រឹមត្រូវនោះ គឺលោកបាននិយាយថា សាក្សីនោះគាត់ បាននិយាយពិតថា គឺគាត់ធ្វើការងារខាងផ្នែកសេដ្ឋកិច្ចនៅម-១៣ ។ ថាតើគាត់ធ្វើការនៅម-១៣ មិនមែននៅក្នុងផ្នែកសេដ្ឋកិច្ច ហើយនៅពេលដែលគាត់ ម-១៣ ថាគាត់អាចឃើញបញ្ហាផ្សេងៗដែរឬទេ? ឬក៏តាមយោងទៅតាមលោកសាក្សីនេះបានប្រឌិតនូវរឿងរ៉ាវទាំងឡាយ?

**ឆ៖** លោកចៅក្រមជាទីគោរព! បុគ្គលនេះមិនមែនជាបុគ្គលិករបស់មន្ទីរ-១៣ទេ ។ ដូច្នេះ គ្មានភារកិច្ច ដែលខ្ញុំចាត់តាំងឲ្យទៅដូរស្រូវ ដូរអង្ករទេ ។ គ្មានសិទ្ធិចូលមន្ទីរ១៣ ទេ គ្មានបានឃើញស្ទីច្បាស់នឹងភ្នែកនៅមន្ទីរ-១៣ ទេ នេះបុគ្គល ចាន់ វឿន នេះ ។

ដូច្នេះរឿងទាំងអស់ដូចខ្ញុំបានជម្រាបលោកចៅក្រមហើយ ជារឿងប្រឌិតទាំងស្រុង ឬក៏ជារឿង

ឮតាមគេហើយយកមកប្រឌិតថែម ឬក៏ជានិយាយពិតខ្លះ ។ ដូចជារណ្តៅបី មួយរណ្តៅមានបីបួនប្រាំនាក់អីអាហ្នឹងមែន ។

សរុបមកវិញ ចាន់ វឿន មិនមែនជាបុគ្គលិកមន្ទីរ១៣ មិនមែនជាបុគ្គលិកសេដ្ឋកិច្ចរបស់មន្ទីរ ១៣ គ្មានបានឃើញអីផ្ទាល់ភ្នែក នៅមន្ទីរ១៣ ទេ ។ ឯចំណែក ឧក្រិដ្ឋកម្មរបស់ខ្ញុំទៅលើប្រជាជននៅអមលាំង ខ្ញុំនៅតែចងចាំឥតភ្លេចទេ ។ នេះជារឿងមួយធ្ងន់ធ្ងរដែរចំពោះសតិអារម្មណ៍របស់ខ្ញុំ ។ ឯចំណែកសក្ខីកម្មស្អីៗឯណា ឯណី ខ្ញុំអត់ទទួលទេ ។

**ស៖** ថាតើសាក្សីស្តាប់ឮអ្វីដែលជនជាប់ចោទបានលើកឡើងដែរឬទេ? ហើយសាក្សីមានយោបល់ចង់ថ្លែង ឬចង់លើកឡើងដែរឬទេ? ឬក៏លោកសាក្សីចង់បញ្ជាក់ និងក៏តម្កល់នូវចម្លើយដែលលោកបានលើកឡើង ឬក៏លោកចង់កែប្រែនូវចម្លើយរបស់លោក?

**សាក្សី KW-31៖**

បាទ ខ្ញុំចង់តដូចគាត់ថា ខ្ញុំមិនមែននៅមន្ទីរ១៣ ហើយក៏មិនមែនជាបុគ្គលិក ហើយមិនមែនគាត់ចាត់តាំងសេដ្ឋកិច្ច ។ ចុះហេតុអីបានគាត់ថាអ៊ីចឹង បើខ្ញុំនៅដើរជាមួយ-- ប៉ុន្តែគាត់ស្តាប់ហើយ តាសយហ្នឹង យកក្រណាត់មិនដឹងយកមកពីណាទេ យកមកឲ្យខ្ញុំដើរដូរស្រូវ ដូរអង្ករឲ្យអ្នកទោសហ្នឹង ជាពិតអ៊ីចឹងតែម្តង ដល់គាត់និយាយថាអត់យ៉ាងម៉េចបើខ្ញុំអ្នកដើរហើយ ។ រួចថា ខ្ញុំមិនមែនបុគ្គលិកកន្លែងគាត់ឯណា មួយឃុំអមលាំងគេស្គាល់ខ្ញុំរហូត ទើបដឹងខ្ញុំអត់មានប៉ះពាល់បងប្អូនណាមួយទេ គេនៅចាំមុខខ្ញុំអ៊ីចឹង ។ រួចហេតុម៉េចបានគាត់ថា ខ្ញុំអត់នៅមន្ទីរ១៣ បើខ្ញុំនៅធ្វើការឲ្យគាត់ហ្នឹង រួចគាត់ប្រកែកថាខ្ញុំអត់យ៉ាងម៉េច? អាហ្នឹង ខ្ញុំសូមឆ្លើយតែប៉ុណ្ណឹង ។

[១០:២៧:០៨]

**ស៖** សាក្សីអាចប្រាប់ដែរឬទេ? ថាសាក្សីបានចាំអ្នកទោសដែលនៅម-១៣ ម្នាក់ ដែលត្រូវបានគេកាត់ដៃជើងបុគ្គលម្នាក់ទៀត? ថាតើសាក្សីចាំទៅលើព្រឹត្តិការណ៍នៃការកាត់ដៃជើងរបស់អ្នកទោសម្នាក់ដែរឬទេ?

**ឆ៖** បាទ, ខ្ញុំអត់បានឃើញ អត់បានដឹង ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំអត់មានសំណួរបន្ថែមទេ ដើម្បីសួរសាក្សីនោះទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានសំណួរអីសួរដល់សាក្សីរូបនេះទេ? បើអត់អង្គជំនុំជម្រះប្រកាស-- សូមអញ្ជើញលោកស្រីចៅក្រម ខាតរាយច៍ ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតរាយច៍៖**

**ស៖** អរគុណលោកប្រធាន ។ សាក្សីបានលើកឡើងថា អ្នកទោសដែលនាំមកម-១៣ គឺមានបុរសស្ត្រី និងកូនក្មេង តើសាក្សីបាននិយាយអ៊ីចឹងដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបាននិយាយមែន ។

**ស៖** ហើយលោកបាននិយាយថាក្មេងៗ ទាំងអស់នោះគឺមានអាយុក្មេងមែនទែន គឺមានអាយុ៣ ទៅ ៤ឆ្នាំ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ ។

**ស៖** នៅពេលដែលលោកនៅម-១៣ ថាតើលោកបានឃើញក្មេងប៉ុន្មាននាក់?

**ឆ៖** ឃើញក្មេងចំនួនតែបីនាក់ទេ កូនក្មេងតូចៗ ។

**ស៖** ថាតើមានអ្វីកើតឡើងទៅលើកូនក្មេងទាំងបីនាក់នោះ?

**ឆ៖** បាទ, កើតឡើង យកម្តាយមក យកទាំងកូនមកទៀត កូនតូច ។

**ស៖** ថាតើមានក្មេងនៅក្នុងចំណោមទាំងបីនោះមានក្មេងណាមួយមកពីអមលាំងដែរឬទេ?

**ឆ៖** សុទ្ធតែនៅអមលាំង ។

**ស៖** លោកដឹងថាក្មេងទាំងអស់នោះទៅភូមិរបស់គេវិញដែរឬទេ?

**ឆ៖** បាទ,អត់ទេ ។ ទាំងម្តាយក៏បាត់ កូនក៏បាត់ ។

**ស៖** ថាលោកឃើញស្ត្រីប៉ុន្មាននាក់ ដែលលោកឃើញនៅមឥ១៣?

**ឆ៖** សុទ្ធតែកូនក្មេងទាំងអស់ ។

**ស៖** គឺអ្នកទោសដែលជា ស្ត្រី ថាតើអ្នកទោសស្ត្រីនោះ គាត់មានកូនទៅជាមួយគាត់ដែរឬទេ?

**ឆ៖** បាទ, ឃើញស្ត្រីនោះមានកូនបី ប៉ុន្តែមិនដឹងកូនបងណាៗខ្ញុំមិនបានដឹងទេ ប៉ុន្តែខ្ញុំឃើញកូនបីនាក់ ដែលចាប់មកទាំងម្តាយទាំងកូន ។

**ស៖** ថាតើមានអ្នកទោសផ្សេងៗទៀតដែលជាស្ត្រី ហើយគាត់មិនមានកូននាំទៅមកជាមួយដែរឬទេ?

**ឆ៖** បាទ,ទេ ។

**ស៖** ដូច្នេះ លោកឃើញស្ត្រីម្នាក់ ហើយស្ត្រីនោះគាត់មានកូនបីនាក់ទៅជាមួយគាត់?

**ឆ៖** ឃើញផ្សេងទេ ឃើញកូនក្មេងបី ប៉ុនមិនដឹងកូនបងណាៗខ្ញុំមិនដឹងទេ ។ ប៉ុន្តែចាប់មកទាំងម្តាយទាំងកូន ទាំងបី។ កូនតូចបី ។

**ស៖** ថាតើស្ត្រីនោះត្រូវបានគេឃុំខ្លួនដូចអ្វីដែលលោកបានលើកឡើងពីមុនដែរឬទេ?

**ឆ៖** បាទ, ម្តាយវាត្រូវ តាឌុច គាត់ឃុំខ្លួន ។ ហ្នឹងហើយមកទាំងកូនតូចមក ចាប់ពីភូមិមកម្តាយមកទាល់យកទាំងកូនតូចមកហើយ ។

**ស៖** ថាតើត្រូវបានគេទុកនៅក្នុងរណ្តៅ ឃុំនៅក្នុងរណ្តៅ ឬក៏ឃុំនៅកន្លែងណាផ្សេង?

**ឆ៖** ទុកខាងក្រៅ ម្តាយនៅខាងក្រៅដែរដើម្បីមើលកូនតូចនោះ ។

**ស៖** អរគុណ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោង ១១ ខ្វះ ១០នាទីសូមអញ្ជើញចូលវិញ។ មន្ត្រីតុលាការជូនសាក្សីរូបនេះទៅបន្ទប់រង់ចាំ ហើយនាំគាត់មកកាន់ទីនេះវិញឲ្យបានមុនម៉ោងកំណត់ ។

*[សវនាការសម្រាកពីម៉ោង ១០:៣៣ នាទី ដល់ម៉ោង ១១:០២ នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត ហើយជាបន្តនេះ សូមប្រគល់វេទិកានេះជូនទៅចៅក្រម ហ្សង់ម៉ាក ដើម្បីបន្តនៃការសាកសួរ ឬក៏ទៅដល់សាក្សីបន្តទៀត ។

សូមអញ្ជើញ លោក ហ្សង់ម៉ាក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ជាការពិត អង្គជំនុំជម្រះ សង្កេតឃើញថា មានចំណុចខុសគ្នានៅក្នុងខ្លឹមសារនៃសក្ខីកម្មរបស់សាក្សី ដែលបានលើកឡើងក្នុងពេលស៊ើបអង្កេត ហើយនិងអ្វីដែលបានលើកឡើងដោយសាក្សី នៅពេល

នេះ ។ ហើយអ្វីដែលយើងធ្វើនៅពេលនេះ គឺយើងនឹងអានចម្លើយរបស់សាក្សី នៅក្នុងដំណាក់កាលស៊ើបអង្កេត ហើយនៅក្នុងកថាខណ្ឌនីមួយៗ គឺយើងនឹងអានវាទៅនឹងសំណួរដែលបានសួរទៅសាក្សី ហើយយើងពិនិត្យទៅមើលចំណុចខុសគ្នា ថាតើយើងអាចដោះស្រាយទៅលើបញ្ហានេះយ៉ាងម៉េច?

ដូច្នេះ ខ្ញុំសូមឲ្យក្រឡាបញ្ជី ធ្វើការអានឯកសារ គឺឯកសារ D៧៨/១ គឺយើងនឹងអានចាប់ពីកន្លែងសំណួរ និងចម្លើយ យើងមិនអានចំណុចមុនហ្នឹងទេ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សួរ-ឆ្លើយ៖

**ង.អ និង ហ្វេស.អិល:** សូមរៀបរាប់ដោយសង្ខេបពីប្រវត្តិរបស់លោកមុនឆ្នាំ១៩៧០ តើលោករៀននៅសាលាណាខ្លះ? ក្រោយឆ្នាំ១៩៧០ តើលោកបានចូលរួមក្នុងកងទ័ពខ្មែរក្រហម ក្នុងអង្គភាពណា? **ច.វ:** កាលពីក្មេង ខ្ញុំរៀនត្រឹមថ្នាក់ទី១២ ។ នៅឆ្នាំ១៩៧០ ខ្ញុំបានចូលធ្វើជាឈ្លប ឃុំអមលាំងដែលមានមេឃុំឈ្មោះ តុប ជាអ្នកនាំចូល ។ ចូលធ្វើកងឈ្លបបានមួយខែក្រោយមក គេបញ្ជូនខ្ញុំទៅកងទ័ពភូមិភាគប្រចាំនៅសមរភូមិ ផ្លូវជាតិលេខ៥ ដែលមានឈ្មោះ វិន ជាកូនប្រសារ តាម៉ុក ជាប្រធានកងពល ។ ក្រោយមកខ្ញុំបានរត់ចេញ ពីជួរកងទ័ពមកនៅផ្ទះ ។ មកនៅផ្ទះបានបីថ្ងៃ ក៏ត្រូវឈ្មោះ សាយ មកពីហាណូយ បានបញ្ជូនខ្ញុំទៅនៅមន្ទីរម-១៣ ។ ខ្ញុំមកធ្វើការនៅម-១៣ ប្រហែលក្នុងឆ្នាំ១៩៧៤ ។

[១១:០៥:១១]

**ង.អ និង ហ្វេស.អិល:** តើតួនាទីរបស់លោកធ្វើអ្វីខ្លះនៅមន្ទីរម-១៣? សូមលោកបញ្ជាក់ពីទីតាំងម-១៣ តើឋិតនៅកន្លែងណា? តើអ្នកណាជាប្រធានម-១៣? **ច.វ:** ខ្ញុំមានតួនាទីជាកងការពារនៅម-១៣ ។ មន្ទីរម-១៣ ឋិតនៅត្រពាំងច្រាប ។ ទីតាំងគុកនេះ មានរណ្តៅបីកន្លែង ក្នុងរណ្តៅនីមួយៗមានជម្រៅ២ម៉ែត្រ ទំហំ៤ម៉ែត្រ បួនជ្រុង ។ រណ្តៅនីមួយៗ ឋិតនៅឆ្ងាយពីគ្នាប្រហែលកន្លះម៉ែត្រ ។ នៅអមសងខាងរណ្តៅទាំងបីនេះ មានរោងពីរ ដែលឋិតនៅខាងឆ្វេង និងខាងស្តាំរណ្តៅ សម្រាប់ដាក់អ្នកទោសស្រាលៗ ចំណែកឯនៅក្នុងរណ្តៅ គឺសម្រាប់ដាក់អ្នកទោសធ្ងន់ៗ ។ ក្នុងរណ្តៅនីមួយៗ មានដាក់អ្នកទោសពី ៥ ទៅ ៦ នាក់ តែប៉ុណ្ណោះ ។ ចំពោះនៅរោងធំ នៅខាងកើត មានអ្នកទោសប្រហែល ១០ នាក់ ចំណែក រោងតូច នៅខាងលិច មានអ្នកទោសប្រហែល ៦ ទៅ ៧ នាក់ ។ ឯនៅជុំវិញកន្លែងឃុំឃាំងមានធ្វើរបងឫស្សីព័ទ្ធជុំវិញ ។ នៅខាងក្រៅគុកមានរោងសម្រាប់អ្នកយាមស្នាក់នៅ ។ អ្នកយាមគុកខាងក្នុងមានគ្នាពីរនាក់ ។ បុគ្គលិកធ្វើការនៅម-១៣ ទាំងអស់មានប្រហែល១៣ នាក់ ក្នុងនោះមាន

អ្នកដាំស្ល អ្នកការពារ អ្នកសួរចម្លើយ និងមានពេទ្យពីរនាក់ ដែលជាអ្នកទោសស្រាល ។ មន្ទីរម-១៣នេះ មាន ឌុច ជាប្រធាន ឈ្មោះ ចាន់ ជាអនុប្រធាន និង ឈ្មោះ មាស ជាសមាជិក ។ អ្នកទាំងបីអ្នកនេះ សុទ្ធតែជាអ្នកសួរចម្លើយ ។ មានម្នាក់ទៀត ឈ្មោះ ប៉ុន ជាអ្នកសួរចម្លើយដែរ ប៉ុន្ដែ ឌុច បានសម្លាប់គាត់បាត់ទៅហើយ ប្រហែលក្នុងឆ្នាំ១៩៧៤ ។ ចំណែក អ្នកការពារមានភារកិច្ចនាំអ្នកទោសស្រាលៗ ទៅធ្វើការនៅខាងក្រៅ ហើយការងារនោះ គឺកាប់ដី និងដាំបន្លែ ។ ចំណែកឯអ្នកទោសធ្ងន់ មិនបានបញ្ចេញមកធ្វើការនៅខាងក្រៅទេ ។ អ្នកការពារម្នាក់ទទួលភារកិច្ចនាំអ្នកទោសបីនាក់ ទៅធ្វើការជាប្រចាំរៀងរាល់ថ្ងៃ ។ អ្នកដាំបាយ គឺជាប្រពន្ធរបស់ តាចាន់ ដែលមានឈ្មោះ មុំ ។

**ង.អ និង ហ្វេស.អិល៖** តើអ្នកទោសទាំងនោះត្រូវគេចោទពីបទអ្វី? ហើយមានអ្នកទោសប្រភេទណាខ្លះ?

[១១:០៨:០៩]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** ចាតើសាក្សីអាចបញ្ជាក់នូវចម្លើយ ដែលបានអានអម្បាញ់មិញដែរឬទេ? ឬក៏មានចំណុចណាមួយ ដែលបានអានអម្បាញ់មិញនេះ មិនឆ្លើយតបទៅនឹងចម្លើយរបស់លោក ដែលបានឆ្លើយនៅក្នុងថ្ងៃនេះ?

**សាក្សី KW-31៖**

**ឆ៖** ចម្លើយអំមិញ គឺការពិតណាស់ ។ ចម្លើយហ្នឹង គឺថាពិតអ៊ីចឹងមែនហើយ ច្បាស់លាស់ហើយ ។

**ស៖** ចម្លើយនេះនិយាយថា នៅពេលមួយនោះមានអ្នកសួរចម្លើយម្នាក់ឈ្មោះ ប៉ុន ដែលត្រូវបានសម្លាប់ដោយ ឌុច នៅក្នុងឆ្នាំ១៩៧៤ ។ ចាតើលោកបានឃើញការសម្លាប់ ប៉ុន ដោយ ឌុច នេះដែរឬទេ? គឺលោកបានឃើញដោយខ្លួនឯងដែរឬទេ ចាលោកច្បាស់ហើយថា គឺជា ប៉ុន ឬក៏លោកចង់បញ្ជាក់បន្ថែមទៅលើបញ្ហានេះជូនតុលាការ?

[១១:០៩:៣៨]

**ឆ៖** ត្រង់ហ្នឹង ព្រោះ ប៉ុន ហ្នឹង ពីដើមទៅធ្វើការជាមួយ តាឌុច ហ្នឹង ជនសួរចម្លើយដែរ ប៉ុន្ដែបាត់គាត់បាត់អស់រយៈពេលនេះហ្នឹង អត់ឃើញគាត់នៅក្នុងមន្ទីរហ្នឹងទៀត ។ ដឹងជាទៅខាងណា ព្រោះចាកន្លែងនោះតែបាត់ហើយ មានតែបាត់ខ្លួនទេបាទ អត់មានទៅណាទេ ព្រោះអ្នកកងការពារដែរ ។

ក្រែងអត់បានដឹង ដឹងខុសពីរឿងអីមិនដឹង ប៉ុន្តែ ប៉ុន មុនអ្នកស្ទួរចម្លើយដែរ ដឹងគាត់ស្លាប់ ដឹងគាត់រស់ បើវារស់ឃើញហើយ ។

**ស៖** ថាលោកបានឃើញ ឌុច បាញ់ ហើយនិងសម្លាប់ ប៉ុន នេះដែរឬទេ?

**ឆ៖** បាទ, អត់បានឃើញទេ ប៉ុន្តែគ្រាន់ថាបាត់ បាត់អ្នកស្ទួរចម្លើយហ្នឹង ។

**ស៖** ដូច្នេះ គឺចំណុចទាំងឡាយដែលនិយាយនេះ គឺការសន្និដ្ឋានរបស់លោកគឺមិនមែនអ្វីដែលលោកបានឃើញដោយខ្លួនឯងនោះទេ?

**ឆ៖** ការពិតអត់បានឃើញទេ ។ ប៉ុន្តែ គ្រាន់ថា គ្រាន់ការសង្ស័យ សង្ស័យថា បាត់ឈ្មោះ ប៉ុន ហ្នឹង មិនដឹងបាត់ទៅកន្លែងណា ព្រោះធ្លាប់ឃើញគាត់ក្នុងមន្ទីរកងការពារអ្នកជនស្ទួរចម្លើយមួយដែរ ។

**ស៖** ដូច្នេះ យើងបន្តការអាននេះបន្តទៀត ។ ប៉ុន្តែ វាជាការល្អ ដែលយើងត្រូវតែឈប់ក្នុងមួយវាក្យខណ្ឌម្តងៗ ។

[១១:១២:00]

**លោកស្រី សែ កុលវុឌ្ឍី៖**

ង.អ និង ហ្វេស.អិល: តើអ្នកទោសទាំងនោះត្រូវគេចោទប្រកាន់ពីបទអ្វី? ហើយមានអ្នកទោសប្រភេទណាខ្លះ? ច.វ: អ្នកទោសទាំងនោះ មានប្រុស មានស្រី អ្នកខ្លះមានកូនតូចមកជាមួយផង ។ ខ្ញុំមិនដឹងថា គេមានកំហុសអ្វីទេ ខ្ញុំឃើញអ្នកជាប់នៅទីនោះ មានតែប្រជាជនធម្មតា ដែលរស់នៅតាមភូមិនានា នៅក្នុងឃុំអមលាំងនេះ ។ ខ្ញុំមិនដែលឃើញមានទាហាន លន់ នល់ ជាប់នៅទីនោះទេ ។

ង.អ និងហ្វេស.អិល: សូមលោកបញ្ជាក់អំពីស្ថានភាពអ្នកទោសដែលជាប់នៅទីនោះមានលក្ខណ: យ៉ាងណាខ្លះ? ច.វ: អ្នកទោសធ្ងន់ ដែលដាក់នៅក្នុងរណ្តៅ ត្រូវគេដាក់ខ្នោះជើងទាំងយប់ទាំងថ្ងៃ ។ ចំណែកអ្នកទោសស្រាលពុំមានដាក់ខ្នោះទេ ។

ង.អ និង ហ្វេស.អិល: តើលោកបានដឹងអំពីអ្នកទោសត្រូវស្លាប់ ដោយសារទឹកជំនន់លិចរណ្តៅដែរឬទេ? ច.វ: ខ្ញុំបានដឹងពេលនោះ ។ ខ្ញុំបានរស់នៅទីនោះដែរ ពេលទឹកលិចនោះ គឺជារដូវវស្សា មានទឹកជំនន់ឡើងយ៉ាងខ្លាំងភ្លាមៗ នៅពេលដែលកំពុងភ្លៀងធ្លាក់ខ្លាំងកណ្តាលយប់ ដែលបណ្តាលឲ្យអ្នកទោសក្នុងរណ្តៅស្លាប់ទាំងអស់ ។ ចំណែក កងការពារ និងអ្នកធ្វើការនៅម-១៣ ទាំងអស់នាំគ្នារត់ឡើងដើមឈើដែលនៅក្បែរនោះ ។ ទឹកជំនន់នោះ លិចក្នុងរយ:ពេលមួយយប់ពីរថ្ងៃទើបស្រកវិញ ។

ង.អ និង ហ្វេស.អិល: តើពេលនោះ ឌុច មានបញ្ជាឲ្យជួយសង្គ្រោះអ្នកទោសដែរឬទេ? ច.វ:

ពេលនោះពុំមានបញ្ហាទេ ក្រោយពេលទឹកស្រករួចទើប ឌុច បញ្ជាឲ្យទៅមើលអ្នកទោស ដែលបានស្លាប់ដោយសារទឹកជំនន់ ។

[១១:១៣:៤៩]

ង.អ និង ហ្វេស.អិល៖ ចំពោះអ្នកទោសស្រាលៗ ពេលទឹកជំនន់នោះ តើមានគេរត់-- តើមានរត់គេចខ្លួនដែរឬទេ? ច.វ៖ អ្នកទោសស្រាលៗ ក៏រត់ឡើងដើមឈើដែរ ពុំអាចរត់គេចខ្លួនទេ ។

ង.អ និង ហ្វេស.អិល: សូមលោកបញ្ជាក់អំពីការសួរចម្លើយអ្នកទោស តើគេនាំយកអ្នកទោសទៅសួរចម្លើយនៅកន្លែងណា? អ្នកណាមានសិទ្ធិសួរចម្លើយអ្នកទោសខ្លះ? តើ ឌុច ធ្លាប់សួរចម្លើយអ្នកទោសខ្លួនឯងដែរឬទេ? ច.វ៖ ការសួរចម្លើយ គឺសួរនៅក្នុងរបងគុកនោះតែម្តង ។ ឌុច ជាអ្នកចេញបញ្ជាឲ្យអ្នកការពារនាំអ្នកទោសនោះមកឲ្យអ្នកសួរចម្លើយ ។ ទោះបី តា ចាន់, តា មាស សួរចម្លើយក៏ដោយលុះត្រាតែ ឌុច អនុញ្ញាតឲ្យសួរ ទើបសួរបាន ។ ពេលសួរចម្លើយ បើអ្នកទោសមិនឆ្លើយ ឌុច គាត់ធ្វើទារុណកម្មលើអ្នកទោសដោយខ្លួនឯង ។ ចំណែក ចាន់ និង មាស ពុំមានសិទ្ធិធ្វើទារុណកម្មអ្នកទោសទេ ទោះបីអ្នកទោសមិនឆ្លើយក៏ដោយ ។ ពេលសួរចម្លើយអ្នកទោស ឌុច គាត់សួរចម្លើយផង និងកត់ត្រាចម្លើយទុកក្នុងសៀវភៅផង ។ ក្រោយពីសួរចម្លើយ គាត់តែងតែយកសៀវភៅកត់ត្រាទាំងនោះមកពិនិត្យឡើងវិញ ។ ចំពោះ តាចាន់ ឬតាមាស ពេលសួរចម្លើយរួចហើយ បើអ្នកទោសមិនឆ្លើយ គាត់ទៅរាយការណ៍ឲ្យ ឌុច ។ ក្រោយមក ឌុច បានមកសួរផ្ទាល់ខ្លួនឯង និងធ្វើទារុណកម្មផង ។ ខ្ញុំមិនដែលឃើញមាននីរសារមកទទួលយកសៀវភៅចម្លើយសារភាពអ្នកទោសពី ឌុច ទេ ។

**ប្រធានអង្គជំនុំ៖**

បានៗ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** កថាខណ្ឌមួយចំនួនបានអានជូនលោក ។ ជាបឋម តើលោកបញ្ជាក់ចម្លើយពីមុនរបស់លោកដែលថា មានការជន់ទឹក ហើយនិងមានការស្លាប់ ដូចដែលលោកបានរៀបរាប់នៅក្នុងនោះ ដែរឬទេ?

**សាក្សី KW-31៖**

**ឆ៖** បាទ, ពេលនោះមាន ពេលទឹកជន់មាន មិនមែនថាអត់ទេ ក្នុងគុកមានស្លាប់ ។ អត់នរណាយកទាន់ទេបង ទឹកនោះលឿនជាទីបំផុតហើយ ។ ជាការពិត ។

**ស៖** លោកបញ្ជាក់ដែរឬទេថា ឌុច មិនបានបញ្ជាថា ឲ្យដោះលែងអ្នកទោសនៅក្នុងរណ្តៅ ឬក៏ដោះលែងពួកគេឲ្យចេញពីរណ្តៅ?

**ឆ៖** គាត់អត់មានបទបញ្ជាអីទេ ព្រោះស្លន់ស្លោ រកតែកន្លែងរត់ដែរហ្នឹង រត់ទឹក ។ អត់បានបញ្ជា បទបញ្ជាឲ្យលែងអ្នកទោសអីទាន់ ។ មកឆឹបភ្លាមទឹក លិចតែម្តង ។

**ស៖** នៅក្នុងកថាខណ្ឌបន្តបន្ទាប់មកទៀត លោកបាននិយាយថា របៀបនៃការសួរចម្លើយ ត្រូវបានប្រព្រឹត្តឡើង ។ លោកបានលើកឡើងថា អំពើទារុណកម្ម គឺមិនអាចអនុវត្តឡើងដោយ មិនមានបញ្ជាពី ឌុច នោះទេ ។ តើលោកបញ្ជាក់ចំណុចហ្នឹងដែរឬទេ?

**ឆ៖** បាទ, មុននឹងសួរចម្លើយទាល់តែអាចបញ្ជាពីតាឌុច បានយកអ្នកទោសហ្នឹង មកឲ្យសួរចម្លើយបាន ។ ទាល់អនុញ្ញាតពី តាឌុច ហ្នឹង ។ អត់នរណាហ៊ានចេះធ្វើផ្តេសផ្តាសបានទេ ទាល់តែអនុញ្ញាតពីគាត់ ។

[១១:១៨:៣០]

**ស៖** ហើយបន្ទាប់មកទៀត លោកនិយាយថា ឌុច គឺគាត់តាមដាន ហើយនិងគាត់សួរចម្លើយដោយខ្លួនឯងដោយប្រើទារុណកម្ម ។ ហើយនៅក្នុងការយល់ឃើញរបស់លោកថា តើវាមានន័យថាដូចនេះគឺគាត់ចូលរួមនៅក្នុងការសួរចម្លើយតាមលក្ខណៈប្រព័ន្ធ ហើយគាត់ប្រើប្រាស់ ទារុណកម្មតាមលក្ខណៈជាប្រព័ន្ធ តើមែនដែរឬទេ?

**ឆ៖** តាមការពិត គាត់សួរខ្លួនគាត់ផ្ទាល់ហ្នឹង។ ដោយដូចខ្ញុំជម្រាបពីខាងលើអ៊ីចឹងថា រហូតដល់វាយដំទៀតឯណោះ រហូតដល់ស្រោតខោស្រោតអាវទៀតឯណោះ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមឲ្យអានកថាខណ្ឌបន្ទាប់ទៀត ។

**ប្រធានអង្គជំនុំ៖**

អានមួយកថាខណ្ឌ ឈប់មួយកថាខណ្ឌម្តង ឈប់សិនទៅ ដើម្បីឲ្យមានការផ្ទៀងផ្ទាត់សិនណ៎ា ដោយចៅក្រមឡាវែន ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ង.អ និង ហ្វេស.អិល៖ ក្នុងរយៈពេលសួរចម្លើយអ្នកទោស តើ ឌុច បានធ្វើទារុណកម្មតាមរបៀបណាខ្លះ?

ច.វ៖ មានតែ ឌុច ម្នាក់គត់ដែលមានសិទ្ធិធ្វើទារុណកម្មលើអ្នកទោស ។ គាត់ធ្វើទារុណកម្មដោយផ្ទាល់តែម្នាក់ឯង ដូចជា យកក្រណាត់ជ្រលក់នឹងប្រេងកាតរុំនឹងឈើ រួចដុតអ្នកទោស ដែលចងដៃទៅក្រោយ ព្យួរឡើងលើនឹងមែកឈើ ហើយយោលចុះយោលឡើង ។ ពេលខ្លះ ឌុច បានវាយអ្នកទោសនឹងរំពាត់ឫស្សី ដែលមានរបួសឈាមពេញខ្លួន ។ អ្នកទោសខ្លះទៀតត្រូវ ឌុច យកទៅជ្រមុជទឹកនឹងដងស្ទឹង ដែលនៅជាប់នឹងកន្លែងគុកនោះ បណ្តាលឲ្យអ្នកទោសសន្លប់ ។ ហើយអ្នកការពារបានសែងយកទៅដាក់ក្នុងគុកវិញ ។ ចំពោះអ្នកទោសស្រី ឌុច បានយកភ្លើងទៅដុតចំដោះបណ្តាលឲ្យរលាក ។ អ្នកទោសដែលត្រូវធ្វើទារុណកម្ម ឌុច បានឲ្យស្រាតខោអាវចេញទាំងអស់ នៅតែខ្លួនទទេ ទើបយកទៅធ្វើទារុណកម្ម ។ ចំពោះអ្នកទោសដែលសួរមិនឆ្លើយ ពេលខ្លះ ឌុច បានយកកាំភ្លើងបាញ់សម្លាប់តែម្តងដែលខ្ញុំបានឃើញផ្ទាល់ មានបាញ់អ្នកទោសចំនួន៣នាក់ ។ ទីមួយ ឌុច បាញ់អ្នកទោសដែលចងនៅក្រោមដើមឈើ ចំនួន៣គ្រាប់ដោយកាំភ្លើងខ្លី ។ ទីពីរ បាញ់ដោយកាំភ្លើងអាកា និងទីបី បាញ់ដោយកាំភ្លើងខ្លីដែរ ។ ពេលធ្វើទារុណកម្មអ្នកទោសម្តងៗពេលខ្លះ ឌុច ហាក់ដូចជាសើចសប្បាយរីករាយដូចឆ្កួតនឹងការធ្វើទារុណកម្មនេះ ។

[១១:២២:០៥]

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែរ៍៖**

**ស៖** ខ្ញុំជឿថា គឺឃ្លាពីរ-បីឃ្លាចុងក្រោយ គឺអត់មានអាន ដូច្នេះខ្ញុំសូមអាន ។

ទីមួយ គឺព្យួរៗពីដើមឈើ ហើយ ឌុច បានបាញ់សម្លាប់ ហើយទីពីរ មានការបាញ់ដោយកាំភ្លើងអាកា ហើយទីបី គឺបាញ់ដោយកាំភ្លើងខ្លី ។ នៅពេល ឌុច ធ្វើទារុណកម្មអ្នកទោសម្តងពេលខ្លះ ឌុច ហាក់ដូចជាសើចសប្បាយរីករាយ ដូចឆ្កួតនឹងការធ្វើទារុណកម្មនេះ ។

ថាតើប្រយោគនេះ គឺមាននៅក្នុងឯកសារភាសាខ្មែរដែរឬទេ? ប្រសិនបើមានមែននោះ តើសាក្សីអាចប្រាប់យើងទេថា លោកបញ្ជាក់ថាឃ្លាទាំងអស់ត្រូវបានអាន ហើយលោកមានអ្វីទៀតដែរឬទេចង់បញ្ជាក់ទៅលើឃ្លា ដែលបានអាននៅចុងក្រោយអម្បាញ់មិញនេះ ។

**សាក្សី KW-31៖**

**ឆ៖** បាទ, អត់មានអីទេបង គឺថាដឹងតែប៉ុណ្ណឹង ឃើញតែប៉ុណ្ណឹង ។ រឿងបាញ់កាំភ្លើងខ្លី ខ្ញុំភ្លេចលើកត្រង់នេះ អត់បាននឹកឃើញបាទ ។ បាញ់នោះៗ ឃើញជាក់ស្តែង បាញ់នៅក្រៅគុក ម្នាក់ហ្នឹងខ្ញុំភ្លេចត្រង់ហ្នឹង ។ ឥឡូវ ខ្ញុំសូមលើកមួយគោលការណ៍ហ្នឹងទៀតចុះ ខ្ញុំឃើញជាក់ស្តែង ។ គាត់បាញ់

កាំភ្លើង មិនដឹងកាំភ្លើងអី អាកាំភ្លើងហ្នឹងវិល មានបាញ់ទៅវិល វិលក្នុងហ្នឹងបាទ បាញ់បីគ្រាប់អ្នកទោសហ្នឹងត្រូវស្លាប់ដែរ ។ ខ្ញុំបានបញ្ជាក់ត្រង់ហ្នឹង ទើបបង្ហើបដល់កន្លែងនេះ ខ្ញុំបាននឹកឃើញ ។ ពិតជាការពិតបាទ ក្រៅពីហ្នឹងខ្ញុំអត់បានដឹងទៀតទេ ព្រោះខ្ញុំចេញពីកន្លែងគាត់បាត់ទៅហើយ ខ្ញុំចប់ត្រឹមហ្នឹងចុះ ។

**ស៖** អ្វីដែលលោកប្រាប់យើងថ្ងៃនេះ គឺលោកមិនត្រឹមតែឃើញការសម្លាប់តែម្តងនោះទេ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវហើយ ឃើញគាត់បន្តរហូត ។

**ស៖** នៅក្នុងចម្លើយដែលបានអានអម្បាញ់មិញ ការសម្លាប់បែបត្រូវបានអាន ហើយពីរបែបទៀត គឺលោកបានឮចំពោះការសម្លាប់ពីរបែបនោះ ឬក៏លោកមិនបានចាំ ទៅលើកការសម្លាប់ពីររបៀបនោះ?

**ឆ៖** ខ្ញុំស្តាប់អត់បានទេលោកមានប្រសាសន៍អំមិញ ។

[១១:២៥:២២]

**ស៖** នៅក្នុងចម្លើយរបស់លោក ដែលលោកបាននិយាយប្រាប់ចៅក្រមស៊ើបអង្កេត ហើយបានអានអម្បាញ់មិញនេះ គឺមានការលើកឡើងអំពីការសម្លាប់បីយ៉ាង ។ ទីមួយ គឺ ឌុច បានបាញ់បីគ្រាប់ ហើយលោកក៏បាននិយាយអំពីការសម្លាប់ផ្សេងៗទៀតដែរ ។ ហើយគឺមានការលើកឡើង គឺថាការបាញ់ទីពីរ គឺបាញ់ដោយអាកា ហើយការបាញ់ទីបី គឺបាញ់ដោយកាំភ្លើងខ្លី ។ ដូច្នេះ សំណួរ របស់ខ្ញុំនោះគឺថា លោកចាំការសម្លាប់បែបនេះមកដល់ថ្ងៃនេះដែរឬទេ? ឬក៏លោកអត់ចាំទេ ចំពោះការសម្លាប់នោះ ហើយនេះគឺជាព្រឹត្តការណ៍ ដែលលោកបាននិយាយទៅលើបញ្ហាហ្នឹង ឬក៏ព្រឹត្តការណ៍ដែលលោកមិនបានចាំទៅលើចំណុចទាំងអស់នេះ?

**ឆ៖** បាទ, គឺបានចាំ ព្រោះអំមិញខ្ញុំភ្លេចអាចំណុចហ្នឹង ។ បានចាំថា លើកទីបីនេះ គឺបាញ់ដោយកាំភ្លើងខ្លីហ្នឹង គឺការពិត ពិតឃើញគាត់បាញ់អ៊ីចឹងមែន ធ្វើសកម្មភាពហ្នឹងបាញ់បីគ្រាប់ ។

**ស៖** អ្វីដែលលោកបាននិយាយអម្បាញ់មិញនេះ គឺលោកបានឃើញ ឌុច សម្លាប់មនុស្សបីនាក់ ដោយប្រើកាំភ្លើងខ្លី និងកាំភ្លើងអាកា ។ ថាតើការសម្លាប់នេះគឺវានៅខុសៗថ្ងៃគ្នា ឬក៏សម្លាប់នៅថ្ងៃតែមួយ?

**ឆ៖** បាទ, ខុសថ្ងៃបង ។ សម្លាប់ ជួនកាលជិតមួយខែឯណោះ បានសម្លាប់មួយទៀត អត់មានជួនគ្នាមួយថ្ងៃហ្នឹងបីទេបាទ បន្តបន្ទាប់គ្នាយូរ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ដូច្នេះ ការអានសូមអានបន្តទៀតឥឡូវនេះ ។

[១១:២៨:០២]

**លោកស្រី សែ កុលវុឌ្ឍី៖**

ង.អ និង ហ្វេស.អិល៖ តើលោកមានដែលឃើញ គេយកសត្វក្អែបឱ្យខាំអ្នកទោស ពេលធ្វើទារុណកម្មដែរឬទេ? ច.វ៖ ពុំដែលឃើញទេ ។

ង.អ និង ហ្វេស.អិល៖ តើអ្នកទោសសុទ្ធតែទទួលទារុណកម្មទាំងអស់ដែរឬទេ? ច.វ៖ អ្នកទោសភាគច្រើន គឺសុទ្ធតែទទួលទារុណកម្មទាំងអស់ ។ មានអ្នកទោសតិចតួចទេ ដែលមិនបានទទួលទារុណកម្ម ជាពិសេស អ្នកទោសស្រាលៗ ។

ង.អ និង ហ្វេស.អិល៖ តើមានអ្នកទោសនៅទីនោះ មានដែលត្រូវបានដោះលែងដែរឬទេ? ច.វ៖ អ្នកទោសខ្លះក្រោយពីបានសួរចម្លើយរួចហើយ ក៏ត្រូវបានគេដោះលែងដែរចំពោះអ្នកទោសស្រាលៗ ។

ង.អ និងហ្វេស.អិល៖ តើមានអ្នកទោសត្រូវបានគេយកទៅសម្លាប់ដែរឬទេ ក្រោយពីសួរចម្លើយរួចហើយ? ច.វ៖ ខ្ញុំមិនបានដឹងទេ ការយកទៅសម្លាប់នោះ ប៉ុន្តែមានបាត់អ្នកទោសខ្លះនៅពេលយប់មិនដឹង គេយកទៅសម្លាប់នៅទីណាទេ ។ ប៉ុន្តែ អ្នកទោសខ្លះ ដែលសួរចម្លើយមិនចេញ ត្រូវបាន ឌុច បញ្ជាឱ្យបង្អត់បាយទឹកពេលក្រោយមកក៏ត្រូវស្លាប់នៅក្នុងគុកតែម្តង ។ ខ្ញុំបានឃើញហេតុការណ៍នេះ មានអ្នកស្លាប់ក្នុងគុកចំនួនពីរនាក់ ។

**សួរដោយចៅក្រម ហ្សង់ម៉ាកឡាវែន៍៖**

**ស៖** សាក្សី, តើលោកអាចបញ្ជាក់ទេថា លោកយល់ព្រមជាមួយនឹងចម្លើយ ដែលបានអានអម្បាញ់មិញនេះ?

**សាក្សី KW-31៖**

**ឆ៖** យល់ព្រម ។

**ស៖** ដូច្នេះ លោកខ្លួនឯងបានឃើញអ្នកទោសស្លាប់ ដោយការអត់បាយ ហើយការស្លាប់ដោយអត់បាយនេះ កើតចេញពីការបញ្ជារបស់ ឌុច ដើម្បីបង្អត់បាយអ្នកទោសទាំងអស់នោះ ។ តើមែនដែរឬទេ?

**ឆ៖** កាលហ្នឹងខ្ញុំបានឃើញអារឿងអត់បាយហ្នឹង ។ បើស្លាប់ដោយការកាប់សម្លាប់ ឬមួយគាត់នាំអ្នកណាឃើញតែម្តង ។

**ស៖** ដូច្នេះលោកខ្លួនឯងមិនបានឃើញ ឌុច ចេញបញ្ជាថាឲ្យបង្អត់បាយអ្នកទោស ។ លោកបានឃើញ ឬក៏បានឮ ឬក៏បានទទួលការប្រាប់ពីអ្នកណាម្នាក់ពីបញ្ជាហ្នឹងដែរឬទេ?

**ឆ៖** ដូចខ្ញុំជម្រាបអ៊ីចឹងថាអត់បានឃើញទេ ត្រង់ហ្នឹង ។ អត់បានដឹង បានឮផងរឿងអត់បាយអត់អីហ្នឹង វាអស់ឃើញមានស្លាប់ទេ ។ ស្លាប់ដូចជាជម្រាបខាងលើថា ការកាប់សម្លាប់ ឬមួយក៏គាត់មួយរយៈមកទៀតក៏ខ្ញុំមិនដឹងដែរ ។

**ចៅក្រម ហ្សង់ម៉ាកឡាវ៉ែន៖**

ដូច្នេះ ខ្ញុំគិតថា យើងអាចបន្តអានទៅលើចម្លើយនេះបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

លោកបានបញ្ជាក់ថា ឌុច បានសម្លាប់ ប៊ុន ។ តើមូលហេតុអ្វី? តើសម្លាប់តាមរបៀបណា? ច.វ៖ ខ្ញុំបានឃើញ ឌុច បាញ់សម្លាប់ ប៊ុន ដោយកាំភ្លើងអាកា ដោយមូលហេតុឈ្មោះ ប៊ុន បានធ្វើឲ្យអ្នកទោសរត់រួចពេលយកទៅសួរចម្លើយ ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវ៉ែន៖**

**ស៖** ថាតើលោកជម្រាបយើងយ៉ាងម៉េច? ថាតើចំណុចនេះវាត្រូវនឹងបញ្ហាការពិតដែរឬទេ ឬក៏វាជាចំណុចដែលលោកសន្និដ្ឋានតែប៉ុណ្ណោះ ចំពោះបញ្ហានេះ? លោកបានឃើញដោយផ្ទាល់ ឬក៏ជាចំណុចដែលលោកធ្វើការសន្និដ្ឋាន ហើយវាកើតចេញពីបទពិសោធន៍របស់លោកតែប៉ុណ្ណោះ?

**សាក្សី KW-31៖**

**ឆ៖** ដូចខ្ញុំជម្រាបខាងដើមហើយថា ប៊ុន ខ្ញុំមិនបានឃើញគាត់បាញ់ទេ ។ គ្រាន់ថា បាត់ឈ្មោះព្រោះគាត់ជាអ្នកសួរចម្លើយអ្នកទោសដែរ ដល់សួរយូរៗបាត់គាត់ហ្នឹងទៅ ហើយខ្ញុំសន្និដ្ឋានមកគាត់សម្លាប់ហើយ ព្រោះបាត់ អ្នកទោស-- កងការពារដល់បាត់ហើយ សុទ្ធតែមានរឿងហើយ ។ រឿង ប៊ុន ហ្នឹង ។

**ចៅក្រម ហ្សង់ម៉ាកឡាវ៉ែន៖**

ខ្ញុំគិតថា យើងអាចបន្តអានឯកសារនេះបន្តទៀត ។

**លោកស្រី សែ កុលវុឌ្ឍី៖**

ចំពោះការដោះលែងអ្នកទោស តើអ្នកណាបញ្ជាឲ្យដោះលែង? ច.វ៖ អ្នកដែលត្រូវបានដោះលែងគឺមានតែ ឌុច ទេមានសិទ្ធិបញ្ជា ។

សូមលោកបញ្ជាក់ពីរបបហូបចុករបស់អ្នកទោសនៅក្នុង ម-១៣ តើមានលក្ខណៈដូចម្ដេចដែរ? ច.វ៖ របបរបស់អ្នកទោសក្នុងម-១៣ មានពីរពេលក្នុងមួយថ្ងៃ គឺពេលព្រឹក និងពេលល្ងាច ។ មួយពេលៗមានតែបបររាវ ដែលគេដួសដាក់ក្នុងបំពង់ទឹកត្នោតជំនួសចាន និងប្រើសំបកគ្រំចងភ្ជាប់នឹងឫស្សីប្រើប្រាស់សម្រាប់ជំនួសស្លាបព្រា ។

តើលោកនៅធ្វើការនៅម-១៣ ហ្នឹងរហូតដល់ឆ្នាំណា? ច.វ៖ នៅចុងឆ្នាំ១៩៧៤ ខ្ញុំបានដោះលែងអ្នកទោស៣នាក់ ដែលខ្ញុំបានស្គាល់រស់នៅក្នុងភូមិសំរោង ក្រោយមកខ្ញុំត្រូវមានទោសវិញ ដោយដាក់ច្រវាក់កខ្ញុំចងភ្ជាប់នឹងដើមឈើ ។ ចងបានបីថ្ងៃខ្ញុំក៏លួចរត់ចេញរួច ពេលមកដល់ភូមិកំណើតក៏បានប្រធានភូមិជួយធានា ទើប ឌុច ឲ្យខ្ញុំរួចខ្លួនតាំងពីពេលនោះមក ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

**ស៖** ដូច្នេះ តើលោកបញ្ជាក់ទៅនឹងចម្លើយដែលអានអម្បាញ់មិញនេះដែរឬទេ?

**សាក្សី KW-31៖**

**ឆ៖** បាទ គឺបាន។ ពិត ។

**ស៖** ដូច្នេះ អាចបន្តអានរហូតដល់ចប់តែម្ដង ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមលោកបញ្ជាក់អំពីអាកប្បកិរិយារបស់ ឌុច នៅពេលនោះ ។ តើគាត់ជាមនុស្សប្រភេទណា? ច.វ៖ ឌុច ជាមនុស្សកាចសាហាវឃោឃៅណាស់ បើ ឌុច ចង់ឲ្យស្លាប់គឺត្រូវតែស្លាប់ ។ ការងារនៅម-១៣ នេះ គឺក្រោមអំណាច ឌុច ទាំងអស់ ។ អ្នកនៅក្រោមឱវាទរបស់ ឌុច ខ្លាច ឌុច ដូចខ្លា មិនប៉ានសម្លឹងមុខទេ បើ ឌុច និយាយសើចៗត្រូវប្រុងប្រយ័ត្នឲ្យហើយ បើនិយាយមុខស្លូតមិនអីទេ ។

តើលោកមានអ្វីចង់បន្ថែមទៀតទេ? ច.វ៖ មិនមាននោះទេ ។

[១១:៣៦:៤៦]

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៖**

**ស៖** ដូច្នេះ លោកបញ្ជាក់យល់ព្រមនឹងអ្វីដែលបានអានអម្បាញ់មិញនេះដែរឬទេ?

**សាក្សី KW-31៖**

ខ្ញុំបាទយល់ព្រម ។

**ស៖** ហើយ ឌុច មានការចង់លើកឡើងទៅលើចម្លើយដែលទើបតែអានដែរឬទេ? ជាថ្មីម្ដងទៀត គឺមិនពាក់ព័ន្ធទៅនឹង-- មិនត្រឹមតែពាក់ព័ន្ធនឹងចម្លើយនេះទេ គឺវាសូមឲ្យលោកបញ្ជាក់នឹងផ្ដល់យោបល់ចំពោះភាពខុសគ្នា ចំពោះចម្លើយនេះផងដែរ ។

**ជនជាប់ចោទ៖**

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្តិច លោកចៅក្រមចង់ឲ្យខ្ញុំអធិប្បាយអំពីភាពមិនចុះសម្រុងគ្នា ។ ភាពមិនចុះសម្រុងគ្នារវាងស្អីខ្លះ?

**ស៖** ថាតើចម្លើយដែលផ្ដល់ដោយសាក្សីនេះ គឺលោកយល់ព្រមនិងពេញចិត្តដែរឬទេ? ឬក៏លោកមានបញ្ហាចោទទៅនឹងចម្លើយទាំងអស់ដែលសាក្សីបានលើកឡើង?

**ឆ៖** បញ្ហាសំខាន់ដែលខ្ញុំចង់ជម្រាបអង្គជំនុំជម្រះទាំងមូល គឺ ចាន់ វឿន មិនមែនជាបុគ្គលិករបស់មន្ទីរ១៣របស់ខ្ញុំទេ ។ ហើយភស្តុតាងដែលខ្ញុំលើកឡើង ខ្ញុំនៅរក្សាដដែល គឺគាត់បានភរថា ខ្ញុំបានបាញ់មិត្ត ប៊ុន ។ មិត្ត ប៊ុន ជាមនុស្សជំនិតរបស់ខ្ញុំបំផុត នេះខ្ញុំលើក ឡើងគ្រាន់ តែជាភស្តុតាងសម្រាប់បញ្ជាក់ថាគាត់មិនមែនជាបុគ្គលិករបស់មន្ទីរ១៣ ។ ឯចំណែក រឿងដែលគាត់ភរបន្តបន្ទាប់ថែមទៀតថាខ្ញុំមានទៅបាញ់ពេលណា ថាខ្ញុំមានបាញ់អ្នកទោសបីនាក់ដោយដៃខ្លួនឯងទៀត ។ នេះគឺមិនត្រូវទេ ។ ឯចំណែករឿងកុមារដែលគាត់ចេះតែ និយាយរាយការណ៍ជូនលោកចៅក្រម ហើយនិងរាយការណ៍ជូនអង្គប្រជុំ ខ្ញុំសូមបញ្ជាក់ថា គ្មានកុមារណារបស់អ្នកភូមិអមលាំងមកនៅនោះទេ ។

សូមបញ្ជាក់ជូនលោកចៅក្រមថា ពីរនាក់ដែលខ្ញុំដោះលែងនោះ ដែលគេហៅថា អាបងអាប្អូននោះគឺជាកូនភ្លោះរបស់មេឃុំ អឿង ។ ប្រពន្ធមេឃុំ អឿង ក៏ចាប់ កូនគាត់ចាប់មកបីនាក់ ។ មេឃុំ អឿង ក៏ចាប់ ។ ខ្ញុំបានទទួលបញ្ជាពីលើមកឲ្យធ្វើទារុណកម្មសួរចម្លើយមេឃុំ អឿង ហើយនិងអាបងបង្អស់ ។ ឯចំណែក ពីរនាក់ កូនគាត់ភ្លោះនោះ អាយុប្រហែល១៥ឆ្នាំ ហើយម្ដាយវាគឺប្រពន្ធមេឃុំ អឿង ក៏អត់ឲ្យសួរចម្លើយដែរ ។ ដល់ក្រោយមក ខាងលើបញ្ជាឲ្យខ្ញុំៗបញ្ជូនទាំងកូនពីរនាក់ ហើយនិងម្ដាយទៅជាមួយគ្នាទៅពោធិ៍សាត់ ។

ដូច្នេះសរុបមកគ្មានក្មេងណានៅទីនោះទេ ។ គ្មានក្មេងៗណាម្នាក់ ដែលហៅថាក្មេង គឺក្មេងចេញ

ពីឃុំអមលាំង ដូចឈ្មោះ វឿន នេះបានប្រកាស ។ ឯចំណែក ខ្ញុំមានសាកល្បងចិញ្ចឹងកុមារ៣នាក់លមើលដែរ តែចិញ្ចឹងមិនរស់ អានេះជារឿងផ្សេង មិនមែនអ្នកអមលាំងទេ ។

ឯចំណែករឿងទឹកលិចវិញ សូមបញ្ជាក់ការពិតដូចតទៅ ។ ទឹកជន់ស្រុកភ្នំ ខ្ញុំបានបញ្ជាក់ជូនអង្គសវនាការពីមុនហើយ។ ថ្ងៃនោះភ្លៀងនៅកន្លែងនោះតិចទេ ប្រហែលជាម៉ោង៩ព្រឹក ។ ភ្លៀងតិចទេ មិនច្រើននៅនុ៎ង តែស្រាប់តែទឹកមកពីលើវឹបៗ មួយម៉ោងឡើងប្រហែលមួយម៉ែត្រ ។ លោកចៅក្រមគិតមើលមួយម៉ោងឡើងមួយម៉ែត្រ ។ ខ្ញុំឃើញអ៊ីចឹង ខ្ញុំទៅឈរនៅមាត់រណ្តៅ អាទឹកហៀរចូលរណ្តៅខ្ញុំថា ចេញៗ ទាំងខ្ញុំទាំងគេទៅឈរបន្តោងធ្នឹមផ្ទះ ធ្នឹមរោង ទឹកលិចត្រឹមនេះ ទាំងអស់គ្នា ទាំងអ្នកទោសទាំងខ្ញុំ ខ្ញុំនៅហ្នឹង ។ ល្ងាចប្រហែលជាម៉ោង៣ទើបទឹកស្រក ពេលហ្នឹងបានខ្ញុំជម្លៀសអ្នកទោស ហើយនិងកងការពារខ្ញុំទៅលើទួល ផ្ទះបង ជោត ប្រធានភូមិត្រពាំងគ្រោក ។

ដូច្នេះ គ្មានអ្នកទោសណាម្នាក់ស្លាប់នៅទីនោះ ដោយសារទឹកជំនន់ដូចដែលខ្ញុំបានរាយការណ៍ជូនអង្គសវនាការពីមុនអ៊ីចឹង ។ គ្មានអ្នកណាម្នាក់ឡើងដើមឈើទេ ហើយនៅសល់ទួលមួយនៅផ្ទះបង ជោតហ្នឹងតែម្តង ប្រធានភូមិ ។ ហើយពេលនុ៎ងឆ្លងទៅផ្ទះបង ជោត មិនបានទេ ព្រោះទំពាំងច្រាបហ្នឹងវាទំនាបជាងអាកន្លែងគុក ។ ដូច្នេះ មនុស្សមិនឃើញស្អីពិតប្រាកដ ហើយមកនិយាយ វាអត់ត្រូវទេ ។

ឯចំណែកខ្ញុំទៅសុំកងការពារពីតាសាយ មកពីហាណូយឯណាហ្នឹងគ្មានទេ ខ្ញុំមិនដែលទៅសុំកងការពារពីតាសាយអាយុម្ភៃប្លាយមកធ្វើកងការពារខ្ញុំទេ ។ ខ្ញុំទៅរើសពីភូមិឃុំយកអាយុ១៥ ដល់ ១៧ ។

សរុបមក ខ្ញុំបដិសេធតែសក្ខីកម្មអីដែលភូតភរ ។ ខ្ញុំបដិសេធតែសក្ខីកម្មអីដែលសាក្សីឈ្មោះចាន់ វឿន នេះភូតភរទេ ។ ឯចំណែកឧក្រិដ្ឋកម្មរបស់មន្ទីរ១៣ទាំងមូល ឧក្រិដ្ឋកម្មទាំងមូលដែលខ្ញុំប្រព្រឹត្តទៅលើជាតិ ប្រជាជនខ្ញុំ ខ្ញុំទទួល នៅមន្ទីរ១៣ហ្នឹង ខ្ញុំទទួល ។ ខ្ញុំអត់គេចពីស្មារតីទទួលខុសត្រូវហ្នឹងទេ ។ ប្រជាជនអមលាំង ខ្ញុំស្រង់ឈ្មោះបណ្តើរៗហើយ ។ នឹកដល់រឿងប្រជាជនអមលាំង ខ្ញុំចុកចាប់ណាស់ ។ សូមបញ្ចប់ប៉ុណ្ណេះ ។

**ស៖** ខ្ញុំមានសំណួរមួយ ថាតើប៉ុន អាចរត់ចេញពីម-១៣ ដែរឬទេ? ឧទាហរណ៍ ថាគាត់អាចរត់ទៅម-១៣ ខ ដែរឬទេ? ឬក៏គាត់នៅ ម-១៣ គ្រប់ពេលទាំងអស់?

**ឆ៖** លោកចៅក្រមជាទីគោរព! មិត្តប៉ុន នេះ ជាមនុស្សមកពីខេត្តជាមួយនឹងខ្ញុំ ចេញពីកុដិលេខ ៣ វត្តឧណ្ណាឡោមជាមួយនឹងខ្ញុំ ។ ខ្ញុំបណ្តុះបណ្តាល ខ្ញុំឲ្យនៅចាំជាប់នៅហ្នឹងកន្លែងហ្នឹង បណ្តុះបណ្តាលខាងសួរចម្លើយហ្នឹងតាំងពីដើមរហូតមក ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំអត់មានសំណួរបន្ថែមទៀតទេ ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាមានសំណួរអ្វីចង់សួរដល់សាក្សីរូបនេះទៀតដែរឬទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក យ៉េត ចរិយា៖**

អរគុណលោកប្រធាន។

**ស៖** ចាន់ វឿន តាមការអះអាងរបស់លោក លោកបានបញ្ជាក់ថាលោកជាបុគ្គលិកម-១៣ ។ តើពេលដែលលោកជាបុគ្គលិកម-១៣ ហ្នឹង លោកមានស្គាល់នរណា ខ្លះដែលជាបុគ្គលិកនៅទីនោះទេ?

[១១:៤៨:៥២]

**សាក្សី KW-31៖**

**ឆ៖** បាទ, សូមឆ្លើយ ។ បុគ្គលិកកងការពារ ស្គាល់ខ្លះ មិនស្គាល់ខ្លះ ព្រោះវានៅឆ្ងាយពីគ្នា ។

**ស៖** ស្គាល់តើមានអ្នកនៅរស់ទេសព្វថ្ងៃហ្នឹង?

**ឆ៖** មាន ។

**ស៖** ឈ្មោះអី?

**ឆ៖** មួយឈ្មោះ ខន ។

**ស៖** ចាន់ ខន?

**ឆ៖** បាទ ។

**ស៖** ស្អីទៀត?

**ឆ៖** ពីរទៀត ឡុញ ។ មិនដឹងស្អីឡុញទេ នៅខាងកំពង់គោក ។ ហើយមួយទៀត នៅប៉ុស្តិ៍ជឿន ថ្នល់បំបែក អាហ្នឹងកងការពារ ។ រួចមួយទៀត វ៉ាន់ ។ ខ្ញុំស្គាល់តែប៉ុណ្ណឹងទេ ក្រៅពីហ្នឹង គេអ្នកកងការពារឆ្ងាយៗ ខ្ញុំអត់បានស្គាល់ទេ ។

**ស៖** អ្នកទោស ដែលពេលលោកជាបុគ្គលិក ម-១៣ មានស្គាល់អ្នកទោសឈ្មោះអីខ្លះ?

**ឆ៖** អ្នកទោសនោះ ស្គាល់ក៏មិនអស់ដែរបង ។ ខ្ញុំស្គាល់តែក្នុងឃុំខ្ញុំហ្នឹងទេ ដូចដែលឆ្ងាយៗ ខ្ញុំអត់ស្គាល់ទេ ។

**ស៖** អ្នកស្គាល់ឈ្មោះអីខ្លះ?
**ឆ៖** អ្នកស្គាល់មានតាសយ មួយ ។ ពួខ្ញុំហ្នឹង រួច លី យើង។ លី ចាមហ្នឹង ។ រួច ងង ខេង ។ ច្រើនដែរបង ប៉ុន្តែ ខ្ញុំមិនអាចរៀបរាប់អស់បានទេ ។
**ស៖** ស្គាល់ហាម អ៊ុនទេ?
**ឆ៖** ស្គាល់ ។
**ស៖** ហាម អ៊ុន ប្រាកដជាស្គាល់?
**ឆ៖** អ៊ុន ហ្នឹងពួកម៉ាកខ្ញុំបាទ ។
**ស៖** គាត់រស់ ឬស្លាប់ឥឡូវនេះ?
**ឆ៖** ស្លាប់ហើយ ។
**ស៖** សូមលោកបញ្ជាក់ម្តងទៀតមើល៍ អ្នកដឹកនាំនៅ ម-១៣ ក្រៅពីឌុច តើមានអ្នកណាទៀតទេ?
[១១:៥០:៣៤]
**ឆ៖** មានតែប៉ុន ហើយនឹង មាស, ចាន់ ហ្នឹងហើយ ក្រៅពីគាត់មក ។
**ស៖** ស្គាល់ឈ្មោះ ផល ទេ?
**ឆ៖** ផល ស្គាល់ ។ ស្គាល់ទាំងមុខទៀត ។
**ស៖** ផល និងប៉ុន តើចាំច្បាស់ទេ ថាអ្នកណាមួយឈ្មោះ ផល ? អ្នកណាមួយឈ្មោះ ប៉ុន?
**ឆ៖** មួយឈ្មោះផល មួយឈ្មោះប៉ុន ។ ស្គាល់ ។
**ស៖** រួច ផល ទៅណាទៅ ផល?
**ឆ៖** ផល ហើយនឹង ប៉ុន ហ្នឹងបាត់ខ្លួនបាត់ ។ ព្រោះគាត់នៅក្នុងមន្ទីរ តាឌុចហ្នឹង អាចគាត់អ្នកសួរចម្លើយអ្នកទោសដែរ ។ អ៊ីចឹងបានជាខ្ញុំថា អត់ឃើញផល ហើយ ប៉ុន ហ្នឹង មិនដឹងជា គាត់ជម្លៀសទៅខាងណា ឬមួយយក៏គាត់យកទៅខាងណា ខ្ញុំមិនបានដឹងដែរ ។
**ស៖** អ៊ីចឹងសូមបញ្ជាក់ឲ្យច្បាស់ក្នុងចំណោមមនុស្សពីរនាក់ហ្នឹង គឺផល និងប៉ុន ។
**ឆ៖** បាទ ។
**ស៖** បាត់ខ្លួនទាំងពីរ?
**ឆ៖** បាត់ទាំងពីរ ។

**ស៖** អត់ដឹងថាបាត់ពីមូលហេតុអីទេ?

**ឆ៖** អត់ដឹងមូលហេតុអី ។ ដឹងគាត់យកទៅខាងណា អីខាងណាទេ ។ គាត់បាត់ខ្លួនតែម្តង អត់ឃើញក្នុងមន្ទីរហ្នឹងទេ ។

**ស៖** ផល មានតួនាទីជាស្មៀនៅ ម-១៣?

**ឆ៖** ផល មាននាទីសួរចម្លើយអ្នកទោសដែរ ។

**ស៖** អរគុណ ។ ដែលឃើញចាន់ និងមាស បាញ់អ្នកទោសទេ?

**ឆ៖** បាទអត់ ។

**ស៖** អត់ដែលឃើញទេ?

**ឆ៖** បាទ ។

**លោកយ៉េត ចរិយា៖**

អស់សំណួរតុលាការ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញសហព្រះរាជអាជ្ញា ។

**សួរដោយលោក អាឡិចសាន់ឌឺ ប៊ើត៖**

[១១:៥២:០៥]

**ស៖** អរគុណលោកប្រធាន ។ ថាតើលោកទទួលបានការបណ្តុះបណ្តាលណាមួយដែរឬទេមុនពេលដែលលោកធ្វើការនៅម-១៣?

**សាក្សី KW-31៖**

**ឆ៖** បាទ, ខ្ញុំអត់មានបាននាទីអីទេបង ត្រឹមម៉ាកងការពារ មិនដែលឃ្លាតចេញទេ ។ ការងារទៅ ដូចយកអ្នកទោសទៅណោះ ទៅណោះអីសម្លាប់អីអត់មានទេបង ។ គ្រាន់តែបាននាទីកងការពារនៅក្នុងមន្ទីរគាត់ហ្នឹងទេ ។

**ស៖** មុនពេលដែលលោកទទួលបញ្ជាឲ្យយាមអ្នកទោស ថាតើលោកទទួលបានការណែនាំ ណាមួយដែរឬទេ? ឧទាហរណ៍ ថាតើឌុច ឬក៏បុគ្គលដទៃណាមួយបាននិយាយជាមួយលោកៗ ថាតើលោកធ្វើយ៉ាងម៉េចនៅពេលដែលអ្នកទោសព្យាយាមរត់?

**ឆ៖** អ្នកទោសមុនយកទៅធ្វើការខាងក្រៅទាល់អនុញ្ញាតពីតាឌុច បានបាន ។ អត់ចេះតែយកៗ

បានទេ ទាល់អនុញ្ញាត ។ គាត់ថា ឥឡូវយកបី ឬប្អូននាក់ទៅធ្វើការ អាចកងការពារយកទៅបាន ។ អត់ចេះតែនាំយកបានទេ ទាល់អនុញ្ញាតពីគាត់ទៅ ។

**ស៖** សំណួរទីពីររបស់ខ្ញុំគឺថា ថាតើ ឌុច ឬក៏ណាដទៃណាមួយ ប្រាប់លោក ថាតើលោកធ្វើយ៉ាងម៉េច ប្រតិកម្មយ៉ាងម៉េច ប្រសិនបើអ្នកទោសគាត់ព្យាយាមរត់?

**ឆ៖** បើអ្នកទោសរត់ គាត់អាចបញ្ជា ដូចថារត់រួចមុខណា ឲ្យបាញ់ អត់ឲ្យរួចទេ ។ ដូចថាមុខសញ្ញាខ្ញុំយកទៅធ្វើការអ៊ីចឹង ឬមួយមុខសញ្ញាផ្សេងៗទៀត កាលណាអ្នកទោសរត់ហើយ គឺគាត់បញ្ជាឲ្យបាញ់ហើយ ។ គាត់ដាក់បញ្ជា ។ កាលណាអ្នកទោសរួច អ្នកកងការពារត្រូវតែជាប់គុកដែរ ។ ដូចរូបខ្ញុំអ៊ីចឹង ដូចអ្នកទោសអ៊ីចឹងដែរ អ៊ីចឹងខ្លួនឯងជាប់គុកតែម្តង ។ អាហ្នឹងត្រូវ បើថានេះ អាចគាត់បញ្ជាឲ្យបាញ់ បាញ់ទៅ ។ រួចបើមុខមាត់គាត់ឆ្ងាយទៅ ដូចខ្ញុំហ្នឹងដោះលែង កុហកថាអ្នកទោសកាត់ច្រវាក់រត់អីអ៊ីចឹងទៅ។

[១១:៥៥:០៥]

**ស៖** លោកបានប្រាប់យើងថា អ្នកទោសត្រូវបានគេសួរចម្លើយ ។ ថាតើអ្នកទោសទាំងអស់ត្រូវបានគេសួរចម្លើយ តើលោកបានដឹងដែរឬទេ? មានទាំងអស់ ឬក៏តែមួយចំនួនទេ ដែលត្រូវបានគេសួរចម្លើយ?

**ឆ៖** អ្នកទោសថា ឲ្យតែគេចាប់ពីក្រៅមកដល់កន្លែងគាត់ហើយ យូរនិងឆាប់សួរទាំងអស់ហ្នឹង រឿងធ្ងន់រឿងស្រាលខ្ញុំមិនបានដឹងដែរ ប៉ុន្តែសួរៗទាំងអស់ ។ ត្រូវសួរមូលហេតុ រឿងនេះ រឿងនោះ វៃសួរចម្លើយអ៊ីចឹងតែម្តង ។

**ស៖** លោកបានប្រាប់យើងថា ឌុច ធ្វើការសួរចម្លើយ ។ តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាតើលោកខ្លួនឯងឃើញឌុចហ្នឹងសួរចម្លើយប៉ុន្មានដងដែរ?

**ឆ៖** ឃើញបីប្អូនដង ដូចខ្ញុំមានប្រសាសន៍ខាងមុនអ៊ីចឹង ។ ថាឃើញចាប់ព្យួរអ្នកទោសហ្នឹងវៃសួរចម្លើយទៅ ។ ក្រោយមកក៏បាន-- ក្រោយមកបានសួរចម្លើយដូច ថាបាញ់អ៊ីចឹងទៅ ។ សួរមិនចេញបាញ់ងាប់អ៊ីចឹងទៅ ។

**ស៖** ខ្ញុំចង់សួរលោកអំពីព្រឹត្តិការណ៍ពីរដាច់ដោយឡែកពីគ្នា ។ ទីមួយ នៅពេលលោករៀបរាប់ថា ឌុច បានដុតដោះរបស់ស្ត្រី ថាតើលោកដឹងទេ តើលោក ឌុច ហ្នឹងដឹងថា លោកកំពុងតែមើលគាត់ដែរឬទេ?

**ឆ៖** បាទ, មើល ។ ខ្ញុំក៏បានមើលគាត់ដែរ ។ ខ្ញុំមកពីងូតទឹកមក ឃើញចងនារីហ្នឹង ដោះអាវអស់រលីងនៅតែដោះហ្នឹង ដុត ។ អារឿងភ្លើងចន្លុះដូចគាត់ថាអី ខ្ញុំមិនដឹងដែរ គ្រាន់តែឃើញដុត ។ ខ្ញុំមើលពីចម្ងាយទៅ ខ្ញុំមិនសូវហ៊ានជិតគាត់ដែរ ព្រោះខ្ញុំខ្លាចគាត់ ។ ឃើញដុតធ្វើទារុណកម្មនារីហ្នឹងពិតប្រាកដតែម្តង ។ ដុតនៅនឹងរោងបាយខាងក្រោយងហ្នឹង ខាងកើតស្ទឹង ខាងកើតរបងគុក មិនមែនខាងកើតស្ទឹងទេ សូមទោស ។ ជាប់របងគុកដែរ គ្រាន់តែខាងកើត ។ ចងព្យួរហើយដុត ដុតភ្លើងតែម្តង ។ ខ្ញុំមើលពីចម្ងាយដែរ តែគ្រាន់តែឃើញរម្ងូរឫស្សី ហ្នឹងដុត ។ មិនដឹងគាត់ដុតជ័រទឹកមិនដឹង ឬដុតប្រេងកាតមិន ខ្ញុំអត់បានដឹងដែរ ។ ប៉ុន្តែ ឃើញដុតៗតែម្តង ។

[១១:៥៨:០៩]

**ស៖** ថាតើលោកលួចមើល ហើយលោកដឹងថា ឌុច ហ្នឹងអាចមើលឃើញលោកកំពុងតែ លួចមើលដែរ ឬទេ? នេះជាសំណួរដែលខ្ញុំចង់សួរ ។

**ឆ៖** ឌុចឃើញខ្ញុំ ព្រោះខ្ញុំនៅជិតនុ៎ង ហើយខ្ញុំតចុងតុគាត់អ៊ីចឹងហើយ និយាយគាត់មិនឃើញខ្ញុំម៉េច? គាត់មើលខ្ញុំ ។

**ស៖** ថាតើ ឌុច បាននិយាយអីខ្លះដែរឬទេ ពេលដែលគាត់ដុតនុ៎ង?

**ឆ៖** គាត់អត់បាននិយាយអីជាមួយខ្ញុំទេ ។ និយាយតែជាមួយអ្នកទោសនុ៎ងទេ ។

**ស៖** ថាតើគាត់បាននិយាយអីខ្លះជាមួយអ្នកទោសមួយនោះ?

**ឆ៖** និយាយៗ សួរចម្លើយហ្នឹងបាទ ។ សួរចម្លើយតែអ្នកទោសនោះទេ រឿងជាមួយខ្ញុំគាត់អត់មាននិយាយអីទេ ។ ខ្ញុំបានតែឈរមើលពីចម្ងាយ ។ គាត់វ៉ៃធ្វើបាបនារីនោះសួរចម្លើយទៅ និយាយជាមួយអ្នកទោសនុ៎ងទេ ។

**ស៖** ថាតើលោកមើលព្រឹត្តិការណ៍ដុតនោះរយៈពេលប៉ុន្មានដែរ? ថាមួយនាទី ឬក៏យូរជាងហ្នឹង?

**ឆ៖** បាទឃើញដុតនោះយូរដែរហើយ ជាប់ជិត១៥នាទីជាងឯណោះ មកដុតខាងមុខហ្នឹង។

[១២:០០:១០]

**ស៖** ថាតើនៅចុងក្រោយ មានអ្វីកើតឡើងចំពោះអ្នកទោសហ្នឹង គឺគាត់នៅរស់ ឬក៏គាត់ស្លាប់ ហើយគាត់មានស្ថានភាពយ៉ាងម៉េច នៅពេលដែលលោកឈប់មើលគាត់ដែលទទួលរងការដុតហ្នឹង?

**ឆ៖** ក្រៅពីហ្នឹង គាត់ស្រាយលែងមកចូលក្នុងគុកវិញ ដាក់ក្នុងគុកវិញ ។

**ស៖** អរគុណ ។ ព្រឹត្តិការណ៍ទីពីរដែលខ្ញុំចង់លើកឡើងចំពោះលោកសាក្សី ។ លោកបានប្រាប់

យើងថាលោកបានឃើញ ឌុច គឺសម្លាប់ពូរបស់លោក ហើយគឺខ្ញុំគិតថាចំណុចនេះគឺវាមានការអាប់អួរចំពោះលោកក្នុងការលើកឡើង ។ ខ្ញុំអាចសួរលោកជាបឋមបានដែរឬទេថា ឌុច នោះបានដឹងថា លោកកំពុងតែមើលទៅលើព្រឹត្តិការណ៍នុំងដែរឬទេ? ថាលោកលួចមើល ឬក៏យ៉ាងម៉េច?

**ឆ៖** ស្តាប់អត់បានទេ ត្រង់ហ្នឹង លួចមើលស្អី?

**ស៖** ខ្ញុំសូមអភ័យទោស ខ្ញុំនឹងសួរឲ្យបានយឺតៗ ។ ព្រឹត្តិការណ៍ដែលលោកបានរៀបរាប់ ដែលថា ឌុច បានបាញ់សម្លាប់ពូរបស់លោក ថាតើលោកឈរមើលទៅលើការបាញ់សម្លាប់នោះដោយលួចលាក់ ហើយ ឌុច បានដឹងថា លោកពូកំពុងមើលទៅលើព្រឹត្តិការណ៍បាញ់សម្លាប់ហ្នឹងដែរឬទេ?

**ឆ៖** កាលបាញ់ពូខ្ញុំ ខ្ញុំនៅជិតហ្នឹង ព្រោះគាត់អត់ដឹងថាខ្ញុំនៅជិតហ្នឹងទេ ព្រោះខ្ញុំនៅពីខាងដូចពូខ្ញុំគាត់បាញ់អ៊ីចឹង ខ្ញុំនៅពីខាងកើត បាំងតែដំបូកមួយ។ ខ្ញុំមកពីលុបមុខស្ទឹងមក ខ្ញុំឮសូរផ្ទូង! ដល់ផ្ទូង! ខ្ញុំស្មានតែអ្នកទោសហ្នឹងចាប់កាំភ្លើង។ ផ្ទូង! មួយទៀតទៅបានឃើញពូខ្ញុំចងជាប់បង្គោល ដួលដល់ដីហើយ ។ ខ្ញុំក៏គេចអត់ឲ្យគាត់ឃើញទេ គេចដើរមកតាមរបងគុក ក្រៅគុកមកលើអ៊ីចេះវិញមក ។ ខ្ញុំស្រក់ទឹកភ្នែក ឃើញបាញ់មាស្លាប់ហើយ ហើយខ្ញុំអត់ហ៊ានមាត់អីដែរ ។ ពិតប្រាកដបាញ់មាខ្ញុំមែន តាសយ ហ្នឹង រួចគាត់ថាមិនមែនឈ្មោះ តាសយ ឯណា ។ តាសយ គុយគី គាត់នៅធ្វើយាយជីវត្តកន្សែងសំរាល់ថ្ងៃនេះ ចាំសួរទៅ នៅរស់ទាល់រាល់តែថ្ងៃហ្នឹង ប្រពន្ធតាសយ ហ្នឹង មីងខ្ញុំហ្នឹង ។ ព្រោះគាត់និយាយទៅថាអត់មានឈ្មោះ តាសយ ។ តាសយ អមលាំង តាសយ គុយគី នេះ ឥឡូវគាត់អត់ប្តីគាត់ទៅ គាត់បួសធ្វើយាយជី នៅវត្តកន្សែងសំ រាល់ថ្ងៃហ្នឹង នៅវត្តកន្សែងសំ អមលាំងហ្នឹង ។

**ស៖** លោកបានរៀបរាប់ថាមានថ្ងៃមួយនោះ លោកបានឃើញរណ្តៅ ហើយនិងឆ្អឹងដែលត្រូវបានកប់នៅក្នុងនុំងថាតើ លោកអាចប្រាប់ដែរឬទេ ថាតើលោកឃើញឆ្អឹង ឬក៏សាកសពទាំងអស់នោះប៉ុន្មាន?

**ឆ៖** បាទដូចខ្ញុំជម្រាបពីខាងដើមអ៊ីចឹង ។ តាឌុច ហ្នឹង រួចគាត់ថាមិនដេញល្ហូស! មិនអនុញ្ញាតពីគាត់ទេ ប៉ុន្តែ ខ្ញុំលួចនាំអ្នកទោសហ្នឹងយកទៅដេញល្ហូស ស្របក់ហ្នឹងមានជុង ជុងល្ហូសយើងហ្នឹង ។ ដល់ខ្ញុំនាំទៅជិតដល់អាកន្លែងចុះស្ទឹង គាត់ក៏បានឲ្យកងការពារថា អាណានាំអ្នកទោសដើរទៅខាងនុំង? អាមួយថា សារឿន ។ មើល៍ហៅវាមកនេះមក អត់មានយកអ្នកទោសទៅខាងនុំងទេ ។ ខ្ញុំបាទក៏ត្រឡប់មកវិញដែរ ។ ត្រឡប់មកវិញគាត់ស្តីបន្ទោសខ្ញុំថា ឈប់នាំអ្នកទោសដើរទៅខាងនុំងណា ។ រួចខ្ញុំក៏អត់មានចាប់អារម្មណ៍ថាអ៊ីចឹងដែរ ដល់គាត់--

**ស៖** គឺខ្ញុំហាក់ដូចជាចាប់ចម្លើយរបស់លោកអត់ទាន់ ប្រហែលជាមានចន្លោះប្រហោងយ៉ាងម៉េចចំពោះការឆ្លើយរបស់លោក ថាតើលោកចាំទេ ថាលោកបានឃើញសាកសពប៉ុន្មាន? ឬក៏លោកបានឃើញ ហើយលោកអត់ចាំចំនួនសាកសពនោះ ?

**ឆ៖** អត់ឮផង ។ អត់ឮ ។

**ប្រធានអង្គជំនុំ៖**

សហព្រះរាជអាជ្ញាសួរម្តងទៀត សួរសំណួរចុងក្រោយអម្បាញ់មិញ សួរម្តងទៀត អត់ច្បាស់ព្រោះគាត់អំមិញស្តាប់អត់បានណ៎ា ។

**សួរដោយលោក អាឡិចសាន់ឌឺ បេ៊ត៖**

អរគុណ លោកប្រធាន ។

លោកបានរៀបរាប់ថា មានពេលមួយនោះ ដែលលោកបានដើរប្រទះឃើញសាកសព ហើយនិងរណ្តៅនោះ ហើយខ្ញុំគិតថា លោកបានប្រាប់យើងខ្ញុំ លោកមិនសមនឹងដើរទៅទីនោះទេ ហើយគឺមិនមែនដែលលោកនឹងត្រូវដើរកន្លែងនោះទេ ។ ហើយសំណួររបស់ខ្ញុំដែលចង់សួរនោះថា៖

**ស៖** នៅពេលដែលលោកឃើញរណ្តៅដែលមានសាកសពនៅក្នុងនុ៎ង ថាតើលោកចាំ មានចំនួនសាកសពហ្នឹងប៉ុន្មាន ដែលមាននៅក្នុងរណ្តៅ ហើយមានទំហំប៉ុន្មានចំពោះរណ្តៅទាំងអស់នោះ?

**ឆ៖** នៅពេលនោះរណ្តៅមានបួន សាកសពខ្ញុំមិនដឹងដែរ ។ គ្រាន់តែក្នុងរណ្តៅមួយៗសាកសពខ្លះកន្លះ ខ្លះពេញ ក្នុងរណ្តៅហ្នឹង ។ វាមិនបានដឹងចំនួនអ្នកស្លាប់ប៉ុន្មានក្នុងមួយរណ្តៅប៉ុន្មាននាក់ៗ ខ្ញុំអត់បានដឹងទេ ព្រោះឃើញរណ្តៅបួនហ្នឹង អាខ្លះពេញ អាខ្លះកន្លះ បាទនៅក្នុងរណ្តៅហ្នឹង។ អត់មានលុបទេ ។

[១២:០៧:១៩]

**ស៖** លោកអាចជម្រាប ថាតើរណ្តៅហ្នឹងមានទំហំប្រហែលជាប៉ុនណា?

**ស៖** រណ្តៅហ្នឹងបើថាបួនជ្រុង ដូចមិនដូចបួនជ្រុង គ្រាន់តែវង្វង់ដូចអណ្តូងកអ៊ីចឹង ។ ជម្រៅប្រហែលជាពីរម៉ែត្រប៉ុណ្ណឹង ។ ជីកអត់មានបួនជ្រុង រង្វង់មូល មូលដូចអណ្តូងទឹកល្អយើងហ្នឹង ជម្រៅប្រហែលពីរម៉ែត្រប៉ុណ្ណឹង រណ្តៅបួនហ្នឹង ។

**ស៖** នៅពេលដែលលោកឃើញសាកសពនៅក្នុងរណ្តៅ ថាតើលោកអាចប្រាប់ទេ តើវាមានស្ថានភាពយ៉ាងម៉េច ថាតើពួកគេមានសម្លៀកបំពាក់ដែរឬទេ ? ពួកគេមានចងដៃ ឬក៏ពួកគេអត់មានចង

ដៃ និងអត់សម្លៀកបំពាក់ ថាតើលោកអាចយល់ឃើញថា ពេលនុ៎ងត្រូវបានសម្លាប់តាមរបៀបណា ឬក៏សម្លាប់យ៉ាងម៉េច?

**ឆ៖** តាមខ្ញុំមើលឃើញហ្នឹង វាមានប្រុស មានស្រី ហើយសម្លៀកបំពាក់ធម្មតា ។ ប៉ុន្តែ ខ្លះឃើញអត់អាវអ៊ីចឹងដែរ ។

**ស៖** លោកបានឃើញ ថាតើសាកសពទាំងអស់នោះមានរបួសយ៉ាងម៉េច? ថាតើប្រហែលជាគេ ត្រូវបាន គេសម្លាប់ហ្នឹងយ៉ាងម៉េច? ចំពោះសាកសព ឃើញរបួសយ៉ាងម៉េចដែរ?

**ឆ៖** ក្នុងរណ្តៅហ្នឹង ឃើញតែក្នុងរណ្តៅមុខតែវ៉ៃហើយបង បើអត់មានអីទេ បើឃើញមួយរណ្តៅៗហ្នឹងមានសពនៅក្នុងហ្នឹងទៅហើយ ។ ដូចស្នាមរបួសអីអត់បានឃើញទេ ឃើញតែមនុស្សស្លាប់ចូលរណ្តៅទៅហើយ ឲ្យខ្ញុំមើលម៉េចកើត បើនៅជ្រៅដែរ ។

**លោក អាឡិចសាន់ឌឺ ប៊ើត៖**

លោកប្រធានខ្ញុំនៅសល់សំណួរមួយទៀត ។

**ស៖** លោកបានប្រាប់យើងខ្ញុំថា នៅពេលដែលលោករៀបរាប់អំពីអត្តចរិតរបស់ ឌុច លោកថាបើសិនជាគាត់សើចនឹងមានបញ្ហា ហើយប្រសិនបើមុខគាត់ស្មើ គឺអត់នឹងមានបញ្ហានោះទេ តើលោកអាចជម្រាបយើងខ្ញុំបន្ថែមទៅលើបញ្ហា ថាតើលោកមានន័យយ៉ាងម៉េចចំពោះអត្តចរិតគាត់ សើចហ្នឹងគាត់មុខ គាត់នៅនឹងៗ ?

[១២:១០:២២]

**ឆ៖** បាទ, ព្រោះខ្ញុំធ្លាប់នៅជាមួយគាត់ហ្នឹង ធ្លាប់ឃើញគាត់អ៊ីចឹង ។ កាលណាគាត់សួរចម្លើយអ្នកទោសទៅ និយាយជាមួយកងការពារ បើគាត់និយាយមុខស្ងួត អត់បញ្ហាទេ ។ តែញឹមៗហ្នឹងដូចជារូបខ្ញុំហ្នឹង ត្រូវមាត់ត្រូវកគាត់ញឹកហើយ បីបួនលើក បីសារហើយ នាំអ្នកទោស ទៅធ្វើស្រែធ្វើអីហ្នឹងនាំទៅហូបបាយហ្នឹងក៏រឿងដែរ ។ ញឹមៗវិញច្បាស់ជាខ្ញុំមានរឿងហើយ ។ អ្នកទោសអ៊ីចឹងដែរ បើសួរចម្លើយទៅ បើគាត់មុខស្ងួតអត់អីទេ តែស្រែកហាស់ៗ ហាស់ៗអ៊ីចឹង ប្រយ័ត្នបន្តិចទៅ។ មិនប្រយ័ត្នអីទេ មុខតែមានត្រូវហើយ អាចវ៉ៃ ឬមួយក៏ម៉េចក៏នេះដែរ ។ ប៉ុន្តែ ខ្ញុំឃើញច្បាស់ជាវ៉ៃហើយ ។ តែកងការពារអ៊ីចឹងដែរ បើថាមកពីណាណី តែខុសហើយ តែគាត់ស្តីបន្ទោសហើយ បើមុខស្ងួត គាត់ដើរចេញមិនអីទេ ប្រយ័ត្នតែសើចហេ៎ៗហ្នឹង ច្បាស់ហើយបង ។ ហ្នឹងខ្ញុំកត់សម្គាល់គាត់អ៊ីចឹងតែម្តង ។

**លោក អាឡិចសាន់ឌឺ ប៊េត៖**

អរគុណលោកសាក្សី ចាន់ វឿន ។ អរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ បន្តដំណើរការសវនាការ ។ អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំវិញ ហើយឲ្យនាំគាត់មកកាន់ទីនេះនៅ ឲ្យបានមុនម៉ោងមួយ និងសាមសិបនាទី ហើយមន្ត្រីតុលាការសម្របសម្រួលជូនសាក្សីរូបនេះទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកកាន់សាលសវនាការឲ្យបានមុនម៉ោងមួយកន្លះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ !

*[សវនាការសម្រាកពីម៉ោងម៉ោង១២:១២នាទីដល់ម៉ោង ១៣:៣៨ នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការតទៅទៀត។ ហើយជាកិច្ចបន្តនេះ សូមប្រគល់វេទិកាជូនទៅដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលមានបំណងសួរសំណួរដល់សាក្សីរូបនេះ ។ សូមអញ្ជើញ ដោយចាប់តាមលេខរៀង តាមលំដាប់លេខរៀងពីក្រុម១ រហូតទៅដល់ក្រុម៤ បើមានសូមអញ្ជើញមេធាវីក្រុម១ ។

**លោក អាឡាំង វ៉ែនណឺ៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ដោយមានការអនុញ្ញាតរបស់លោក យើងអត់មានសំណួរទៅកាន់ជនជាប់-- សូមអភ័យទោស គឺយើងខ្ញុំអត់មានសំណួរសួរទៅកាន់សាក្សីទេ។ ប៉ុន្តែយើងខ្ញុំមានសំណួរមួយចំនួនចំពោះជនជាប់ចោទ ទាក់ទងទៅនឹងសក្ខីកម្មរបស់សាក្សីមួយនេះ ។

សូមឲ្យរៀបរាប់ពីអ្នកទោសនៅម-១៣ ដែលត្រូវបានគេកប់ទាំងរស់ ។ តើលោកអាចបញ្ជាក់

ដែរឬទេ គឺនៅក្នុងឆ្នាំ១៩៧៤ គឺមានអ្នកទោសមួយចំនួនត្រូវបានគេកប់នៅក្នុងរណ្តៅ?

**ប្រធានអង្គជំនុំ៖**

សូមមេធាវីតាំងសំណួរម្តងទៀត ហើយបញ្ជាក់ឡើងវិញ ដោយសារអំមិញគាត់អត់ទាន់បានស្តាប់កាសនៅឡើយទេ ហើយអ៊ីចឹងសូមអញ្ជើញមេធាវីតាំងសំណួរម្តងទៀត ដើម្បីឲ្យគាត់ស្តាប់នូវសំណួរឲ្យបាន ហើយទើបអាចឆ្លើយច្បាស់លាស់នូវសំណួរនោះ ។ សូមអញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

**ស៖** សាក្សីនេះព្រឹកមិញ បានរៀបរាប់អំពីអ្នកទោសនៅម-១៣ ដែលត្រូវបានគេកប់ទាំងរស់នៅក្នុងរណ្តៅមួយចំនួន ។ ដូច្នេះ សូមឲ្យលោកជនជាប់ចោទបញ្ជាក់ថានៅឆ្នាំ៧៤ តើមានអ្នកទោសត្រូវបានគេកប់ទាំងរស់ដែរ ឬទេ នៅក្នុងរណ្តៅមួយចំនួននៅ ម-១៣ ក្នុងឆ្នាំ១៩៧៤?

[១៣:៤២:០៩]

**ជនជាប់ចោទ៖**

**ឆ៖** លោកប្រធានជាទីគោរព! តាមខ្ញុំបាទស្តាប់ព្រឹកមិញសក្ខីភាពរបស់ឈ្មោះ ចាន់ វឿន នេះគ្មាន និយាយអំពីអ្នកទោសកប់ទាំងរស់នេះ ។ អាហ្នឹងសូមចប់ ។

**លោក អាឡាំង វ៉ែនណឺ៖**

**ស៖** ខ្ញុំសួរអំពីអ្នកទោសដែលត្រូវបានគេកប់នៅក្នុងរណ្តៅនៅក្នុងឆ្នាំ-- ឃុំខ្លួននៅក្នុងរណ្តៅនៅក្នុង១៩៧៤ អ៊ីចឹងគឺខ្ញុំសួរអំពីសំណួរនេះ ខ្ញុំអត់ដឹងថា តើមានការបកច្រឡំ ឬយ៉ាងម៉េចទេ?

**ប្រធានអង្គជំនុំ៖**

លោកមេធាវីតាំងសំណួរសាជាថ្មីម្តងទៀត ឲ្យច្បាស់លាស់ តើលោកសួរថា យ៉ាងម៉េចទៅ? ហើយសូមជនជាប់ចោទត្រងត្រាប់ស្តាប់នូវសំណួររបស់មេធាវីរូបនេះ ដើម្បីឆ្លើយ ហើយប្រសិនបើដូចអំមិញនេះ គឺក៏បានដែរ ប្រសិនបើមានហេតុផលនៃការសួរហ្នឹង វាខុសអំពីអ្វី ដែលសាក្សីបានធ្វើសក្ខីកម្មអំពីព្រឹកមិញ ។ សូមអញ្ជើញមេធាវី ។

**លោក អាឡាំង វ៉ែនណឺ៖**

**ស៖** សំណួររបស់ខ្ញុំនោះគឺថា លោក សូមឲ្យលោកបញ្ជាក់ថាតើមានមនុស្សមួយចំនួននៅ ម-១៣ នៅក្នុងឆ្នាំ១៩៧៤ ត្រូវបានគេកប់ ត្រូវបានគេឃុំនៅក្នុងរណ្តៅដែរឬទេ? តើមានការឃុំខ្លួនដែរឬទេនៅក្នុងរណ្តៅក្នុងឆ្នាំ១៩៧៤?

**ជនជាប់ចោទ៖**

**ឆ៖** លោកចៅក្រម លោកប្រធានជាទីគោរព! រឿងដែលឃុំឃាំងជនរងគ្រោះនៅមន្ទីរ១៣ តាំងពីកើត រឿងគ្រាប់បែក បេ-៥២ មក យើងខ្ញុំឃុំជនរងគ្រោះនៅក្នុងរណ្តៅ ។ ទាំងខ្ញុំ ទាំងជនរងគ្រោះដែលជាប់ឃុំនៅទីនោះ សុទ្ធតែដេកក្នុងរណ្តៅចំហទាំងអស់គ្នា ។ រឿងនេះ យើងបាននិយាយគ្នាហូរហែរួចមកហើយ មិនគួរលើកយកមកពេលនេះ បញ្ជាក់អីទៀតទេ ។

**ស៖** តើលោកអាចជម្រាបយើងថាមែនឬក៏មិនមែន? ថានៅក្នុងឆ្នាំ១៩៧៤ មានមនុស្សមួយចំនួនត្រូវបានឃុំខ្លួននៅក្នុងរណ្តៅ នៅក្នុងមន្ទីរ ម-១៣ តើមែន ឬក៏មិនមែន?

[១៣:៤៥:00]

**ឆ៖** ខ្ញុំឈប់ឆ្លើយហើយ ខ្ញុំឆ្លើយច្បាស់លាស់រួចហើយ ។

**លោក អាឡាំង វ៉ែនណឺ៖**

ដោយមានការអនុញ្ញាតរបស់លោកប្រធាន គឺជនជាប់ចោទ គឺអត់បានឆ្លើយតបសំណួររបស់ខ្ញុំទេ ហើយវាគ្រាន់តែជាសំណួរសាមញ្ញប៉ុណ្ណោះ ហើយប្រសិនបើគាត់មិនចាំគឺវាអត់បញ្ហាទេ ក៏ប៉ុន្តែជនជាប់ចោទមិនបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំដែលតាំងជូននេះ ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទបាន, អង្គជំនុំជម្រះបានប្រាប់សិទ្ធិគាត់ហើយ គាត់មានសិទ្ធិមិនឆ្លើយនឹងសំណួរដែលសួរបាន ។ អ៊ីចឹងគាត់រក្សាសិទ្ធិមិនឆ្លើយនឹងសំណួរនេះ ដោយហេតុគាត់យល់ថា សំណួរច្រំដែល ។ អ៊ីចឹងបង្វែរត្រឡប់ទៅវិញ គឺគាត់លែងឆ្លើយនឹងសំណួរលោកទៀតហើយ លោកមេធាវី ។ ឥឡូវនេះ គឺវេទិកាត្រូវសួរដល់សាក្សី តើសាក្សីរូបនេះលោកមានសំណួរដែរឬទេ? បើមិនមានទេ យើងនឹងបញ្ជូនវេទិកានេះទៅឲ្យមេធាវីផ្សេងទៀត ។

អញ្ជើញមេធាវីក្រុម២ មានសំណួរអ្វីសួរដល់សាក្សីរូបនេះទេ? បើមានសូមអញ្ជើញ ។

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្តី៖**

សូមគោរពលោកប្រធាន គឺយើងខ្ញុំអត់មានសំណួរណាមួយសួរនោះទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីក្រុម៣ មានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? សូមអញ្ជើញបើមាន ។

**សួរដោយលោក គីម ម៉េងឃី៖**

ខ្ញុំបាទ គីម ម៉េងឃី មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម៣ មានសំណួរសួរទៅកាន់សាក្សីពាក់ព័ន្ធទៅនឹងការងាររបស់លោកដែលថា លោកបានរៀបរាប់ប្រាប់ថា ការងាររបស់លោក គឺជាអ្នកកាន់ខាងកិច្ចការសេដ្ឋកិច្ច ហើយក្រៅពីហ្នឹងគឺលោកនាំអ្នកទោសមួយចំនួនចេញទៅធ្វើការងារ ។

**ស៖** សួរថាតើការនាំអ្នកទោសចេញទៅធ្វើការងារនៅខាងក្រៅហ្នឹង តើអ្វីខ្លះ? ហើយស្ថានភាពនៃការនាំទៅហ្នឹង គឺយ៉ាងម៉េចដែរ?

**សាក្សី KW-31៖**

ឆ៖ បាទ សូមឆ្លើយ ។ កាលនាំនេះ គឺនាំអ្នកទោសយកទៅកាប់ព្រៃធ្វើទំនប់ប ទំនប់ហៅទំនប់ "តាំងទឹង" ។ លើកកាប់ដី លើកធ្វើទំនប់យកទឹកហ្នឹងដឹងអីមិនដឹងកាប់ធ្វើទំនប់ម៉េចទេ? ប៉ុន្តែឲ្យធ្វើទំនប់ហ្នឹង ទៅដល់នុំងប្រហែលជាមួយម៉ោងទេ អត់បានធ្វើអីផង សុំទៅខ្ញុំក៏ឲ្យកាត់ច្រវាក់កាត់អីហ្នឹង ទៅអត់បានធ្វើផង ។ ប្រហែលជាមួយម៉ោងប៉ុណ្ណឹងទេ អ្នកទោសហ្នឹងអាចកាត់ច្រវាក់រត់ ហ្នឹងខ្ញុំនាំទៅ ។

សូមអស់ ។

[១៣:៤៨:៣៨]

**ស៖** អ៊ីចឹងខ្ញុំសូមបញ្ជាក់លោកបន្តិចថា តើលោកនាំទៅដោយខ្លួនឯង ឬក៏មានអ្នក ណាប្រាប់ឲ្យលោកនាំអ្នកទាំងហ្នឹងទៅធ្វើការ?

**ឆ៖** បាទ, សូមឆ្លើយ ។ ព្រោះបញ្ជាពី តាឌុច ផ្ទាល់តែម្តងឲ្យខ្ញុំនាំអ្នកទោសទៅ ព្រោះថ្ងៃនុំងគាត់អត់មានកម្លាំងបញ្ចូលកងការពារហ្នឹង ខ្ញុំក៏មកពីរកខាងសេដ្ឋកិច្ចហ្នឹងក៏គាត់បញ្ចូលខ្ញុំឲ្យទៅជួយការនុំង។ បញ្ជាពីរ តាឌុច ទៅ ។ សូមអស់ ។

**លោក គីម ម៉េងឃី៖**

បាទ ខ្ញុំអស់សំណួរសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

មានទៀតទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក ហ្វីលីព កាណុន៖**

អរគុណលោកប្រធាន លោក កាណុន បានលើកឡើង ។ ខ្ញុំមានសំណួរខ្លីៗសួរទៅកាន់សាក្សី ។ លោក ចាន់ វឿន ព្រឹកមិញនេះ-- ហើយនិងការលើកឡើងរបស់លោកនៅក្នុងចម្លើយដែលបានអានព្រឹក

មិញដូចតទៅ៖

**ស៖** ពេលខ្លះ ឌុច គាត់សប្បាយដូចមនុស្សឆ្កួតនៅពេលដែលគាត់ធ្វើទារុណកម្មអ្នកទោស ។ សំណួររបស់ខ្ញុំនោះ គឺថាលោកអានពន្យល់ថាវាមានន័យយ៉ាងម៉េច? ហើយថាតើអត្តចរិតរបស់គាត់នៅពេលនោះគឺមានលក្ខណៈយ៉ាងម៉េច?

[១៣:៥០:២៤]

**សាក្សី KW-31៖**

**ឆ៖** បាទ, នៅនេះ ដែលខ្ញុំថាគាត់សប្បាយដូចឆ្កួត ព្រោះគាត់បានសួរចម្លើយអ្នកទោសអ៊ីចឹងទៅ ។ ជួនកាលគាត់វ៉ៃ គាត់តប់សើចលែងហ៊ោកញ្ជៀវអ៊ីចឹងទៅ ។ សូមអស់ ។

**ស៖** តើវាបង្ហាញច្បាស់លាស់យ៉ាងម៉េច? ថាគាត់សម្តែងអាកប្បកិរិយា ឬគាត់បញ្ចេញអត្តចរិតយ៉ាងម៉េចអ្វីដែលគាត់ធ្វើនៅពេលនោះ?

**ឆ៖** ពេលនោះ ឲ្យតែគាត់សួរអីគាត់តែងតែសើចផង មុខស្ងួតផង សើចហ៊ោកញ្ជៀវអ៊ីចឹងដូចខ្ញុំបាននិយាយពីខាងដើមអ៊ីចឹង ។ ឲ្យតែគាត់សួរអ្នកទោសហើយ ឲ្យតែគាត់សើចហើយ គឺនឹងមានផែនការរបស់គាត់ហើយ ។ ហ្នឹងខ្ញុំចំណាំ សម្គាល់អ៊ីចឹង ។ មិនបាច់ថាអ្នកទោសទេ គ្រាន់តែកងការពារហ្នឹងមិនហ៊ានមើលមុខគាត់ផងទេ ។ ដូចស្តេចអ៊ីចឹងមិនហ៊ានសម្លឹងមុខទេ ពេលគាត់សួរចម្លើយអ្នកទោសដើរជិតអត់ហ៊ានមើលមុខទេ ។ សូមអស់ ។

[១៣:៥២:០៥]

**ស៖** ខ្ញុំសូមត្រឡប់ទៅបញ្ហាស្ត្រីដែលលោកបានឃើញថា គេធ្វើទារុណកម្មគាត់ ដោយប្រើភ្លើងដុត ។ ព្រឹកមិញលោកបានជម្រាបយើងខ្ញុំថា គឺស្ត្រីនោះមិនស្លាប់ភ្លាមៗនោះទេ ហើយគឺគាត់ត្រូវបានគេយកទៅដាក់ក្នុងគុកវិញ ។ ខ្ញុំចង់សួរថា ថាតើគាត់ហ្នឹងចំណាយពេលរយៈប៉ុន្មានទើបគាត់ហ្នឹងស្លាប់?

**ឆ៖** ពេលដែលគាត់សួរចម្លើយដុតនោះ អត់ៗមានស្លាប់ទេ គាត់គ្រាន់តែដុតវាស្រែក ។ ធម្មតាគ្រាន់តែដុតឈឺស្រែក គាត់នៅតែដុតហើយស្លាប់ទេបង យកមកបញ្ជូលក្នុងគុកវិញ ។ អត់មានស្លាប់នៅកន្លែងដុតនុ៎ងទេ ។ គឺគាត់នាំមកកន្លែងគុកវិញដដែល ។ ហ្នឹងស្ត្រីដែលខ្ញុំឃើញដុតនៅនឹងភ្នែកខ្ញុំហ្នឹង ។ សូមអស់ ។

**ស៖** ថាតើមានអ្វីកើតឡើងចំពោះស្ត្រីនោះ បន្ទាប់ពីនុ៎ងមក?

**ឆ៖** សូមមានប្រសាសន៍ម្តងទៀត ។

[១៣:៥៣:៥៤]

**ស៖** ខ្ញុំនឹងនិយាយសួរឡើងវិញ ហើយបញ្ជាក់បំភ្លឺសំណួរនេះ ។ នៅពេលស្ត្រីនោះត្រូវបានយកទៅដាក់គុកវិញ តើលោកបានដឹងថា មានអ្វីកើតឡើងចំពោះស្ត្រីនោះ បន្ទាប់ពីស្ត្រីនោះត្រូវបានគេនាំយកទៅញាត់ក្នុងគុកវិញ?

**ឆ៖** ពេលនោះខ្ញុំក៏អត់បានដឹងដែរ គ្រាន់តែបានឃើញនាំទៅគុក ម៉េចៗទៀតខ្ញុំអត់បានដឹងដែរ ព្រោះខ្ញុំមិនប៉ាននៅជិតផង ឃើញអ៊ីចឹង ។

**លោក ហ្វីលីព កាណុន៖**

អរគុណលោកប្រធាន ។ គឺខ្ញុំអត់មានសំណួរអីបន្ថែមទៀតទេ ។

[១៣:៥៤:៥២]

**ប្រធានអង្គជំនុំ៖**

ដល់មេធាវីក្រុម៤ តើលោកមានអ្វីត្រូវសួរដល់សាក្សីរូបនេះទេ? បើមានសូមអញ្ជើញ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន និងសូមគោរពលោកប្រធាន ព្រមទាំងលោក លោកស្រីចៅក្រមជំនុំជម្រះ នៃអង្គជំនុំជម្រះជាទីគោរព ។ ខ្ញុំបាទ ហុង គឹមសួន សូមអនុញ្ញាតសួរសាក្សីលោក ចាន់ វឿន ពីព្រឹកមិញលោកបានមានប្រសាសន៍ទាក់ទងជាមួយនឹងឈ្មោះ ហម អ៊ីន លោកថាបានស្គាល់ ហើយស្លាប់បាត់ទៅហើយ ។ តើការស្លាប់របស់ ហម អ៊ីន នោះស្លាប់នៅក្នុងម-១៣ ឬក្រោយពេលចេញពីម-១៣?

**សាក្សី KW-31៖**

**ឆ៖** ឈ្មោះ ហម អ៊ីន ដែលត្រូវជាពួកម៉ាកខ្ញុំផងនោះ មិនស្លាប់ក្នុងមន្ទីរ-១៣ ទេ ។ ព្រោះគាត់បានដោះលែងឲ្យបានមកផ្ទះអី ស្លាប់នៅផ្ទះហ្នឹងទេ ។ អត់មានស្លាប់នៅក្នុងគុកទេ ព្រោះ ហម អ៊ីន ហ្នឹងគាត់អ្នកជាប់គុក ។ ហើយនេះ តាឌុច គាត់ដោះលែងមកស្លាប់នៅនឹងផ្ទះហ្នឹង ទើបតែនឹងស្លាប់ដែរទេ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរសំណួរបន្តទៅទៀត ឈ្មោះ សយ ដែលលោកបានមានប្រសាសន៍ជូនលោកប្រធាននិងអង្គជំនុំជម្រះព្រឹកមិញនោះ តើឈ្មោះ សយ ហ្នឹងជាអ្នកទោសដែល

លោកថាបានឃើញលោក ឌុច បាញ់សម្លាប់ តើមនុស្សហ្នឹងផ្សេងពីពូរបស់លោក ឬយ៉ាងម៉េច?

**ឆ៖** សូមឆ្លើយ ។ សយ គឺពូខ្ញុំ ។ ពូជីដូនមួយ ដែលគាត់ត្រូវបានបាញ់សម្លាប់ហ្នឹង គឺពូខ្ញុំតែម្តង ពូសយ នៅអមលាំងហ្នឹងតែម្តង ។ នៅផ្ទះជិតខ្ញុំហ្នឹង ត្រូវជាមាខ្ញុំ គាត់បាញ់សម្លាប់នឹងគឺ សយ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរតទៅទៀត ឪពុកមារបស់លោក តើត្រូវបានចាប់ពីក្នុងភូមិមក ឬក៏គាត់ជាបុគ្គលិកនៅក្នុងមន្ទីរម-១៣?

**ឆ៖** កាលដែលគេចាប់គាត់ហ្នឹង មានដូចថា ឈ្លបគេ ពីដើមជំនាន់នោះហៅ "ឈ្លប" កងឈ្លប ហ្នឹងចាប់គាត់មក ។ ចាប់យកមកមន្ទីរ-១៣ ហ្នឹង មិនមែន តាឌុច ហ្នឹងគាត់ចាប់ផ្ទាល់ដៃទេ មានកងឈ្លបគេចាប់ គាត់ហ្នឹងមកបញ្ជូនមកមន្ទីរហ្នឹង ។ សូមអស់ ។

[១៣:៥៧:២២]

**ស៖** តើខ្លួនលោកផ្ទាល់នៅពេលមកម-១៣ នេះ មានការសួរយកចម្លើយពីលោក ឌុច ដែរឬទេ?

**ឆ៖** ចំពោះខ្ញុំអត់ប៉ាន ព្រោះជំនាន់នុ៎ងថា "ក្បាលអ្នកណា សក់អ្នកហ្នឹង" ចាប់បងប្អូនខ្ញុំអត់ប៉ានមាត់ដែរ អត់ប៉ានឲ្យប៉ះពាល់អីទេ ព្រោះខ្លាច ។

**ស៖** សំណួរខ្ញុំសួរថា លោកៗផ្ទាល់ តើមានការសាកសួរចម្លើយពីលោក ឌុច ដែរឬទេ? សួរលោកតែម្តង ។ សូមអរគុណ ។

**ឆ៖** អត់បានទេ ។ អត់បានសួរចម្លើយទេ ។ អត់បានទទួល ។ សូមអស់ ។

**ស៖** នៅក្នុងមន្ទីរម-១៣ តើលោកមានជាប់សាច់ញាតិនឹងបុគ្គលិករបស់ម-១៣ ដែលទេកាលនោះ?

**ឆ៖** បាទអត់ ។ អត់មាន ។

**ស៖** លោកបានឆ្លើយព្រឹកមិញថា លោកបានហែករបងឫស្សីរត់គេចខ្លួនទៅដល់ភូមិ ហើយត្រូវបានមេភូមិបញ្ជូនមក ម-១៣ វិញ ឬយ៉ាងម៉េច?

**ឆ៖** ការពិតអ៊ីចឹងមែន ។ ម៉ោង៩យប់ ខ្ញុំរត់ៗចេញ ហែករបងគុករត់ៗទៅដល់ប្រធានភូមិនុ៎ងឲ្យប្រធានភូមិជួយ ។ បានប្រធានភូមិគាត់ថា ហើយចាំព្រឹកអញបញ្ជូនអ្អែងមកមន្ទីរហ្នឹងវិញ ចាំអ្អែងធានា ព្រឹកឡើកគាត់បញ្ជូនខ្ញុំមកវិញ ។ មកហើយក៏ប្រធានភូមិហ្នឹងនិយាយថា ធានាថានិយាយជាមួយនឹង តាឌុច ហ្នឹង ឲ្យវានៅហ្នឹង ហើយខ្ញុំមិនឲ្យវាទៅទេ ។ ប្រហែលជាមួយអាទិត្យបានគាត់ឃើញធ្វើក្រដាសលិខិតឲ្យខ្ញុំមួយចេញទៅនឹងតាមសហករណ៍ទៀត ។ បានខ្ញុំរួចពីពេលនុ៎ងរហូតដល់សព្វថ្ងៃនេះ។

សូមអស់ ។

[១៣:៥៩:១១]

**លោក ហុង គីមសួន៖**

បាទ សូមអរគុណលោកប្រធាន សូមចប់ហើយ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៅនេះសូមប្រគល់វេទិកានេះជូនទៅ មេធាវីការពារក្តី ។ តើមេធាវីការពារក្តីហ្នឹងមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញ ។

[១៣:៥៩:៥៧]

**សួរដោយលោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណ លោកចៅក្រម ។

**ស៖** លោកសាក្សី, ខ្ញុំចង់សួរលោកនូវសំណួរតូចៗជាក់លាក់មួយចំនួន ។ ដំបូងគឺ ខ្ញុំចង់សួរទាក់ទងទៅនឹងប្រវត្តិរូបផ្ទាល់ខ្លួនរបស់លោក ។ តើលោកមានស្គាល់មនុស្សម្នាក់ឈ្មោះ (ខ្ញុំសុំទោស) លោកស្គាល់ មនុស្សម្នាក់ឈ្មោះ ចាំង កាំ ទេ?

**សាក្សី KW-31៖**

**ឆ៖** បាទអត់ស្គាល់ផង ។

**ស៖** ខ្ញុំមិនបានឮចម្លើយពីសាក្សីទេ ។ ខ្ញុំនឹងសុំសួរសំណួរឡើងវិញម្តងទៀត ។
តើលោកសាក្សីមានស្គាល់មនុស្សម្នាក់ឈ្មោះ ចាំង កាន់ ទេ?

**ឆ៖** បាទខ្ញុំអត់បានស្គាល់ទេ ។

**ស៖** សូមលោកប្រាប់ឈ្មោះឪពុករបស់គាត់មើល?

**ឆ៖** ចាំង កាំង ណាមួយ? ខ្ញុំអត់ស្គាល់ផង ឲ្យខ្ញុំប្រាប់ម៉េចកើត ដឹងឈ្មោះអីផង ។

**ស៖** គឺយើងមានបញ្ហាជាមួយនឹងការបកប្រែ ។ អ៊ីចឹងខ្ញុំមិនដឹងថា តើមានសំណួរយ៉ាងម៉េចទេ? ជាមួយការឆ្លើយនេះ ពីព្រោះឥឡូវនេះ គឺថាយើងឋិតនៅក្នុងដំណើរការនីតិវិធីផ្នែកច្បាប់ ហើយយើងមានបញ្ហាបំផុតទាក់ទងទៅនឹងការបកប្រែ ។ បើអ៊ីចឹង ខ្ញុំនឹងនិយាយពីបញ្ហានេះ នៅពេលក្រោយ។ ឥឡូវហ្នឹង ខ្ញុំចង់និយាយម្តងទៀតពីសំណួររបស់ខ្ញុំ ។ អ៊ីចឹងរបស់ខ្ញុំ គឺតើលោកសាក្សី លោកមានស្គាល់មនុស្សម្នាក់ឈ្មោះ ចាន់ ខន ទេ?

**ឆះ** បាទ, ស្គាល់ ។

**សះ** ជាថ្មីម្តងទៀត តើលោកអាចប្រាប់ឈ្មោះឪពុករបស់ ចាន់ ខន បានទេ? គាត់ឈ្មោះអីដែរ ឪពុករបស់គាត់ហ្នឹង?

**ឆះ** បាទ,អាចប្រាប់បាន ។ ឈ្មោះ ខុម ប៉ុន្តែមិនដឹងតាគាត់ស្អីទេ ។ ខ្ញុំស្គាល់ឪពុកគាត់ ខុម, ខុម ពែល ម្តាយគាត់ឈ្មោះ ពែល ។

[១៤:០៤:២០]

**សះ** ហើយសូមលោកប្រាប់ឈ្មោះភូមិរបស់គាត់មើល តើគាត់រស់នៅភូមិណា? ភូមិដែលគាត់កំពុងតែរស់នៅហ្នឹង!

**ឆះ** ភូមិគាត់កំពុងរស់នៅសព្វថ្ងៃ ភូមិតានៀត ។

**សះ** តើគាត់នឹងជាសាច់ញាតិរបស់លោកឬ? ចាន់ ខន ហ្នឹងជាសាច់ញាតិរបស់លោកឬ?

**ឆះ** ហ្នឹងត្រូវ អត់សាច់ញាតិទេ ប៉ុន្តែខ្ញុំហៅវាថា ពូកម៉ាក ។ សូមអស់ ។

[១៤:០៥:៤២]

**សះ** អ៊ីចឹង តើគាត់ហ្នឹងធ្លាប់ត្រូវបានគេដាក់ក្នុងមន្ទីរឃុំឃាំងនៅមន្ទីរ១៣ ដែរឬ?

**ឆះ** អាត្រង់ហ្នឹង តាមខ្ញុំដឹង គាត់កងការពារដែរ ។ កងការពារ ដូចខ្ញុំអ៊ីចឹង។ ប៉ុន្តែ ក្រោយមក ខ្ញុំរត់បាត់ ខ្ញុំអត់ដឹងទេ គាត់មានទោសមានអីនៅខាងក្រោយ ខ្ញុំអត់បានដឹងដែរ ។ សូមអស់ ។

**សះ** លោក ចាន់ វឿន តើការពិតលោកជាអ្នកបានរៀបការជាមួយនឹងអ្នកស្រីម្នាក់ឈ្មោះមៀល ឬ?

**ឆះ** បាទ,អត់ទេ អត់ដឹងផង ។

**សះ** អ៊ីចឹង គឺឈ្មោះ ម៉ាលី ។ តើមានលោករៀបការជាមួយនឹងស្ត្រីម្នាក់ឈ្មោះ ម៉ាលី ឬទេ?

**ឆះ** អត់បាទ អត់បានដឹងផង ។

**សះ** អ៊ីចឹង តើលោកអាចប្រាប់បានទេ ប្រពន្ធរបស់លោកឈ្មោះអ្វីដែរ?

**ឆះ** ប្រពន្ធខ្ញុំ ។ ប្រពន្ធលើកទីមួយឈ្មោះ ទូច ។ ប៉ុន្តែ ស្លាប់បាត់ហើយ ។ ក្រោយមក ខ្ញុំបានប្រពន្ធក្រោយ នៅភូមិព្រែក ឈ្មោះ អឿន ។ បាទអត់មាន ម៉ាលីស ទេ ឈ្មោះ អឿន ក្រោយហ្នឹង ។ នៅសព្វថ្ងៃហ្នឹង ។ សូមអស់ ។

**សះ** សូមអរគុណលោក វឿន ។ ព្រឹកមិញលោកបាននិយាយថា នៅមុនដំបូង នៅពេលដែល

ពេលលោកត្រូវបានគេឱ្យទៅធ្វើការក្នុងមន្ទីរម-១៣ ហ្នឹង លោកធ្វើនៅខាងផ្នែកសេដ្ឋកិច្ច តើត្រឹមត្រូវទេ?

**ឆ៖** បាទពិតជាត្រឹមត្រូវ ។ គាត់ចាត់តាំងខ្ញុំ ធ្វើជាសេដ្ឋកិច្ចមែន ។

[១៤:០៨:២៨]

**ស៖** តើលោកអាចនិយាយប្រាប់បានទេ? ឬក៏អាចប្រាប់មកពួកយើងថា តើលោកធ្វើការនៅខាងផ្នែកសេដ្ឋកិច្ចហ្នឹង អស់រយៈពេលប៉ុន្មានខែដែរ? បើសិនជាលោកអាចនៅចាំ ។

**ឆ៖** អាចនៅពេលនុ៎ង ខ្ញុំមិនសូវបានចាំ ប៉ុន្តែតែអស់ពេលយូរដែរ យូរពេកទៅហើយ ។ ដើរហ្នឹងសឹងអស់ៗរទេះគោមួយហើយ គ្រាន់តែដើររកស្រូវឱ្យអ្នកទោសហ្នឹង ។ មានរទេះគោមួយ ខ្ញុំនិយាយប្រវត្តិមួយ គាត់ស្លាប់បាត់ហើយ ជាមួយខ្មោចតា ស៊យ ហើយនិង ម៉ន ហ្នឹង ដើរសេដ្ឋកិច្ច ។ យកក្រណាត់ទៅដូរនៅរលាក់កងជើងយើងខាងតេទឹកពុះអីនុ៎ង ទៅនុ៎ងទេ ។ ស្របក់នឹងដូរក្រណាត់យកស្រូវទិញអាថ្មពិលអីហ្នឹង យកទៅដូរស្រូវគេហ្នឹង បានទៅមកយកចិញ្ចឹមអ្នកទោសហ្នឹង វារយៈពេលយូរពេលដែរ ។ សូមអស់ ។

[១៤:០៩:៤៤]

**ស៖** ខ្ញុំសុំទោស សូមសួរលោកនូវសំណួរនេះ ។ អ៊ីចឹង រយៈពេលវែងហ្នឹង តើមានន័យថាម៉េច? ប៉ុន្មានខែ បីខែ, បួនខែ ឬក៏ប្រាំខែ តើលោកអាចបញ្ជាក់ឱ្យបានច្បាស់បានជាងហ្នឹងទៀតទេ? អាចបញ្ជាក់ឱ្យបានច្បាស់ជាងហ្នឹងបន្តិចទៀតទេលោក?

**ឆ៖** បានប្រហែលជាបួនខែជាងចុះ ។ អាជាងហ្នឹង ខ្ញុំមិនដឹងទេ ប៉ុន្តែថាចំនួនប្រហែលប៉ុណ្ណឹង។ បាទ ព្រោះខ្ញុំ ហើយបានគាត់មកឱ្យខ្ញុំនៅក្នុងមន្ទីរវិញ ។

**ស៖** សូមអរគុណ។ អ៊ីចឹង បន្ទាប់ពីពេលហ្នឹងមកឬ ដែលលោកបានក្លាយខ្លួនទៅជាអ្នកយាមនោះ?

**ឆ៖** ដល់ពេលហ្នឹងហើយ គាត់ឱ្យខ្ញុំយាមអ្នកទោសនោះ ។ ខ្ញុំលែងដើរសេដ្ឋកិច្ចហើយ មកធ្វើការនៅក្នុងមន្ទីរជាមួយគាត់ហ្នឹង ក៏គាត់ឱ្យខ្ញុំ អីយាមអ្នកទោសក្រៅបន្តិចបន្តួចហ្នឹង។ ដល់ថ្ងៃមួយបានបញ្ចេញអ្នកទោសហ្នឹងនៅក្រៅ ដូចខ្ញុំបានជម្រាបខាងដើមអ៊ីចឹង យកទៅធ្វើការធ្វើទំនប់យើងនៅត្រពាំងទឹងហ្នឹង ។ ឈ្មោះ អូរត្រពាំងទឹងហ្នឹង គាត់ឱ្យលើកទំនប់ លើកអី ឆ្ការព្រៃហ្នឹងទៅ ។ ដល់ថ្ងៃហ្នឹងថៃដន្យអីបានខ្ញុំដោះលែងរួចទៅ បានជាខ្ញុំមានរឿងមានទោសហ្នឹងមកជាប់គុកកន្លែងគាត់ហ្នឹង ខ្ញុំបានរត់

រួចទៅ ហើយពីហ្នឹងខ្ញុំអត់មានដឹងសាច់រឿងអីទៀតទេ ចប់ត្រឹមខ្ញុំអស់គុកហើយ ដកខ្ញុំទៅនៅសហ-ករណ៍ហ្នឹង ខ្ញុំក៏លែងដឹងរឿងពីកន្លែងគាត់ទៀត ។ សូមអស់យោបល់ ។

**ស៖** អ៊ីចឹង លោកបានធ្វើជាអ្នកយាមហ្នឹង តើអស់រយៈពេលប៉ុន្មាន? បើតាមលោកចាំនោះ?

[១៤:១១:៤៧]

**ឆ៖** អស់ពេលយូរដែរ ។ ប្រហែលជាទ្រង់ បើមិនបី ទៅបួនប៉ុណ្ណឹងដែលខ្ញុំឈប់ដើរសេដ្ឋកិច្ចហ្នឹង។ ហើយបានប្រហែលចំនួនប៉ុណ្ណឹង បានខ្ញុំឱ្យរួចអ្នកទោសទៅ បានខ្ញុំអស់មានសិទ្ធិនៅកន្លែងគាត់ហើយ។ ខ្ញុំបានរត់ចេញទៅ គេបញ្ជូនវិញ គាត់បញ្ជូនខ្ញុំទៅនៅសហករណ៍ ចប់ត្រឹមហ្នឹង ។ អត់មានដឹងរឿងអីទៀតទេ ។

**ស៖** ដូច្នេះ បើសិនខ្ញុំព្យាយាមសង្ខេបនូវអ្វីដែលលោកនិយាយហ្នឹង មានន័យថា លោកចាំថាលោកបានធ្វើការផ្នែកសេដ្ឋកិច្ចហ្នឹង ប្រហែលជាបួនខែ ហើយក្រោយមកលោកនៅចាំថា លោកបានធ្វើជាអ្នកយាមហ្នឹង ប្រហែលជាបួនខែទៀត ។ តើត្រឹមត្រូវទេ?

[១៤:១២:៤៤]

**ឆ៖** ពិតជាត្រឹមត្រូវ ។

**ស៖** ដូច្នេះ ខ្ញុំជឿថា ប្រហែលជាលោកនៅចាំថា ចាំឈ្មោះអ្នកយាមផ្សេងៗទៀត ដែលលោកបានធ្វើជាមួយនោះ ។ ដូច្នេះ តើលោកអាចប្រាប់ឈ្មោះអ្នកយាមខ្លះបានទេ ដែលលោកគិតធ្លាប់ធ្វើការជាមួយនោះ?

**ឆ៖** ខ្ញុំបាទជម្រាបបានខ្លះ មិនបានខ្លះ ព្រោះខ្ញុំភ្លេច ព្រោះវាមានអ្នកក្រៅច្រើនដែរ ។ ខ្ញុំចាំតែកន្លែង ដូចជាភូមិខ្ញុំអ៊ីចឹងមាន ខន ហ្នឹងមួយ, ហិន នោះពីរ, ឈិន នោះបី មកយើងខាងត្បូង ជឿននោះមួយទៀត ចាំតែប៉ុណ្ណឹងទេ ដែលអ្នកកងការពារនៅមន្ទីរ១៣ ហ្នឹង ។

**ស៖** លោកបានប្រាប់ពួកខ្ញុំកាលពីព្រឹកមិញថា លោកបានធ្វើជាមួយផ្នែកសេដ្ឋកិច្ចហ្នឹង គឺថាលោកបានមកកន្លែងមន្ទីរហ្នឹង ប្រហែលជារៀងរាល់ពីរអាទិត្យម្តងមែនទេ? មានន័យថា ពីរអាទិត្យបានមកម្តង ។

**ឆ៖** ទៅឆ្ងាយអ៊ីចឹងទៅ ពីរអាទិត្យ បើជិតទៅមួយអាទិត្យជាងបានវិលមកវិញ ។ ទម្រាំតែដើររកស្រូវរកអង្ករហ្នឹងបាន ។

**ស៖** អ៊ីចឹងនៅពេលលោកត្រឡប់មកវិញហ្នឹង តើលោកនៅក្នុងមន្ទីរហ្នឹងអស់រយៈពេលប៉ុន្មានថ្ងៃ?

**ឆ៖** អត់កំណត់ដែរ ។ ជួនកាលមកទៅ បានមួយអាទិត្យជាង ឬក៏២០ថ្ងៃជាងអ៊ីចឹងទៅ ។ អត់ទៅឡើងទៅទៀត ។ តាមមានក្រណាត់ មានក្រណាត់ចុះមកដល់ថ្ងៃណា ទៅថ្ងៃហ្នឹងទៅ ។ កាលណាយើងដូរអស់ក្រណាត់ហើយ ទម្រាំចាំក្រណាត់ថ្នាក់លើបើកមកឲ្យទៀត ដើររកទៅទៀត ។ វាអត់ពេលកំណត់ ។

[១៤:១៥:២១]

**ស៖** អ៊ីចឹង នៅក្នុងអំឡុងពេលនុំង នៅពេលដែលលោកស្នាក់នៅក្នុងមន្ទីរនោះ លោកបាននិយាយប្រាប់ទៅខាងសហព្រះរាជអាជ្ញានៅពេលសហព្រះរាជអាជ្ញាសួរសំណួរនោះ គឺថា លោកបាននិយាយថា លោកបានឃើញ ឌុច ធ្វើការសួរចម្លើយបីទៅបួនដង ។ តើជាការត្រឹមត្រូវទេដែលថាលោកបានឃើញ ឌុច សួរចម្លើយបីទៅបួនដងនោះ?

**ឆ៖** បាទ ពិតបានឃើញ ។ ពិតជាត្រឹមត្រូវ ការពិត ។

**ស៖** ដូច្នេះតើលោកអាចប្រាប់តុលាការបានទេ? តើការសួរចម្លើយបីបួនដងហ្នឹង ដែរលោកបានឃើញហ្នឹង ធ្វើឡើងនៅកន្លែងណា? ហើយការសួរចម្លើយហ្នឹងធ្វើឡើងនៅក្នុងបន្ទប់ ឬធ្វើនៅក្រៅបន្ទប់?

**ឆ៖** ពេលគាត់យកអ្នកទោសមកសួរចម្លើយ ជួនកាលក្រៅគុក ជួនកាលក្នុងគុក។ ដល់ពេលយប់អ៊ីចឹងទៅ គាត់សួរក្នុងគុក ពេលថ្ងៃគាត់បញ្ចេញអ្នកទោសហ្នឹងក្រៅគុកអ៊ីចឹងសួរ ។

**ស៖** បើអ៊ីចឹង ឥឡូវយើងព្យាយាមបញ្ជាក់ឲ្យបានច្បាស់ជាងហ្នឹងបន្តិច លោកនិយាយថា លោកបានឃើញការសួរចម្លើយហ្នឹងបីទៅបួនដង ។ អ៊ីចឹង តើលោកបានឃើញ ឌុច សួរចម្លើយហ្នឹងនៅខាងក្រៅគុកហ្នឹងប៉ុន្មានដង ហើយនៅខាងក្នុងគុកហ្នឹងប៉ុន្មានដង?

**ឆ៖** ឃើញនៅខាងក្រៅបីដង ។ សួរចម្លើយខាងមនុស្សស្រីនោះម្តង ប្រុសពីរដង ។ បើនៅខាងក្នុងនុំង ឃើញបីបួនដង មានតែប៉ុណ្ណឹងទេ ។ គាត់សួរ ម្តងសួរអ្នកនេះ ម្តងសួរអ្នកនោះអ៊ីចឹងទៅផ្លាស់ប្តូរគ្នា ។ កាលណាអានេះសួរមិនឆ្លើយអ៊ីចឹងទៅ គាត់ទុកហ្នឹងទៅ យកមួយមកសួរមួយទៀត ។ ព្រោះមានសួរយប់ មានសួរថ្ងៃ មានសួរក្នុងគុក មានសួរក្រៅគុក ។ សូមអស់។

**ស៖** នៅពេលដែលលោកនិយាយថា នៅខាងក្រៅគុកហ្នឹង តើលោកចង់និយាយថា មានន័យថាម៉េចនៅខាងក្រៅគុកនោះ?

**ឆ៖** ក្រៅគុកហ្នឹង គឺគាត់ថាឧបមាថានាំអ្នកទោសសួរយកមកក្រៅគុកអ៊ីចឹងមក មិនឆ្ងាយប៉ុន្មានពីរបងឫស្សីគុកហ្នឹងទេ ។ សួរជិតហ្នឹង ប៉ុន្តែ នៅខាងក្រៅមិននៅក្នុងគុកទេ ។ មួយក្នុងគុកមួយ

ខាងក្រៅ ។ សូមអស់ ។

[១៤:១៨:៣៩]

**ស៖** មានន័យថា តើនៅខាងក្រៅរបងឫស្សីគុកហ្នឹងឬ? ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលហ្នឹង គាត់គ្រាន់តែបញ្ចេញដែរ-- ឧបមាថា ក្នុងគុកបញ្ចេញមកក្រៅអ៊ីចឹង ជិតរបងខាងក្រៅ ប្រហែលជាប់របងគុកមិនឆ្ងាយទេ ។ គាត់យកមកជាប់របងគុកដែរ ប៉ុន្តែ ខាងក្រៅ សួរហើយបានគាត់យកមកក្នុងវិញ ។ អាហ្នឹងថា ខាងក្រៅ ។ ពេលគាត់សួរខាងក្នុងហ្នឹងៗ សួរខាងក្នុងគុកហ្នឹង ចេញពីរណ្តៅគុកមកសួរនៅនឹងដីយើងហ្នឹង ប៉ុន្តែ ខាងក្នុងគុក ។ អ្នកក្រៅយកទៅក្រៅ សួរខាងក្រៅគុករបងឫស្សីយើង វាមានបួនជ្រុងវែងអ៊ីចឹងទៅ គាត់នាំទៅខាងក្រៅអ៊ីចឹងទៅ មិនឆ្ងាយពីគុកទេ ប៉ុន្តែគេហៅថា ចេញពីគុកខាងក្រៅ ។ ខាងក្រៅគុក ។ សូមចប់ ។

**ស៖** បើអ៊ីចឹង ឥឡូវយើងចាប់ផ្តើមជាមួយនឹងចំណុចមួយនេះ បានន័យថា លោកបានឃើញគាត់ហ្នឹងសួរចម្លើយអ្នកទោសហ្នឹង គឺនៅខាងក្រៅៗរបង ។ អ៊ីចឹង តើពេលនោះនុ៎ង នរណាគេដែលនៅជាមួយ ឌុច ក្រៅពីអ្នកជាប់ឃុំឃាំងនោះ នៅពេលដែលគាត់សួរចម្លើយអ្នកទោសនៅខាងក្រៅគុកនោះ?

**ឆ៖** ពេលនោះអត់មាន មានតែគាត់និងអ្នកទោសហ្នឹងទេ ។ សួរជាមួយអ្នកទោស គឺមានតែ ឌុច និងអ្នកទោសហ្នឹងទេ អត់មានកងការពារនៅជិតទេ។

**ស៖** អ៊ីចឹងបើសិនជា ខ្ញុំយល់អំពីអ្វីដែលលោកនិយាយនោះ អ៊ីចឹងប្រហែលជាបីទៅបួនដងដែលលោកនិយាយនោះ គឺថាលោកបានឃើញ ឌុច ចេញពីគុកហ្នឹង ដែលនាំអ្នកទោសចេញហើយសួរចម្លើយនៅខាងក្រៅ ។ អ៊ីចឹង នៅពេលដែលលោកឃើញហើយ លោកនៅឯណាវិញដែរ?

**ឆ៖** ខ្ញុំចេះតែនៅជិតៗហ្នឹង អត់ប៉ានជិតគាត់ទេ ។ មើលតែរបៀបកងការពារ គ្រាន់តែដើរខាងៗហ្នឹង បើរឿងគាត់សួរអ្នកទោសអ៊ីចឹងយើងសិទ្ធិកងការពារអត់ប៉ាននៅជិតគាត់ទេ ។ ដូចខ្ញុំជម្រាបខាងដើមហ្នឹង ព្រោះមើលមុខគាត់អត់ប៉ានមើលផង រកជិតគាត់ទៀត ។

**ស៖** តើនរណាគេអនុញ្ញាតឲ្យលោកចេញទៅខាងក្រៅគុក បើសិនជា ឌុច នៅខាងក្រៅគុកហើយលោកជាអ្នកយាម ។ តើនរណាគេអនុញ្ញាតឲ្យចេញទៅខាងក្រៅគុកនោះ ចេញទៅខាងក្រៅរបងគុកនោះ?

**ឆ៖** នៅពេលនោះនាទីកងការពារមានសិទ្ធិដើរដែរ ។ មិនមែនត្រឹមតែយាមអ្នកទោសទេ ទោះបីអត់យាមនៅក្នុងហ្នឹង ក៏អាចដើរទៅក្រៅបាន ដើរមកក្នុងបានដែរ ។ អត់ដូចអ្នកទោសអី គេយកទៅដាក់គុកមិនឲ្យដើរទេ ។ ព្រោះកងការពារ វាមានសិទ្ធិចេញចូល ។ ចេញខាងក្រៅបានចូលខាងក្នុងខាងបានដែរ ។ សូមអស់ ។

[១៤:២២:១៥]

**ស៖** អ៊ីចឹងលោកទើបតែនិយាយប្រាប់ពួកយើងថា ឌុច នៅតែឯងទេ នៅជាមួយអ្នកទោស ហើយលោកនៅជាមួយអ្នកយាមផ្សេងៗទៀត ។ អ៊ីចឹង តើលោកអាចប្រាប់មកខាងតុលាការនូវឈ្មោះរបស់អ្នកយាមដែលនៅជាមួយលោកនៅពេលនោះ? ហើយដែលថា អាចបានឃើញនូវអ្វីដែលបានកើតឡើង ដែលដូចដែលលោកបាននិយាយប្រាប់នោះ?

**ឆ៖** ខ្ញុំមិនសូវបានចាំឈ្មោះដែរ អ្នកយាមនោះវាមានច្រើនដែរហ្នឹង ។ ជានរណាៗទេ វាច្របូកច្របល់គ្នាដែរ ប្រហែលជាប្រាំមួយប្រាំពីរនាក់អ៊ីចឹងទៅ ។ ប៉ុន្តែ ពេលគាត់សួរចម្លើយកងការពារយាមតែអ្នកទោសនៅខាងក្នុងហ្នឹងទេ រឿងយកមកក្រៅអត់មានយាមទេ ។ គាត់សួរចម្លើយ អត់មានទៅយាមអ្នកសួរចម្លើយហ្នឹងទេ គាត់សួរតែគាត់ជាមួយអ្នកទោសអ៊ីចឹងទៅ កងការពារនៅការពារនៅក្នុងគុកហ្នឹងទេ ។ សូមអស់ ។

**ស៖** អ៊ីចឹង លោកប្រាប់ពួកយើងថា មិនមានអ្នកយាមណាដែលបានចេញទៅជាមួយលោក ឌុច ទេ នៅពេលដែលគាត់ចេញទៅក្រៅ ។ ប៉ុន្តែ លោកវិញ លោកនៅជាមួយអ្នកយាមដល់ទៅប្រាំមួយនាក់ដែលលោកនៅឈរជិត ឌុច ហើយអាចមើលឃើញអ្វីដែលគាត់ធ្វើ ។ អ៊ីចឹង នេះជាអ្វីដែលខ្ញុំយល់ហ្នឹងត្រឹមត្រូវទេ?

**ឆ៖** ពិតត្រឹមត្រូវ ។

**ស៖** អ៊ីចឹង តើនរណាគេខ្លះនៅជាមួយលោកនៅពេលនោះ?

**ឆ៖** នៅហ្នឹងឈ្មោះ ខន ហ្នឹង ហើយនិង ហិន, ជឿន ណាៗទៀត ខ្ញុំវាភ្លេចឈ្មោះអស់ហើយ វាប្រាំមួយនាក់ហ្នឹង វាមិនសូវបានចាំវាអស់ទេ ។ ច្របូកច្របល់គ្នា វាដើរចុះដើរឡើងហ្នឹង ។

**ស៖** អ៊ីចឹង ទៅតាមអ្វីដែលខ្ញុំយល់នោះ គឺថាការសួរចម្លើយ ការធ្វើទារុណកម្មហ្នឹង បានធ្វើឡើងហ្នឹងបានធ្វើឡើងនៅកណ្តាលវាល មែនទេ?

**ឆ៖** បាទ, បានធ្វើកណ្តាលវាលមែន អត់មានអីបិទបាំងទេ ព្រោះកន្លែងនុ៎ងគុកឫស្សី អត់មាន

ជញ្ជាំងក្តារអ៊ីចឹងណា ។ បើធ្វើខាងក្នុងបាំងឫស្សី ចេញខាងក្រៅកណ្តាលវាលហើយ ។ សូមអស់ ។

**ស៖** ដូច្នេះហើយ មានន័យថាគ្រប់គ្នាហ្នឹង គឺអាចបានឮចម្លើយពីអ្នកទោសនោះ ដែលពេលហ្នឹងឯងកំពុងតែត្រូវបានសួរចម្លើយ មានន័យថាចម្លើយរបស់គាត់នរណាក៏គេស្តាប់ឮដែរ មែនទេ?

[១៤:២៥:២២]

**ឆ៖** ពិតស្តាប់បានហើយ ។ បើជិតៗអ៊ីចឹង ហើយគាត់សួរកណ្តាលវាល ឬខាងក្នុងហ្នឹងក៏កន្លែងហ្នឹង អាចកងការពារដើរចុះដើរឡើងស្តាប់បានទាំងអស់ ។ បាទ, ការពិត ។

**ស៖** ជាការប្រសើរណាស់អ៊ីចឹង ។ ឥឡូវយើងនិយាយម្តងទៀត អំពីស្ត្រីដែលជាអ្នកទោសនោះ ដែលលោកនិយាយថា ឌុច បានធ្វើទារុណកម្មលើរូបគាត់ ។ អ៊ីចឹង តើពេលនុំងគាត់ហ្នឹងត្រូវបានគេសួរចម្លើយនៅកន្លែងណា? នៅខាងក្នុងរបងគុក ឬក៏នៅខាងក្រៅរបងគុក?

**ឆ៖** ដែលស្ត្រីគាត់សួរចម្លើយដល់ដុតហ្នឹង នៅខាងក្រៅគុក ។ របងគុកវាវែងអ៊ីចឹង អានេះជ្រុងខាងទទឹងអ៊ីចឹង គាត់ធ្វើសកម្មភាពនៅខាងក្រោយអ៊ីចឹង បន្ទាប់របងឫស្សីដែរ ។ ប៉ុន្តែ ចងដើមឈើមួយរួចមានរោងរានអ៊ីចឹង គាត់ក៏ធ្វើសកម្មភាពនុំងទៅ មិនមែនធ្វើក្នុងគុកទេ គឺធ្វើខាងក្រៅឫស្សីហ្នឹងពេលថ្ងៃ-- ពេលព្រឹក ច្រឡំពេលថ្ងៃ បាទពេលព្រឹក ។

**ស៖** លោកបានឆ្លើយសំណួររបស់ខាងសហព្រះរាជអាជ្ញា ថា ឌុច បានឃើញខ្ញុំ ពីព្រោះពេលហ្នឹង ខ្ញុំនៅក្បែរគាត់ ។ ខ្ញុំខាងចុងម្ខាងនៃតុ ។ នេះជាអ្វីដែលខ្ញុំបានឮពីការបកប្រែ ។ ឌុច បានឃើញខ្ញុំហ្នឹង ពីព្រោះខ្ញុំនៅខាងចុងម្ខាងនៃតុ ។ អ៊ីចឹង តើលោកអាចពន្យល់ប្រាប់តុលាការបានទេ តើតុហ្នឹងជាតុអ្វី?

**ឆ៖** តុហ្នឹងតុឈើ តុរៀបកូនឈើទេ អត់មានក្តារដូចយើងជំនាន់នុំង ប្រើតុឈើ រៀបកូនឈើ ។ តុបាយក៏កូនឈើ អាតុដែរអង្គុយលេងអ៊ីចឹងទៅក៏កូនឈើ ជាពិសេស កូនឈើប៉ុនៗកដៃទេ ។ សូមអស់។

**ស៖** អ៊ីចឹងមានន័យថា មានតុមួយនៅខាងក្រៅរបងគុកមែនទេ?

**ឆ៖** ពិតហើយ ។

**ស៖** អ៊ីចឹង តើនរណាគេខ្លះទៀត នៅអង្គុយ ឬក៏នៅក្បែរតុហ្នឹង? អ៊ីចឹង គឺលោក ឌុច, អ្នកទោស ហើយនិងលោក តើមាននរណាគេទៀតនៅក្បែរនុំង?

**ឆ៖** ពេលហ្នឹងអត់មានទេ ។ មានតែខ្ញុំមួយដែលអាចមកពីលុបមុខមក ប៉ុនមិនទាន់គាត់ឃើញ

គាត់ធ្វើអ៊ីចឹងទៅ ។ ខ្ញុំចេញមកលុបមុខហ្នឹង ខ្ញុំឃើញគាត់ធ្វើទារុណកម្មនារីនុ៎ងដុត ។ មានតែខ្ញុំមួយនៅអែបជិតគាត់ហ្នឹង ។ សូមអស់ ។

**ស៖** លោកអាចពន្យល់ជូនអង្គជំនុំជម្រះដែរឬទេ? ហេតុអ្វីបានលោកនៅទីនោះនៅពេលនុ៎ង? ខ្ញុំយល់ថា ឌុច គឺគាត់សួរចម្លើយអ្នកទោស តើហេតុអ្វីបានជាលោកនៅទីនោះនៅពេលនុ៎ង? ថាតើ ឌុច គាត់ហៅលោកឲ្យទៅឬក៏យ៉ាងម៉េច?

[១៤:២៩:១០]

**ឆ៖** បាទ ដូចខ្ញុំជម្រាបខាងដើមអ៊ីចឹង អត់មានហៅទៅទេ ខ្ញុំចេញទៅលុបមុខ ដល់ចេញទៅលុបមុខអ៊ីចឹងទៅ ខ្ញុំលាងជើងលាងដៃទម្រាំហើយ ចេញឃើញមក ឃើញគាត់ចងអ្នកទោសដុតបាត់ទៅហើយ ។ ខ្ញុំក៏អែបខាង ខ្ញុំឈរមើល ម៉ាសន្ទុះដែរ ។ ឈរមើលហ្នឹងចុងតុហ្នឹង ។ ឈរ ខ្ញុំអត់ហ៊ានឈរមើលយូរ ដល់ពេលឃើញអ៊ីចឹង ខ្ញុំក៏ដើរចេញទៅក្រៅគុកដើរទៅលើអ៊ីចឹង តាមស្ទឹងទៅលើទៅ ។ ខ្ញុំសូមអស់ ។

**ស៖** នៅពេលដែលលោកនិយាយថា នៅចុងតុ ថាតុហ្នឹងមានទំហំប៉ុនណាដែរ? សូមលោកស្មានមើល? គឺវាប៉ុនកន្លែងដែលលោកកំពុងអង្គុយហ្នឹងអត់ តុហ្នឹង?

[១៤:៣០:០០]

**ឆ៖** រាងបួនជ្រុងប៉ុនវែង ប្រហែលប៉ុណ្ណឹង ។ ប៉ុណ្ណឹងបាទ ប៉ុនវែងប្រហែលចំនួនប្រហែល ៥ ម៉ែត្រ ។ វែងណាស់តុឈើហ្នឹង សម្រាប់ទុកហូបបាយ កងការពារហូបបាយ ។ ប៉ុន្តែ កន្លែងហ្នឹងគេរើចោលហើយនៅតែតុទេ ទៅហូបបាយនៅកន្លែងថ្មីនុះលើនោះវិញ តុនោះទុកគ្រាន់គាត់សួរ ទារុណកម្មអ្នកទោសដែលដុតៗដោះដុតអីហ្នឹងកន្លែងហ្នឹង កន្លែងតុចាស់ហ្នឹងចំនួនប្រហែល៥ម៉ែត្រទេតុហ្នឹង ។

**ស៖** សហព្រះរាជអាជ្ញាបានសួរលោកព្រឹកមិញ ហើយគាត់អត់បានទទួលចម្លើយពីលោកថាតើ ឌុច បាននិយាយអ្វីខ្លះ ឬក៏គាត់ទទួលបានចម្លើយឯណាមួយ? ប្រសិនបើលោកនៅ ចុងតុ លោកប្រហែលជាស្ដាប់ឮសំណួរ ឌុច សួរនៅពេលនោះ ហើយនិងចម្លើយ ដែលអ្នកទោសឆ្លើយ ហើយគឺសុំឲ្យប្រាប់ថាតើលោកបានឮអ្វីខ្លះមិនត្រឹមតែលោកបានឃើញទេ ។ អ៊ីចឹងសាក្សី តើលោក បានឃើញបានឮអ្វីខ្លះក្នុងពេលព្រឹត្តិការណ៍មួយដែលលោកឈរមើលនៅទីនោះ?

**ឆ៖** ខ្ញុំឃើញអត់មានសួរអីទេ ឃើញតែដុតតែម្ដង ។ អត់មានឮសួរសម្ដីអីទេ ឃើញតែដុតអាប្រេងយើងមូលក្រណាត់ដុតតែម្ដង គឺដុតៗ ខ្ញុំឃើញអ៊ីចឹងអត់បានឮអីទេ ក៏ដើរចេញទៅ ខ្ញុំខ្លាចដែរ

ព្រោះឃើញអ៊ីចឹងហើយឈរមើលអត់មានអនុញ្ញាតក៏យើងពិបាកដែរ ។ អ៊ីចឹងហើយខ្ញុំក៏គេចខ្លួនចេញទៅ ឈរបានមួយសន្ទុះមើលបានគាត់ឃើញអ៊ីចឹង ។ សូមអស់ ។

**ស៖** បាទល្អ ។ លោកមិនបានឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញា និងសហមេធាវីទេដូច្នេះយើងអាចសន្និដ្ឋានទៅលើចំណុចនេះបាន ។ សំណួរចុងក្រោយប្រសិន បើលោកអនុគ្រោះដល់ខ្ញុំ ខ្ញុំសូមត្រឡប់ទៅលើព្រឹត្តិការណ៍ទាក់ទងទៅនឹងពូរបស់លោក សូមអភ័យទោស ដែលខ្ញុំលើកឡើងអំពីព្រឹត្តិការណ៍នេះឡើងវិញ ។ ប៉ុន្តែ លោកបានផ្តល់ព័ត៌មានសំខាន់ចំពោះសហព្រះរាជអាជ្ញាមុននឹងបន្តិច លោកបាននិយាយថា នៅពេលដែលគាត់បាញ់ពូរបស់ខ្ញុំ ខ្ញុំនៅក្បែរនោះ ខ្ញុំឮសំឡេងបាញ់កាំភ្លើង ហើយខ្ញុំឃើញពូរបស់ខ្ញុំដួលនៅលើដី ។ គឺខ្ញុំឱ្យលោកនឹកអារម្មណ៍ ចងចាំរបស់លោកវិញ តើលោកនៅកន្លែងណានៅពេលនុ៎ង? ថានៅក្នុងរបង ឬក៏នៅក្រៅរបង?

**ឆ៖** ពេលដែលខ្ញុំឮស្នូរកាំភ្លើងបាញ់ ខ្ញុំនៅក្រៅរបងគុក ។ ខ្ញុំជម្រាបថាខ្ញុំនៅខាងក្រៅ ។ ហើយអ្នកបាញ់ក៏បាញ់គងពីរបងគុកមកដែរ ។ ប៉ុន្តែ គេនៅក្រៅមួយចំហៀង ខ្ញុំនៅជ្រុងខាងកើត ។ ដល់អ៊ីចឹងបាញ់មួយគ្រាប់អ៊ីចឹងទៅ ត្រូវពីនេះមួយធ្លាយពីនេះ ហើយបាញ់រាងទទឹងមួយគ្រាប់ទៀតចំដើមទ្រូងគាត់ដួលមកដីតែម្តង ។ បាញ់ចំមួយគ្រាប់ទៀតជាប់បង្កោល នឹងពូខ្ញុំ សយ ឃើញពិតនឹងភ្នែកខ្ញុំ ។

[១៤:៣៤:១៥]

**ស៖** ប្រសិនបើខ្ញុំយល់ត្រឹមត្រូវ គឺលោកនៅក្រៅរបង ប៉ុន្តែការបាញ់សម្លាប់នោះគឺកើតនៅក្នុងរបង តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ ។

**ស៖** ដូច្នេះ នៅពេលដែលលោកឃើញពូរបស់លោកដួលលើដី គឺលោកដើរចូលតាមផ្លូវចូលនៃរបង ឬក៏យ៉ាងម៉េច? អ៊ីចឹង លោកបានឮហ្នឹងគឺលោកដើរចូលរបងឬក៏យ៉ាងម៉េច? ថាតើវាកើតឡើងយ៉ាងម៉េចនៅពេលដែលលោកឮគ្រាប់នោះ?

**ឆ៖** ដល់តែឃើញអ៊ីចឹង ខ្ញុំអត់ហ៊ានដើរចូលក្នុងទេ កាលណាឃើញទៅ ឃើញពូនៅនេះខ្លាចបែកការថាបងប្អូន ។ អ៊ីចឹង ខ្ញុំតាំងពីយកគាត់ដាក់គុកមក ខ្ញុំអត់មានប្រាប់ថាពូខ្ញុំអីទេ អត់ហ៊ានទេ ដល់ឃើញអ៊ីចឹងខ្ញុំដើរគេច គេចពីមុខគាត់បាត់ អត់ឱ្យគាត់ដឹងផងទេ ។ គ្រាន់តែឈរមើលម្នាងដែលគាត់បាញ់ខ្ញុំក៏ដើរចេញពីមុខគាត់បាត់ មករោងបាយខាងលើនេះ លើស្ទឹងខាងគុកនេះវិញអត់បាននៅជិតនោះទេ។ ឃើញពូស្លាប់ហើយខ្ញុំដើរចេញ ។

**សៈ** ខ្ញុំយល់ ។ ដូច្នេះ យើងយល់ស្របថា គឺដំបូងលោកឮសំឡេងកាំភ្លើង ហើយបន្ទាប់សំឡេងកាំភ្លើង គឺលោកឃើញពូរបស់លោកដួលលើដី តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ពិតជាត្រឹមត្រូវ ។

**សៈ** ហើយលោកមើលតាមរយៈរបង ឬយ៉ាងម៉េចថាលោកអាចឃើញពូរបស់លោកដួលតាមរបង ឬយ៉ាងម៉េច? ដោយសារតែលោកនៅក្រៅរបង សូមលោកបញ្ជាក់ទៅលើចំណុចហ្នឹង?

**ឆៈ** ចំណុចនោះរបងឬស្សីអត់ជិតដូចជញ្ជាំងក្តារ ប្រហោងក្រហូងៗយើងអាចមើលឃើញអ្នកទោសបាន មើលឃើញគ្នាទៅវិញទៅមក ។ ព្រោះធម្មតាឬស្សីតែយើងខ្ទាស់ទៅអត់មានជិតដូចជញ្ជាំងក្តារទេ មើលឃើញតាមចិត្ត។ ចេញ ណាចេញណាចូលអីក្នុងហ្នឹងដឹងទាំងអស់ ។ សូមអស់។

**សៈ** ដូច្នេះ អ្វីដែលលោកឃើញគឺលោកឃើញពូរបស់លោកដួលនៅលើដី តើត្រឹមត្រូវដែរឬទេ?

**ឆៈ** ពិតជាត្រឹមត្រូវ ។

**សៈ** ដូច្នេះ លោកសាក្សី លោកអត់បានឃើញនរណាជាអ្នកបាញ់ទេមែនទេ?

[១៤:៣៧:៤៣]

**ឆៈ** អត់ទេ ឃើញតា ឌុច បាញ់ផ្ទាល់ដៃគាត់តែម្តង ឮសួរទៅឃើញតា ឌុច កាន់កាំភ្លើងតែម្តង។ សូមអស់ ។

**សៈ** អរគុណលោកសាក្សី ។ ដូច្នេះ តុលាការនឹងធ្វើការទាញសេចក្តីសន្និដ្ឋានទៅតាមការពិត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្សង់ ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ ម៉ាកឡាវែន៍៖**

**សៈ** ខ្ញុំចង់សួរសំណួរទៅកាន់ជនជាប់ចោទ ។ នៅក្នុងសវនាការមុនៗ ជនជាប់ចោទបានលើកឡើងអំពីអ្នកទោសមួយចំនួនដែលបានលែងពីម-១៣ ។ ថាជនជាប់ចោទអាចប្រាប់យើងដែរឬទេ ថាអ្នកទោសទាំងអស់ដែលជនជាប់ចោទបានលើកឡើងថា ត្រូវបានដោះលែងនោះរួមទាំងលោក ចាន់ វឿន ផងដែរ ឬក៏យ៉ាងម៉េច?

**ជនជាប់ចោទ៖**

**ឆៈ** លោកចៅក្រមជាទីគោរព! នៅខាងដើមៗនេះ ខ្ញុំបាននិយាយអំពីខ្ញុំដោះលែងមនុស្ស១០

នាក់ ។ ក្នុងចំណោម ១០នាក់នេះគ្មានឈ្មោះ ចាន់ វឿន ទេ ហើយសូមបញ្ជាក់ម្ដងទៀត ចាន់ វឿន នេះ មិនមែន ជាកងការពារ ហើយក៏មិនមែនជាអ្នកទោសដែលទៅជាប់នៅទីនោះឲ្យខ្ញុំដោះលែងទេ ។

**ស៖** តើលោកឆ្លើយឲ្យច្បាស់បានដែរឬទេ? នៅក្នុងសវនាការមុនៗ លោកបានលើកឡើងឈ្មោះ ចាន់ វឿន លោកបាននិយាយថា សាក្សី KW-31 ត្រូវបានដោះលែង ក្រោយពីមានសេចក្ដីសម្រេចពីលោក?

**ឆ៖** ខ្ញុំបានជម្រាបអង្គសវនាការពីកាលលើកមុនថាខ្ញុំបានដោះលែង បងសុង ដែលមានឈ្មោះសម្ងាត់ថាKW-30 ។ ឯចំណែក KW-31 ខ្ញុំមិនដែលបាននិយាយចំទេ ។ ខ្ញុំនិយាយ KW-32 ទៅទៀតគឺពិតជាបុគ្គលិករបស់ខ្ញុំ ។ ហើយសូមបញ្ជាក់លោកចៅក្រមថែម ខ្ញុំច្រឡំ KW-30 ទៅជាមួយជនរងគ្រោះឈ្មោះ ស៊ិន ដែលមកធ្វើសក្ខីកម្មនៅទីនេះរួចទៅហើយ ។ ជនរងគ្រោះដែលខ្ញុំដោះលែងនោះមិនមានឈ្មោះ ស៊ិន ទេ ឈ្មោះ សុង នៅភូមិស្នួលដូចគ្នា ។

**ស៖** ចា ឌុច អាចប្រាប់ដែរឬទេ មុនពេលសវនាការថ្ងៃនេះគឺលោកជនជាប់ចោទធ្លាប់ឃើញសាក្សីនេះ ឬក៏លោកមិនដែលឃើញសាក្សីនេះទេ?

**ឆ៖** ខ្ញុំជួបមុខ ចាន់ វឿន នេះតែនៅពេលនេះឯង ចាប់ផ្ដើមជួបនៅពេលនេះឯង ។

**ប្រធានអង្គជំនុំ៖**

ចាន់ វឿន, ឥឡូវវត្តមានរបស់លោកលែងមានសារសំខាន់ទៀតហើយ ពីព្រោះអង្គសវនាការអស់សំណួរសួរលោកហើយ ។ អ៊ីចឹងលោកអាចត្រឡប់ទៅលំនៅដ្ឋាន ឬក៏ទៅគោលដៅណាដែលលោកចង់ទៅបានហើយ ។ ហើយមន្ត្រីតុលាការសូមរៀបចំគាត់ ដើម្បីអញ្ជើញគាត់ត្រឡប់ទៅវិញ ទៅប្រាស្រ័យទាក់ទងនឹងខាងអង្គភាព *WESU* ដើម្បីសម្រួលគាត់បានត្រឡប់ទៅផ្ទះវិញ ។ ដោយពេលសម្រាកអង្គជំនុំជម្រះ ប្រកាសសម្រាកម្ភៃនាទី រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង១៤:៤៣នាទី ដល់ម៉ោង ១៥:០៥ នាទី]*

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញអង្គុយចុះ!

**សួរដោយប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសបន្តដំណើរការនីតិវិធីសវនាការតទៅទៀត ។

ហើយជាកិច្ចបន្ទាប់នេះ ដល់ពេលត្រូវស្តាប់ចម្លើយ សក្ខីកម្មរបស់សាក្សី ចាន់ ខន ។

មន្ត្រីតុលាការសូមអញ្ជើញ សាក្សី ចាន់ ខន ចូលមកកាន់បន្ទប់សវនាការ ។

*(សាក្សីចូលមកកាន់បន្ទប់សវនាការ)*

**ស៖** សាក្សី លោកឈ្មោះ ចាន់ ខន អ៊ីចឹងមែនទេ?

**សាក្សី KW-32៖**

**ឆ៖** បាទ ។

**ស៖** ចាន់ ខន ឥឡូវនេះ ដល់ឆ្នាំនេះអាយុប៉ុន្មានហើយ?

**ឆ៖** *(មិនច្បាស់)* ។

**ស៖** បច្ចុប្បន្ននេះ លោកមានទីលំនៅ នៅកន្លែងណាដែរ នៅភូមិឃុំណា?

**ឆ៖** ភូមិទេពភិរម្យ ឃុំវាលពន់ ស្រុកថ្គង ខេត្តកំពង់ស្ពឺ ។

**ស៖** បច្ចុប្បន្ននេះ លោកមានមុខរបររកស៊ី ធ្វើអ្វីដែរ?

**ឆ៖** ធ្វើស្រែ ។

**ស៖** យោងតាមរបាយការណ៍ ក្រឡាបញ្ជីសវនាការ ថាលោកមិនមានចំណងញាតិ លោហិត ឬញាតិព័ន្ធ ឬក៏ជាសហព័ទ្ធជាមួយនឹងភាគីនៅក្នុងរឿងនេះទេ ជាការពិតទេ?

**ឆ៖** អានសំណួរមួយលើកទៀត ស្តាប់អត់សូវបាន ។

**ស៖** តាមរបាយការណ៍របស់ក្រឡាបញ្ជី បានរាយការណ៍ថា លោក ចាន់ ខន ឯងហ្នឹង មិនមានជាប់ជាញាតិបងប្អូន ឬក៏បងប្អូនសាច់ថ្លៃ ឬក៏ជាចំណងសហព័ទ្ធជាមួយនឹងភាគី នៅក្នុងរឿង ក្តីនេះទេ រឿងនេះជាការពិតទេ?

[១៥:០៩:០១]

**ឆ៖** ពិត ។

**ស៖** នៅក្នុងពេលនេះ អង្គជម្រះបានអញ្ជើញលោកមកធ្វើជាសាក្សី នៅក្នុងរឿងក្តីនេះ ដោយតម្រូវឲ្យលោកស្បថជាមុន មុននឹងធ្វើសក្ខីកម្ម តើលោកបានស្បថរួចហើយឬនៅ?

**ឆ៖** ស្បថហើយៗ ។

**ស៖** នៅក្នុងសវនាការនេះ អង្គជំនុំជម្រះសាលាដំបូង បានកោះអញ្ជើញលោក ឲ្យចូលមកនេះ ដើម្បីចង់ស្ដាប់ លោកនិយាយអំពីរឿងហេតុទាំងឡាយ ដែលលោកបានដឹង បានឮ បានឃើញនៅមន្ទីរសន្ដិសុខម-១៣ ឋិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ដែលមានក្នុងអំឡុងពេលឆ្នាំ១៩៧១ រហូតដល់ឆ្នាំ១៩៧៥ ។ នេះជាអ្វីដែលលោកអាចនិយាយប្រាប់ដល់អង្គជំនុំជម្រះអំពីបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធជាមួយនឹងមន្ទីរនោះ ។ លោកដឹងហើយណ៎ា ។ តើលោកស្គាល់មន្ទីរសន្ដិសុខម-១៣ ដែរឬទេ?

**ឆ៖** បានស្គាល់នៅក្នុងឆ្នាំ១៩៧៣ ។

**ស៖** ហើយមូលហេតុអីទៅនាំឲ្យលោក បានទៅស្គាល់មន្ទីរសន្ដិសុខម-១៣ នៅក្នុងឆ្នាំ១៩៧៣ នោះ?

**ឆ៖** ដំបូងមក មេភូមិថាឲ្យខ្ញុំទៅធ្វើយោធា ដល់ពេលបញ្ជូនខ្ញុំមក បញ្ជូនមកមន្ទីរ-១៣ហ្នឹង ។

**ស៖** ហើយពេលដែលលោកទៅដល់មន្ទីរ-១៣ហ្នឹង គេឲ្យលោកធ្វើកិច្ចការអីទៅ?

**ឆ៖** មកដល់មន្ទីរ-១៣ហ្នឹង គេឲ្យខ្ញុំយាម ។

**ស៖** ឥឡូវនេះ មុននឹងចូលដល់សំណួរដែលមានការពាក់ព័ន្ធទៅនឹងរឿងហេតុពិតប្រាកដហ្នឹង អង្គជំនុំជម្រះគ្រាន់តែប្រាប់ រំឮកឡើងវិញអំពីសិទ្ធិរបស់លោកជាសាក្សី លោកអាចបដិសេធក្នុងការឆ្លើយនឹងសំណួរ ឬអំណះអំណាងណាមួយដែលនាំឲ្យដាក់ពិរុទ្ធភាពទៅលើខ្លួនឯង ។ ប៉ុន្តែ លោកអាចឆ្លើយនូវអ្វីដែលលោកបានដឹង បានឮ បានឃើញ ក្រៅពីអ្វី ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯងណ៎ា ។

លោកអាចរៀបរាប់អំពី ទិដ្ឋភាព ឬក៏ហេតុការណ៍ទាំងឡាយ ដែលលោកបានដឹង បានឃើញ បានឮនៅក្នុងអំឡុងពេល ដែលលោកបានចូលទៅដល់ ទៅធ្វើការ ជាកងការពារនៅក្នុងមន្ទីរម-១៣នោះ រហូតដល់ពេលដែលលោកត្រូវបានចាកចេញពីទីនោះត្រឡប់ទៅមូលដ្ឋាន ទៅលំនៅដ្ឋានរបស់លោកវិញ។ តើលោកអាចនិយាយអ្វី ដែលលោកចងចាំប្រាប់ដល់អង្គសវនាការបានដែរឬទេ?

**ឆ៖** វែងពេកហើយ ស្ដាប់អត់ទាន់អស់ ។

**ស៖** ម្ដងទៀតគឺ ឥឡូវនេះ គោលបំណងនៃការកោះហៅលោកមក គឺចង់ដឹងថា លោកបានដឹង បានឮ បានឃើញ នូវអ្វីខ្លះដែលកើតឡើងនៅក្នុងមន្ទីរសន្ដិសុខម-១៣ ឋិតនៅអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ កាលពីលោកចូលទៅធ្វើការនៅទីនោះ នូវអ្វីដែលលោកចងចាំ តើលោកអាចនិយាយនិទានរឿងហ្នឹងឲ្យអង្គសវនាការស្ដាប់បានដែរឬទេ?

**ឆ៖** ទៅដល់ដំបូងគឺមានឃើញតែអ្នកទោស ។ គឺខ្ញុំបានចូលទៅនៅក្នុងឆ្នាំ១៩៧៣ ឃើញមាន

តែអ្នកទោសនៅក្នុងហ្នឹង ។ អ៊ីចឹង គឺខ្ញុំមានភារកិច្ចជាអ្នកយាម តែដល់ពេលឆ្នាំ១៩៧៤មក គឺដោយការគោរពការចាត់តាំងពីថ្នាក់លើមិនបានត្រឹមត្រូវ ក៏ខ្ញុំត្រូវចាកចេញទៅនៅអូព្រាល ខាងលិចត្រពាំងត្រែង ជាអ្នកធ្វើស្រែចម្ការ លើកទំនប់អីជាធម្មតា រហូតដល់ថ្ងៃរំដោះ១៧ មេសា ទើបខ្ញុំមកនៅកងចល័តនៅឧដុង្គ ។

**ស៖** លោករកនឹកឡើងវិញមើល តើពេលដែលលោកចូលទៅដល់ទីនោះធ្វើកងការពារ រហូតដល់លោកចេញវិញ ទៅធ្វើស្រែ ទៅធ្វើនូវការងារនៅកន្លែងផ្សេងទៀតហ្នឹង រយៈពេលប៉ុន្មានទៅ ចាប់ពីលោកទៅ ហើយលោកចាកចេញពីទីនោះ?

**ឆ៖** ទៅក្នុងឆ្នាំ១៩៧៣ ហ្នឹង ដល់ជិតដាច់ឆ្នាំ១៩៧៣ ចូល ១៩៧៤ ខ្ញុំទៅធ្វើស្រែតែម្តង ។

**ស៖** លោកស្គាល់អ្នកណាជាប្រធានមន្ទីរសន្តិសុខម-១៣ទេ កាលណោះគាត់ឈ្មោះអីទៅ?

លោកចាំទេកាលណោះ។ ម្តងទៀតណ៎ះ! ដោយសារមិនមានការបកប្រែ ហើយមិនបានកត់ត្រានៅក្នុងប្រតិចារឹក ។ យើងតាំងសំណួរម្តងទៀតថា ពេលដែលលោកចូលទៅ ធ្វើការនៅក្នុងមន្ទីរសន្តិសុខម-១៣ ហើយនិងចេញទៅធ្វើស្រែវិញ តើអស់រយៈពេលប៉ុន្មាន?

**ឆ៖** ខ្ញុំទៅរស់នៅហ្នឹងឆ្នាំ១៩៧៣ តែដល់ចេញវិញមិនដឹងខែប៉ុន្មានអី ឆ្នាំខែប៉ុន្មានទេ តែជិតដាច់ ១៩៧៣ ហើយ ។

**ស៖** កាលនោះលោកស្គាល់ថាអ្នកណាដែលប្រធានមន្ទីរសន្តិសុខ ម-១៣ នោះដែរឬទេ?

**ឆ៖** ឈ្មោះ តាឌុច ។

**ស៖** ក្រៅពី ឌុច មានអ្នកបន្ទាប់បន្តបន្ទាប់ លំដាប់ក្រោមៗគាត់មកទៀតទេ មានប៉ុន្មាននាក់? លោកស្គាល់ទេ?

**ឆ៖** ខ្ញុំអត់ចាំបានច្បាស់ផង នៅតូចពេក ។

**ប្រធានអង្គជំនុំ៖**

លោក អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់សាក្សីរូបនេះទៀតដែរឬទេ? បើមានសូមអញ្ជើញ ។

សូមអញ្ជើញលោក ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ស៖ ជាបឋម សូមជនជាប់ចោទអញ្ជើញក្រោកឈរ តើសាក្សីអាចឃើញជនជាប់ចោទ តើ

លោកស្គាល់គាត់ទេ? តើលោកស្គាល់ជនជាប់ចោទទេសាក្សី?

**សាក្សី KW-32៖**

**ឆ៖** ស្គាល់គាត់ តែគាត់រៀងចាស់ហើយ ពីមុនក្មេង ។

**ស៖** តើ ឌុច អាចប្រាប់យើងបានទេ តើលោកចាំឈ្មោះសាក្សី ចាំមុខសាក្សីនេះទេ?

**ជនជាប់ចោទ៖**

**ឆ៖** គឺពិតជាបុគ្គលិករបស់មន្ទីរ-១៣ ។

**ស៖** លោកបានពន្យល់ដល់យើងថា លោកបានទៅដល់ ម-១៣ ក្រោយពីមេភូមិ ប្រាប់ឲ្យលោកទៅធ្វើជាយោធា តើគេប្រាប់ឲ្យធ្វើការងារអ្វីទេ? ដែលថាទៅគេចាត់តាំងឲ្យទៅម-១៣ នោះ គេប្រាប់ថាឲ្យធ្វើអីខ្លះ? តើគេពន្យល់ពីការងារថាឲ្យធ្វើការងារអ្វីទេនៅម-១៣ នោះ?

[១៥:១៩:២០]

**សាក្សី KW-៣២៖**

**ឆ៖** ពេលខ្ញុំទៅដល់ដំបូងហ្នឹង គឺបានពីរ បីថ្ងៃគាត់ឲ្យខ្ញុំយាមកាមធម្មតាហ្នឹងទៅ ។

**ស៖** នៅពេលដែលលោកចាកចេញពីម-១៣ តើ ម-១៣ នោះ ពេលដែលលោកនៅទីនោះ មានន័យថាម៉េច? ជាកន្លែងដែលគេដាក់អ្នកទោស ឃុំឃាំងអ្នកទោស ឬក៏កន្លែងអ្វី កន្លែងហ្នឹង?

**ឆ៖** កន្លែងខ្ញុំទៅដំបូងហ្នឹង គឺកន្លែងទៅដល់កន្លែងគេឃុំឃាំងអ្នកទោស ។

**ស៖** នៅពេលដែលចូលទៅដល់ម-១៣ ភ្លាម តើមានអ្វីដែលលោកឃើញថាសំខាន់សម្រាប់រូបលោកទេ? ថាតើគេចាត់តាំងឲ្យធ្វើការងារហ្នឹង លោកទទួលស្គាល់ថាលោកមានឋានៈ ជាអ្វីទេនៅកន្លែងនោះ? ឬក៏ជាការដំឡូងសក្តិអ្វីនៅពេលនោះៗ?

**ឆ៖** អត់, ជាកងការពារធម្មតា ជាបុគ្គលិកធម្មតាសម្រាប់តែគាត់ប្រើហ្នឹង ។ អត់មានឋានន្តរសក្តិអ្វីទេ ។

**ស៖** តើគេប្រាប់លោកឲ្យចូលរួមនៅក្នុងបដិវត្តន៍ ហើយនឹងត្រូវធ្វើអ្វីសម្រាប់ប្រទេសអ្នកឯង ឬក៏ តើគេប្រាប់ឲ្យលោកធ្វើអ្វីខ្លះនៅពេលហ្នឹងនោះ?

**ឆ៖** អត់មានប្រាប់ម៉េចផង ។ គាត់ប្រាប់ថា ឲ្យទៅយាមកាមអ្នកទោសហ្នឹងទៅ ។

**ស៖** តើលោកអាយុប៉ុន្មាននៅពេលដែលទៅដល់មន្ទីរម-១៣ នោះ?

**ឆ៖** អាយុខ្ញុំមិនសូវចាំបានច្បាស់ដែរ បើគិតជាអាយុប្រហែលជាបើមិន១៣, ១៤ តែប៉ុណ្ណឹង ។

**ស៖** តើលោកទទួលការបណ្តុះបណ្តាលឲ្យធ្វើការងារអ្វីដែរឬទេ?

**ឆ៖** អត់ គាត់អត់ដែលណែនាំបណ្តុះបណ្តាលអីផង ។

**ស៖** តើលោកអាចរៀបរាប់ប្រាប់យើងឲ្យជាក់ស្តែងបានទេ តើគេរៀបចំមន្ទីរម-១៣ នោះដូចម្តេច? គេដំណើរការម៉េច? តើគេឃុំខ្លួនអ្នកទោសដូចម្តេច? ថាតើអ្នកយាមធ្វើអីខ្លះ? នៅកន្លែងណាខ្លះ?

[១៥:២៣:០៥]

**ឆ៖** អ្នកកងការពារហ្នឹង មានសិទ្ធិតែយាមកាម ហើយបើសិនជាអ្នកទោសរត់រួច ឈ្មោះ "ក" យាមត្រូវទទួលខុសត្រូវទៅ ។ បើសិនឈ្មោះ "ខ" យាមហ្នឹងរួច អ្នកទោសអ្នកហ្នឹងទទួលខុសត្រូវទៅ ។ និងការណែនាំរបស់ថ្នាក់លើមានតែប៉ុណ្ណឹង គឺសំខាន់កុំឲ្យអ្នកទោសរត់រួច ដែលខ្លួនឯងមានតួនាទីអ្នកយាម ។

**ស៖** តើលោកមានកាន់អាវុធដែរឬទេ?

**ឆ៖** អ្នកយាមត្រូវតែកាន់អាវុធ ។

**ស៖** តើកាំភ្លើង ឬអាវុធប្រភេទណាដែលលោកកាន់? តើគេបង្រៀនលោកវិធីប្រើអាវុធនោះដែរឬទេ?

**ឆ៖** ប្រើអាវុធទាល់តែមានគេបង្ហាត់បង្រៀន បើអត់ដែលស្គាល់តាំងពីកើតមក អត់ដែលស្គាល់អាវុធផង ។ ទៅដល់ហ្នឹងគេអ្នកនៅមុនៗហ្នឹង បងៗហ្នឹង គេបង្ហាត់យើង ឲ្យចេះប្រើអាវុធហ្នឹងទៅ ។

**ស៖** តើជាអាវុធវែង ឬក៏ជាអាវុធអាកា ឬក៏ជាអាវុធខ្លី រ៉ឺវុលវ៉ែ តើប្រភេទអីដែលលោកកាន់នោះ?

**ឆ៖** កាំភ្លើងអាកា ។

**ស៖** តើមានអ្នកយាមប៉ុន្មាននាក់នៅទីនោះ?

**ឆ៖** អ្នកយាមប្រហែលពី១០នាក់ ទៅ ២០នាក់ ។

**ស៖** តើអ្នកយាមក្មេងជាងគេអាយុប៉ុន្មាន? ថាតើអាយុមធ្យមរបស់អ្នកយាមទាំងនោះប្រហែលប៉ុន្មានដែរ?

**ឆ៖** ក្តាប់មិនសូវបានដែរ ច្រើនគ្នាពេក ។ មិនដឹងជាប៉ុន្មាននាក់ ដែលមានអាយុប៉ុណ្ណឹងក៏អត់--ឥឡូវវាភ្លេចអស់ទៀត ។ មិនដឹងណានៅឯណាផង ។

**ស៖** តើលោកជាអ្នកយាមមានអាយុក្មេងជាងគេបំផុត ឬក៏មានអ្នកយាមណាអាយុតិចជាងលោកនៅពេលនោះ?

**ឆ៖** ក្លាប់អត់បានផង បើឃើញប៉ុនៗហ្នឹងវាច្រើនគ្នាដែរ ។

[១៥:២៦:២៧]

**ស៖** នៅពេលដែលលោកទៅដល់កន្លែងនោះ តើគេប្រាប់លោកថា ហេតុអីដែលត្រូវរក្សាទុកយាមអ្នកនោះ អ្នកទោសទាំងនោះ តើមូលហេតុអីបានជាគេដាក់អ្នកទោស ដើម្បីបដិវត្តន៍ តើគេប្រាប់ដូចម្ដេច ថាឲ្យយាមអ្នកទោសកុំឲ្យរត់រួចហ្នឹង មូលហេតុអី?

**ឆ៖** ព្រោះគេឲ្យយាមមិនឲ្យរត់រួចហ្នឹង គឺអ្នកទោសហ្នឹងគេចាប់មកពីមូលដ្ឋានមក មិនដឹងជាទោសស្អីៗ ខ្ញុំមិនដឹងដែរ ។ ប៉ុន្តែ មកដល់កន្លែងយាម គឺមេថ្នាក់ដឹកនាំហ្នឹង គាត់ថាមិនឲ្យរត់រួចទេ អ្នកណាអ្នកយាមត្រូវទទួលខុសត្រូវខ្លួនឯង ។

**ស៖** តើគេប្រាប់លោកអំពីមូលហេតុនៃការឃុំខ្លួនអ្នកទោសហ្នឹងទេ? តើលោកបានដឹងពីមូលហេតុ នៃការឃុំខ្លួនអ្នកទោសទាំងហ្នឹងទេ? តើគេប្រាប់លោកថា អ្នកទាំងហ្នឹង ជាសត្រូវ ជាខ្មាំង ឬក៏យ៉ាងម៉េច?

**ឆ៖** ពេលគេចាប់ពីមូលដ្ឋានមកភាគច្រើនគឺគេថា ជនក្បត់ គិញ ឬមួយសីលធម៌ ក្បត់វិន័យផ្សេងៗទៀត ។

**ស៖** តើលោកជឿទេថា អ្នកទោសទាំងអស់ហ្នឹងសុទ្ធតែជាជនក្បត់ ឬក៏ជាអ្នកមាន ខុសសីលធម៌ ឬក៏សុទ្ធតែជាគិញ តើលោកជឿថាអ៊ីចឹងទេពេលហ្នឹងនោះ?

**ឆ៖** អត់ជឿផង។ បើវាមកអ៊ីចឹង ខ្លះត្រូវជាសាច់ញាតិជីដូនជីតាអ៊ីចឹង ឃើញគាត់អត់ធ្វើអីផង។

**ស៖** តើលោកបានដឹងថា ចំនួនអ្នកទោស អ្នកដែលគេឃុំខ្លួនហ្នឹង ជាមធ្យមមានប៉ុន្មាន? គឺជាចំនួនដដែល ឬក៏ចំនួនហ្នឹងប្រែប្រួល ថាតើមានរណ្ដៅសម្រាប់ឃុំ តើមានចំនួនប៉ុន្មាន ជាមធ្យម ឬក៏លោកដឹង?

**ឆ៖** ពេលខ្ញុំទៅដល់ហ្នឹង ឃើញមានរណ្ដៅដាក់អ្នកទោសប្រហែលជា២ ឬ ៣ ។ ក្នុង រណ្ដៅមានក្រាលក្ដារ លើរណ្ដៅមានប្រក់ស្លឹក ហើយដាក់អ្នកទោសនៅក្នុងហ្នឹង ។

**ស៖** រណ្ដៅទាំងនោះ តើរណ្ដៅទាំងនោះទំហំប៉ុនៗគ្នាឬក៏យ៉ាងដូចម្ដេច?

**ឆ៖** មានតូច មានធំ ។

**ស៖** តើមានអ្នកទោសប៉ុន្មាន ដែលគេឃុំខ្លួននៅក្នុងរណ្តៅដែលធំជាងគេនោះ លោកអាចនៅចាំបានទេ?

**ឆ៖** ក្តាប់អត់បានផង ភ្លេចអស់ហើយ ។

**ស៖** តើមានអ្នកទោសស្ត្រី បុរស តើមានកុមារដែរឬទេក្នុងចំណោមអ្នកទោសទាំងហ្នឹង?

**ឆ៖** អត់ទេ មានតែចាស់ៗ ។ បើស្រីមាន ។

**ស៖** អ្នកទោសស្រីដែលមានមកនោះ មានកុមារមកជាមួយឬក៏មកតែអ្នកទោសស្រីទេ?

**ឆ៖** មកតែអ្នកទោសស្រីទេ ។

**ស៖** ខ្ញុំអត់យល់ចម្លើយទេ ។ គឺថាតើអ្នកទោសស្ត្រីទាំងអស់នោះមានយកក្មេងទៅជាមួយដែរឬទេ?

**ឆ៖** អត់ ។

**ស៖** ថាអ្នកពីអមលាំង ឬក៏មកពីទីកន្លែងផ្សេងៗ ថាតើមានទាហានក្នុងចំណោមអ្នកទោសដែរឬទេ? ថាតើអ្នកទោសជាប្រភេទយ៉ាងម៉េច? ដូចជាអ្នកទោសបរទេសដែរឬទេ?

**ឆ៖** អ្នកទោសមានច្រើនប្រភេទ មានទាហាន លន់ នល់ ទាហានខ្មែរក្រហម និងជនស៊ីវិល ។

**ស៖** ដូច្នេះ អ្នកទោសនោះគឺ ជាទាហាន លន់ នល់ ហើយមានទាហានខ្មែរក្រហមផងដែរ ។ នេះគឺជាអ្វីដែលលោកនិយាយជម្រាបយើងខ្ញុំ ឬយ៉ាងម៉េច?

**ឆ៖** ព្រោះអ្នកទោសថាខ្លួនគេ ។

**ស៖** លោកដឹងទេ ហេតុអ្វីបានជាទាហានខ្មែរក្រហមត្រូវបានឃុំខ្លួននៅទីនោះ?

**ឆ៖** អត់ដឹងរឿងកំហុសអីផង ។

**ស៖** ថាតើមានអ្នកទោសបរទេសដែរឬទេនៅក្នុងគុកនុ៎ង ។

**ឆ៖** អត់ ។

**ស៖** ថាតើអ្នកទោសទាំងអស់នោះគាត់ស្ថិតនៅក្នុងស្ថានភាពដូចគ្នា អ្នកផ្សេងត្រូវបានគេចោទប្រកាន់ពីការទណ្ឌកម្មធ្ងន់ធ្ងរ ឬក៏ការងារស្រាលដែរឬទេ? ថាតើរងការចោទប្រកាន់អ្វីខ្លះ?

**ឆ៖** អត់ដឹងផង ។ ឃើញអ្នកទោសហ្នឹង ដឹងអ្នកណាទោសធ្ងន់អ្នកណាទោសស្រាល ។

**ស៖** លោកបានឃើញអ្នកទោសដែលត្រូវបានគេអនុញ្ញាតឲ្យធ្វើការនៅពេលថ្ងៃដែរឬទេ?

**ឆ៖** ដែល ។

**ស៖** ថាតើមានអ្នកទោសច្រើន ឬក៏ចំនួនអ្នកទោសក្នុងចំនួនតូចទេ ដែលគេឲ្យទៅធ្វើការនោះ?

**ឆ៖** ចំនួនតិច ។

**ស៖** ថាតើអ្នកទោសគាត់មានអាហារគ្រប់គ្រាន់ហូបដែរឬទេ ឬក៏មានបញ្ហាអ្វីដែលពាក់ព័ន្ធនឹងអ្នកទោស?

**ឆ៖** អាហារហូបអត់គ្រប់គ្រាន់ទេ ។

**ស៖** លោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាលោកធ្លាប់ឃើញអ្នកទោសស្លាប់ដោយសារអត់ឃ្លាន?

**ឆ៖** អានសំណួរម្តងទៀត ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាលោកបានឃើញអ្នកទោសស្លាប់ ដោយសារតែអ្នកអ្នកទោសអត់មានអាហារគ្រប់គ្រាន់ហូប?

**ឆ៖** អ្នកទោសភាគច្រើនស្លាប់ ដោយការអត់អាហារហូបជាច្រើន ។

**ស៖** ថាតើអ្នកទោសស្លាប់រាល់ថ្ងៃ ឬយ៉ាងម៉េច?

**ឆ៖** អត់ទេ ជួនកាលមានថ្ងៃស្លាប់ទៅ ជួនកាលមានថ្ងៃអត់អ៊ីចឹងដែរ ។

**ស៖** លោកចាំទេ ថាមានថ្ងៃមួយគឺមានអ្នកទោសច្រើនណាស់ដែលបានស្លាប់ លោកបានចាំទេថាមានថ្ងៃមួយនោះគឺមានអ្នកទោសច្រើនណាស់ស្លាប់?

**ឆ៖** អត់ អត់ដឹងផង ។ ខ្ញុំចេញបាត់មិនដឹង បើខ្ញុំនៅអត់ដែលឃើញស្លាប់ច្រើនផង ។

**ស៖** លោកអាចរៀបរាប់ជូនយើងខ្ញុំអំពីស្ថានភាពដែលអ្នកទោសត្រូវបានគេយកដាក់ទៅក្នុងរណ្តៅ ថាតើអ្នកទោសត្រូវបានគេដាក់ខ្នោះនៅកជើង ឬក៏ត្រូវបានគេដាក់ខ្នោះដែរឬទេ?

**ឆ៖** គេដាក់ខ្នោះជើង ។

**ស៖** ថាតើអ្នកទោសអនុញ្ញាតឲ្យទៅទន្លេ ទៅងូតទឹកដែរឬទេ?

**ឆ៖** អ្នកទោសមានទៅមុជទឹករាល់ថ្ងៃ នៅពេលថ្ងៃល្ងាច ។

**ស៖** ថាតើអ្នកទោសនោះត្រូវបានគេដោះខ្នោះ ឬក៏គេដាក់ខ្នោះដដែល? ហើយថាករបស់គេមានដាក់ខ្នោះដែរឬទេ?

[១៥:៤០:៣៩]

**ឆ៖** ពេលទៅមុជទឹកអត់ដាក់អីផង ។ បើសិនជាទៅច្រើនអាហ្នឹងមានដាក់ខ្លះ ។

**ស៖** លោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាលោកឃើញអ្នកទោសឈឺ?

**ឆ៖** អ្នកទោសឈឺច្រើនដែរ ព្រោះការផ្តល់ថ្នាំពេទ្យ ឬមួយក៏អាហារវាអត់គ្រប់គ្រាន់ ។

**ស៖** ថាតើមានការថែទាំផ្នែកសុខភាពដល់អ្នកទោសដែរឬទេ? ថាតើមានគ្រូពេទ្យ ឬមានការផ្តល់ថ្នាំសង្កូវដែរឬទេ?

**ឆ៖** មាន ។

**ស៖** តើអ្នកណាគេខ្លះដែលជាពេទ្យនោះ?

**ឆ៖** អត់ស្គាល់ផង ភ្លេចអស់ហើយ ។

**ស៖** ថាតើពេទ្យទាំងអស់នោះ គាត់ធ្លាប់ទៅរៀនផ្នែកពេទ្យដែរឬទេ ឬគាត់ជាកសិករធម្មតា?

**ឆ៖** អត់ដឹងផង មិនដឹងកសិករ មិនដឹងគេរៀនអី អត់ដឹង ស្រាប់តែឃើញពេទ្យនៅហ្នឹង ។

**ស៖** ថាតើពេទ្យទាំងអស់នោះ គឺនៅទីកន្លែងនោះរហូត ឬក៏គាត់នៅម្តងម្កាល ពីពេលមួយទៅពេលមួយ?

**ឆ៖** ពេទ្យនៅនុ៎ងតែម្តង ។

**ស៖** លោកអាចប្រាប់យើងខ្ញុំដែរឬទេ ថាលោកសង្កេតឃើញភាពលំបាកលំបិនអំឡុងពេលមានភ្លៀងធ្លាក់ធំ ថាលោកអាចប្រាប់ទេ ថាមានទឹកជំនន់នៅពេលនោះ?

**ឆ៖** មាន ។ ក្នុងឆ្នាំ១៩៧៣ហ្នឹង ភ្លៀងធំ ទឹកសាយលិចនុ៎ង ។

**ស៖** តើមានអ្វីកើតឡើងទៅដល់អ្នកទោសអំឡុងពេលទឹកលិចនោះ?

**ឆ៖** លិចអ្នកទោស ខ្លះក៏ស្រង់រួច ខ្លះក៏យកអត់ទាន់ទៅ មានគ្រោះថ្នាក់អាយុជីវិតអ៊ីចឹង ។

[១៥:៤៤:៥២]

**ស៖** កន្លែងដែលអ្នកទោសឃុំខ្លួននៅក្នុងរណ្តៅនោះ តើពួកអ្នកទោសនោះត្រូវបានគេអនុញ្ញាតឲ្យចេញមកក្រៅរណ្តៅដែរឬទេ?

**ឆ៖** ដល់ពេលអ៊ីចឹងយកមកលើមកវិញ យកមកបញ្ជូនឲ្យនៅទួល តាមទួលណាដែលអត់ទឹកលិច ដំបូកអ៊ីចឹង យកមកដាក់អ៊ីចឹង ។

**ស៖** នៅពេលដែលអ្នកទោសត្រូវបានយកមកដាក់ខាងក្រៅ ពួកគេទាំងអស់គឺត្រូវបានយកចេញពីទឹកលិចនោះ ឬក៏ពួកគេស្ថិតនៅក្នុងរណ្តៅនុ៎ងដដែល?

**ឆ៖** យកចេញពីក្នុងរណ្តៅ ។

**ស៖** ដូច្នេះ សូមឲ្យលោកពន្យល់យើងខ្ញុំថា តើអ្នកទោសទាំងអស់នោះ គាត់លង់ទឹកយ៉ាងម៉េច?

**ឆ៖** លង់ដែលយកអត់ទាន់ ។ អ្នកដែលត្រូវលង់គឺយកអត់ទាន់ អ្នកដែលអត់បានលង់ គឺយកទាន់មកចេញក្រៅរួចមករួច ខ្លះគ្នាដែលយកមិនទាន់គឺមានការលង់ស្លាប់ទៅ ។

**ស៖** ថាតើមានអ្នកទោសច្រើនដែរឬទេស្លាប់?

**ឆ៖** ស្លាប់តិចដែរ បីបួននាក់ ។

**ស៖** តើលោកចាំដែរឬទេ ដែលលោកត្រូវបានសួរយកចម្លើយដោយអ្នកស៊ើបអង្កេត នៅក្នុងដំណាក់កាលស៊ើបអង្កេត តើលោកមានចាំទៅលើចំណុចហ្នឹងដែរឬទេ?

**ឆ៖** អត់ផង ។

**ស៖** នៅក្នុងកំណត់ហេតុនៃការសម្ភាសន៍សួរយកចម្លើយគឺមានឯកសារលេខD៧៨/៤ ។ ឯកសារមួយនេះ គឺជាកំណត់ហេតុនៃការសម្ភាសន៍ទៅលើបុគ្គលមួយរូបឈ្មោះ ចាន់ ខន ដែលបុគ្គលនេះ--

**ឆ៖** អូ! អាហ្នឹងមាន គេទៅសម្ភាសន៍ម្តង ។

**ស៖** ឯកសារនេះបាននិយាយលើកឡើងថា មានយប់មួយមានទឹកជន់ ហើយអ្នកទោសភាគច្រើននៅក្នុងរណ្តៅបានស្លាប់ ។ ជាទូទៅ អ្នកទោសទាំងអស់បានស្លាប់ លើកលែងតែអ្នកទោសចំនួនតិចប៉ុណ្ណោះដែលអាចរត់គេចចេញនៅយប់នោះ ដោយមានអ្នកជួយ បងធំៗគាត់ជួយ ។ ថាលោកអាចបញ្ជាក់យល់ព្រមជាមួយនឹងចម្លើយដែលបានអានដែរនេះដែរឬទេ? ហើយវាត្រឹមត្រូវនឹងអ្វីដែលលោកបានជម្រាបយើងនៅពេលនេះដែរឬទេ?

[១៥:៥០:០៥]

**ឆ៖** កាលហ្នឹង ទឹកលិចមកហ្នឹង វាភាគច្រើនស្លាប់ច្រើនជាងនៅរស់មែន ។

**ស៖** ខ្ញុំដូចជាមិនសូវយល់នោះទេ លោកបាននិយាយអម្បាញ់មិញថា មានអ្នកទោសចំនួនតិចស្លាប់ ។ ខ្ញុំជឿថាលោកអម្បាញ់មិញនិយាយមានបីទៅបួននាក់ ហើយលោកបញ្ជាក់ថាមាន ចំនួនតែបី ឬក៏បួននាក់ប៉ុណ្ណោះបានស្លាប់ ឬក៏មានចំនួនច្រើនស្លាប់ ។

**ឆ៖** បីបួននាក់ហ្នឹងហើយដែលស្លាប់ ។ ភាគច្រើនមានបីបួននាក់ហ្នឹងហើយស្លាប់ ហើយភាគតិចនៅអ្នកទោសនៅក្នុងហ្នឹងវាតិចដែរ ។ ការយកវាមិនទាន់ ។ បងៗវាយកអត់ទាន់ទៅ ចំណែកឯតូចៗយកម៉េចបានមនុស្ស ។

**ស៖** លោកបានឃើញ ឌុច ចេញបញ្ជាពី ឌុច ឲ្យមានការដកអ្នកទោស ឬបញ្ជូនអ្នកទោសចេញដែរឬទេ?

**ឆ៖** គាត់បញ្ជាឲ្យដកចេញពីក្នុងរណ្តៅ ។ តែដកវាមិនទាន់ ទឹកឡើងលឿនស្រឹត លឿនពេក ។

**ស៖** លោកបានឮ ថាតើលោកបានឮ និងឃើញអ្នកទោសត្រូវបានគេសួរចម្លើយដែរឬទេ?

**ឆ៖** អត់ ។

**ស៖** តើលោកបានឃើញអ្នកទោស បង្ហាញសញ្ញាមួយថាមានអំពើកំរោល ឬអំពើហិង្សាណាមួយត្រូវបានប្រព្រឹត្តចំពោះគាត់ដែរឬទេ?

**ឆ៖** អានសំណួរមួយលើកទៀត ស្តាប់អត់បាន ។

**ស៖** តើលោកបានឃើញអ្នកទោសដែលនៅលើមុខ ឬនៅលើខ្លួនប្រាណមានស្នាមជាំ ឬក៏ស្នាមនៃការវាយតប់ណាមួយទៅលើគាត់ដែរឬទេ?

**ឆ៖** មាន ។

**ស៖** តើលោកអាចប្រាប់ និងរៀបរាប់អំពីស្នាកស្នាមទាំងអស់នោះដែរឬទេ? ហើយពួកគេបានស្លៀកពាក់អ្វីខ្លះ?

**ឆ៖** ពាក់ខោអាវដូចយើងធម្មតា ។

**ស៖** លោកប្រាប់យើងថា លោកឃើញស្នាមជាំនៅលើខ្លួនប្រាណរបស់អ្នកទោស។ ដូច្នេះ តើស្នាមនោះ លោកបានឃើញស្នាមហ្នឹងយ៉ាងម៉េច? តើលោកអាចឆ្លើយសំណួរនេះបានដែរឬទេ?

**ឆ៖** ស្នាមរំពាត់ ។

[១៥:៥៤:៤១]

**ស៖** តើស្នាមនោះនៅលើកន្លែងណានៃរាងកាយរបស់អ្នកទោសដែលលោកបានឃើញហ្នឹង?

**ឆ៖** ស្នាមនៅខ្នង នៅកំប៉េះក្លិត កំភ្លៅអីហ្នឹង ។

**ស៖** តើមានពេលមួយលោកធ្លាប់នាំអ្នកទោសដើម្បីឲ្យគេសួរចម្លើយ តើលោកបានទទួលបញ្ជាឲ្យនាំអ្នកទោសទៅឲ្យគេសួរចម្លើយទេ កាលលោកនៅទីនោះ?

**ឆ៖** អត់ផង ។

**ស៖** ដូច្នេះ តើតួនាទីរបស់លោកពិតប្រាកដក្នុងឋានៈជាអ្នកយាមនៅម-១៣ នោះ ធ្វើអ្វីខ្លះ?

**ឆ៖** មានភារកិច្ចតែយាមហ្នឹង ។

**ស៖** នៅពេលដែលលោកនៅក្នុងមន្ទីរម-១៣នោះ តើលោកបានឃើញឧបករណ៍អ្វីដែលគេអាចប្រើដើម្បីប្រព្រឹត្តអំពើហិង្សាទៅលើអ្នកទោសទេ នៅក្នុងពេលដែលគេសួរចម្លើយនោះ?

**ឆ៖** អត់ផង ។ អត់ដែលដឹង ។

**ស៖** ឥឡូវនេះ ខ្ញុំនឹងអានសេចក្តីដកស្រង់មួយពីនៅលេខ D៧៨/៤ "តើឧបករណ៍អ្វីខ្លះ ហើយវិធីអ្វីខ្លះនៃការធ្វើទារុណកម្មដែលលោកបានឃើញ?" ហើយខ្ញុំដកស្រង់ពីឯកសារនោះ។ ចម្លើយដែលលោកឆ្លើយ "ខ្ញុំបានឃើញរំពាត់ ដំបងឫស្សី ប៉ុន្តែខ្ញុំមិនដែលបានឃើញម្ជុល ឬដង្កាប់ ខ្ញុំមិនដែលឃើញរូបទៅជ្រមុជទឹកទេ ។ វាអាចថា អ្នកទោសទាំងនេះគឺថាគេអាចយកទៅសួរចម្លើយឆ្ងាយ នៅខាងជើងនៃស្រះមួយ ។ ពួកអ្នកទាំងនោះខ្លះគឺមិនដែលត្រឡប់មកវិញទេ ។ ខ្ញុំបានឃើញអ្នកទោស ដែលមាននាំទៅសួរចម្លើយ ហើយវិលមកវិញហើមខ្លួន ហើយមានឈាមពេញខ្លួន បន្ទាប់ពីសួរចម្លើយនោះ ។ ឌុច ធ្លាប់បានបញ្ជាឲ្យកងការពារនាំអ្នកទោសឲ្យទៅគាត់សួរចម្លើយ។ ហើយជាញឹកញាប់អ្នកទោសត្រឡប់មកវិញមានរបួសប្រឡាក់ឈាម ហើយក៏បាត់ខ្លួនតែម្តងទៅ ។ ខ្ញុំបានឃើញសសរបួនឬប្រាំនៅក្នុងបរិវេណប៉ែកខាងកើត ដែលត្រូវបានទុកសម្រាប់ចងបាញ់សម្លាប់អ្នកទោស ដើម្បីបំភ័យអ្នកទោសដទៃទៀត" ។

ចំណុចដែលខ្ញុំទើបតែបានអាននេះ តើមានទំនាក់ទំនងទៅអ្វីជាមួយនឹងការចងចាំរបស់លោកដែរឬទេ?

**ឆ៖** នុ៎ងពិតមែន ។ កន្លែងធ្វើទារុណកម្មមានមែន ។

**ស៖** តើលោកអាចប្រាប់យើងបានទេ អ្នកណាជាអ្នកបាញ់សម្លាប់អ្នកទោស នៅពេលដែលគេចងភ្ជាប់ទៅនឹងបង្គោលដែលលោកបានរៀបរាប់ ដែលថាធ្វើនៅមន្ទីរម-១៣ អ្នកណាជាអ្នកបាញ់សម្លាប់អ្នកទោសនោះ?

[១៥:៥៩:៤០]

**ឆ៖** អត់ដែលឃើញផង ។ គ្រាន់តែឃើញតែកន្លែងហ្នឹង ជួនកាលខ្ញុំមិននៅអីទៅ គេធ្វើទៅ ខ្ញុំអត់ដឹង ។ ព្រោះមុខសញ្ញាផ្សេងគ្នាដែរ ។ ជួនកាលទៅឃាមគាស់ដីបាត់ទៅក៏មាន ។ អ៊ីចឹងទៅវាអត់បានឃើញកន្លែងគេធ្វើ មិនដឹងឈ្មោះណាជាអ្នកបាញ់សម្លាប់ គឺអត់បានឃើញ ។

**ស៖** ខ្ញុំនឹងអានឯកសារ D៧៨/៤ ជាសេចក្តីដកស្រង់នៃឯកសារនោះ ។ អ្នកបាញ់នោះ គឺឈ្មោះ មាស, ឈ្មោះ ចាន់, ឈ្មោះ ប៉ុន ហើយនិង ផល ។ នេះជាអ្វីដែលលោកចងចាំ ឬក៏លោកឮគេ

ប្រាប់លោកទេ? ឬក៏លោកបានឃើញដោយផ្ទាល់ភ្នែកពីការបាញ់នោះ?

**ឆ៖** អាហ្នឹងឮគេនិយាយតៗគ្នា ។

**ស៖** តើលោកបានឃើញ ឌុច ជាអ្នកបាញ់សម្លាប់អ្នកទោសដោយខ្លួនឯងទេ?

**ឆ៖** អត់ផង អត់ដែរឃើញបាញ់ផង ។

**ស៖** អ៊ីចឹង ខ្ញុំនឹងអានបន្តទៅទៀត ។ អ្នកដែលបាញ់សម្លាប់នោះ គឺ មាស, ចាន់, ប៉ុន ហើយនិងផល ហើយខ្ញុំមិនដែលឃើញ ឌុច ជាអ្នកបាញ់ទេ ។ ខ្ញុំគិតថា ការសម្លាប់ទាំងអស់នោះ គឺពិតជាអនុវត្តតាមការបញ្ជារបស់ ឌុច ។ ដោយហេតុថា ដោយសារ ព្រោះឮសូរខ្លាំង ហើយអ្នកល្មើសនឹងត្រូវបាញ់សម្លាប់វិញ ។ អ្នកណាដែលអនុញ្ញាតឲ្យអ្នកទោសរត់រួច គេនឹងសម្លាប់អ្នកនោះវិញ ។

តើនេះវាឆ្លុះបញ្ចាំងពីអ្វីដែលលោកបានឃើញ ដែលលោកបាននិយាយ ដែលបានកត់ត្រានៅក្នុងការសម្ភាសន៍នោះទេ?

**ឆ៖** អាហ្នឹងតែឈ្មោះណាយាម តែរត់រួច អាហ្នឹងត្រូវទទួលទោសហើយ ។ បើអត់រត់រួច គឺគេអត់ដាក់ទោសយើង ។

**ស៖** តើឈ្មោះ ផល លោកដឹងស្អីខ្លះពីឈ្មោះ ផល ហ្នឹង?

**ឆ៖** បង ផល ស្លាប់ ។

**ស៖** តើលោកដឹងដូចម្តេចថា ផល នោះស្លាប់ហើយនោះ?

**ឆ៖** គាត់ស្លាប់នៅនុ៎ង ។ គេថាគាត់សីលធម៌ ។

**ស៖** តើលោកបានឃើញសាកសពគាត់ ថាគាត់ស្លាប់ហ្នឹងទេ?

**ឆ៖** អត់ផង ។

**ស៖** លោកបានប្រាប់យើងពីមុននេះបន្តិចថា សមាជិកខ្លះនៃក្រុមគ្រួសាររបស់លោកក៏ត្រូវបានគេឃុំខ្លួននៅក្នុងមន្ទីរម-១៣ នោះដែរ ។ តើលោកអាចប្រាប់យើងបាន បន្ថែមពីរឿងនេះបានទេ?

**ឆ៖** ត្រូវជាជីតារបស់ខ្ញុំ ។

**ស៖** តើមានអ្វីជាពិសេសកើតឡើងរវាងរូបលោក ហើយនិងជីតារបស់លោក ជីដូនជីតារបស់លោក នៅពេលដែលលោកនៅម-១៣ នោះ?

**ឆ៖** មានអារម្មណ៍ភ័យព្រួយដែរ ព្រោះឃើញជាជីតាជាប់គុកទៅហើយ ។ ក្នុងអារម្មណ៍នោះគឺព្រួយខ្លួនឯងដែរហ្នឹង ខ្លាចមានជាប់ដែរ ។

[១៦:០៥:៣២]

**ស៖** តើជីតារបស់លោកហ្នឹង គេយកគាត់ទៅសួរចម្លើយដែរឬទេ?

**ឆ៖** ហ្នឹងអត់ដឹងផង ។ ពេលហ្នឹងខ្ញុំចេញបាត់ហើយ ។

**ស៖** តើលោកមានឱកាស ដើម្បីជួបជីតារបស់លោកជាថ្មីម្តងទៀតទេ? តើគេដោះលែងគាត់ ឬក៏គាត់នៅរស់? ឬក៏គាត់ស្លាប់នៅក្នុងម-១៣ នោះ?

**ឆ៖** គាត់ស្លាប់នុ៎ងមួយ តាខាងឪ តាខាងម៉ែរួច បានវិលត្រឡប់ទៅផ្ទះវិញ ។

**ស៖** តើជីតារបស់លោកស្លាប់ ដោយរបៀបណានៅក្នុងម-១៣ នោះ?

**ឆ៖** អត់ដឹងផង ។ ខ្ញុំចេញបាត់ហើយ ។

**ស៖** តើលោកបានឃើញជីតាមួយផ្សេងទៀតរបស់លោកទេ ក្រោយពីគាត់ចេញពីម-១៣ហ្នឹង មកដែលលោកចេញពីម-១៣ មក?

**ឆ៖** ទៅជួបគ្នាផ្ទះឯណោះ ។

**ស៖** តើលោកបានជជែកអ្វី និយាយអ្វីទៅគាត់ទេ ពេលដែលជួបនៅផ្ទះនោះ?

**ឆ៖** អត់ដែលជជែកអីផង ។ និយាយគ្នាធម្មតា ហៅគាត់ធម្មតាហ្នឹង ។

**ស៖** តើលោកជជែក ឬក៏និយាយធម្មតាជាមួយគាត់ តើលោកពិភាក្សា និយាយអ្វីជាមួយជីតាដែលនៅរស់ម្នាក់នោះ?

**ឆ៖** អត់និយាយអីផង ។ និយាយលេងសើចធម្មតា ។

**ស៖** តើលោកមិនចាប់អារម្មណ៍នឹងរកឲ្យដឹងឃើញ ថាតើគាត់អាចរួចរស់ជា-- ឲ្យដោះលែងពី ម-១៣ ដូចម្តេចទេ? លោកមិនបានសួរអ្វីទៅជីតារបស់លោក មិនចង់ដឹងថា តើរឿងអីបានជាគាត់រួចរស់ពី ម-១៣ បាន លោកមិនចង់ដឹងអីចឹងទេ? ពេលនោះ ។

**ឆ៖** អត់ប៉ានសួរផង ព្រោះជំនាន់នុ៎ងខ្លាចងាប់ខ្លួនដែរ ដេញដោលសួរម៉េចកើត ។

**ស៖** តើលោកខ្លាចអ្នកណា? ខ្លាចជីតាដែលនៅរស់ ឬក៏អ្នកណា? ដែលថាមិនប៉ានសួរដេញដោលហ្នឹង ។

**ឆ៖** ចុះដែលទៅនៅមូលដ្ឋានភូមិឃុំហ្នឹង មិនមែនស្រឡាញ់យើងទាំងអស់ឯណា ។

**ស៖** លោកខ្លាចសមាជិកក្រុមគ្រួសារខ្លួនឯង? ឬក៏លោកខ្លាចអ្នកជិតខាង? ឬក៏ខ្លាច ឌុច ដែលថាមិនប៉ានសួរដេញដោលនោះ? តើលោកខ្លាចអ្នកណា ដែលមិនប៉ានសួរដេញដោលហ្នឹង?

**ឆ៖** ខ្លាចអ្នកដទៃទៀត គេក្តាប់បានទៅ គេរាយការណ៍ទៅ មិនងាប់ ។ គេមិនចាប់យើងវិញ ។ អ៊ីចឹង កុំសួរតែម្តង ។

**ស៖** និយាយអំពី?

**ឆ៖** និយាយពីអី? ស្តាប់អត់បានផង ។

**ស៖** លោកនិយាយថា លោកបានខ្លាចអ្នកផ្សេងអាចនឹងនិយាយពីអ្វីៗទាក់ទងទៅនឹងអ្វីបានកើតនោះ ។ តើលោកអាចប្រាប់យើងបានទេ? ថាវាមានហេតុអីកើតឡើងទេ បើយើងសួរដេញដោលទៅគេឮ វាមានរឿងអីកើតឡើង?

**ឆ៖** អាហ្នឹង គឺខ្លាចគេតាមដានយើង ។ យើងដេញដោយអី ការងារអី ។ អ៊ីចឹងទៅ គឺខ្លាច ។ អ៊ីចឹង ខ្ញុំមិនប៊ានសួរគាត់ទេ ។ ព្រោះរស់នៅសង្គមហ្នឹង គឺគេតាមដានណាស់ម្នាក់ៗ មិនមែនអាចរស់បានស្រួលឯណា ។ អ៊ីចឹង ហើយត្រូវតែប្រយ័ត្នពាក្យសម្តីខ្លួនឯងហ្នឹង និយាយ តែនិយាយខុសត្រូវការស្លាប់ ។

**ស៖** តើពេលណាដែលលោកបានជួបជីតា ដែលនៅរស់នោះម្តងទៀតហ្នឹង ជួបពេលណា?

**ឆ៖** ជួបតាំងពីឆ្នាំ៧៤ ឯណោះ ។

**ស៖** តើគាត់ស្លាប់នៅពេលណា?

**ឆ៖** គាត់ស្លាប់ ទើបនឹងស្លាប់ យើងរំដោះហើយ ។

**ស៖** ក្រោយពេលរំដោះហើយ លោកនៅតែខ្លាចមិនប៊ានសួរដេញដោលគាត់ដដែល ឬយ៉ាងម៉េច?

**ឆ៖** អត់ទេ ។ ដល់ពេលហ្នឹង អត់សួរអីទៀតផង ។ រហូតដល់គាត់ស្លាប់ទៅ ។

**ស៖** តើលោកមាន ឬក៏លោកឃើញអ្នកទោស ដែលគេនាំអ្នកទោសទៅក្រៅ តើលោកបានឮអំពីការសម្លាប់អ្នកទោសនោះដែរឬទេ?

**ឆ៖** អត់ដឹងផង ។

[១៦:១៣:៣៨]

**ស៖** ដូច្នេះ ខ្ញុំនឹងអាននូវកំណត់ហេតុឯកសារ នូវ D៧៨ ដែលលោកបាននិយាយដូចខាងក្រោមនេះ គេបានសួរលោកថា “តើការសម្លាប់កើតឡើងនៅកន្លែងណា? ដោយរបៀបណា? គេសម្លាប់ដោយបែបណា?”ចម្លើយរបស់លោក ពេលនោះ លោកឆ្លើយថា “អ្នកទោសត្រូវបានសម្លាប់នៅក្នុងព្រៃ ដោយ

គល់ឈើ ឬឫស្សីវាយចំកញ្ចឹងក ។ អ្នកទោសភាគច្រើនស្លាប់ដោយសារ ការសម្លាប់ និងមួយចំនួនស្លាប់ដោយសារការអត់អាហារ" ។ អ្វីដែលខ្ញុំទើបតែអានជូនលោកស្តាប់នេះ តើនេះវាផ្ទុះបញ្ចាំងពីអ្វីដែលលោកបាននិយាយ ឬក៏វាផ្ទុះបញ្ចាំងពីអ្វី ដែលលោកបានចងចាំដែរ ឬទេ?

**ឆ៖** អត់ដឹងផង ។

[១៦:១៥:០៥]

**ស៖** លោកមិនដឹង ដោយលោកមិនចាំអ្វីទាំងអស់ ឬយ៉ាងម៉េច? ឬក៏ដោយហេតុថា លោកមិនដែលៗបានដឹងអំពីហេតុការណ៍នៃការសម្លាប់នោះ?

**ឆ៖** ព្រោះអត់ដែលដឹងហេតុការណ៍ហ្នឹងហើយ ។

**ស៖** ហេតុអ្វីបានជាលោកឆ្លើយប្រាប់ទៅអ្នកស៊ើបអង្កេតនៅក្នុងបទសម្ភាសថាបែបនេះ បើលោកមិនដឹងនោះ មិនចាំនោះ ។

**ឆ៖** ក្នុងនុ៎ង បងៗគាត់អ្នកនិយាយ ពេលហូបបាយអី គាត់អ្នកនិយាយ ។

**ស៖** អ្នកណាជាអ្នកនិយាយ ពេលហូបបាយហ្នឹង? អ្នកដែលចូលរួមក្នុងការសម្លាប់ ឬក៏អ្នកណាផ្សេងជាអ្នកនិយាយនុ៎ង?

**ឆ៖** បងៗគេដែលចាស់ៗនុ៎ង គេអ្នកនិយាយថារឿងហ្នឹង ។

**ស៖** តើគេនិយាយពីអ្វីបើលោកចាំដោយពិតប្រាកដទៅ គេនិយាយពីអ្វី ពីរឿងហ្នឹង?

**ឆ៖** គេនិយាយថា យកមនុស្សទៅ គេវៃអ៊ីចឹងទៅ ។

**ស៖** តើគេនាំអ្នកទៅកន្លែង ហើយគេវាយរបៀបម៉េច?

**ឆ៖** អត់ដឹង ។

**ស៖** លោកបានប្រាប់យើងពីមុននោះថា ថាមានចំនួនប្រហែល អ្នកយាមពីដប់ទៅម្ភៃនាក់នៅម-១៣ តើជាក្រុមដែលៗទទួលបន្ទុកក្នុងការសម្លាប់ដែរឬទេ ក្រុមអ្នកយាមនោះ?

**ឆ៖** អត់ដឹង មិនដឹងក្រុមណា សម្លាប់ក្រុមណា អត់ ។ ព្រោះដឹងតែតួនាទីរបស់ខ្លួនឯង ដឹងតែខ្លួនឯង អ្នកយាមហ្នឹង ។ ព្រោះសុទ្ធតែលាក់ការណ៍ ។

**ស៖** តើមានក្រុមមួយដែលគេចាត់តាំងដើម្បីធ្វើការតាមដានអ្នកទោស ដែលគេបញ្ចេញឲ្យទៅធ្វើការនៅខាងក្រៅគុកនោះដែរ ឬទេ?

**ឆ៖** អត់ដឹង ។

**ស៖** ដូច្នេះ ទាក់ទងទៅនឹងខ្លួនលោកផ្ទាល់ តើលោកធ្លាប់ទៅតាមមើលអ្នកទោសដែលទៅធ្វើការនៅខាងក្រោមនឹ្ទរម-១៣ហ្នឹង ដែរឬទេ?

**ឆ៖** ដែលទៅយាមឲ្យដាំដំឡូង ដាំអីហ្នឹងដែរ ។

[១៦:១៩:២៥]

**ស៖** តើលោកមិនដែលបានកត់សម្គាល់អ្វីខុសពីហ្នឹងទេ? នូវថាឃើញអីជាពិសេស ហេតុការណ៍អីជាពិសេសក្នុងពេលនៅយាមកាមនោះទេ អ្នកទោសហ្នឹង?

**ឆ៖** អត់ដែលមានឃើញអីពិសេសផង ព្រោះខ្ញុំទៅយាម អ្នកទោសអត់ដែលរត់ ។

**ស៖** តើមានអ្នកទោសណាដែលបានព្យាយាមរត់គេចខ្លួនទេ ពេលនោះ?

**ឆ៖** គេយាមមិនដឹងទេ បើខ្ញុំយាម អត់ដែល អ្នកទោសអត់ដែលរត់ផង ព្រោះអាហ្នឹងបែងចែកក្រៅ ផ្សេងៗគ្នា ។

**ស៖** តើលោកបានដឹងពីអ្នកយាមម្នាក់ឈ្មោះ ចាន់ វឿន ទេ?

**ឆ៖** ហ្នឹងយាមឲ្យអ្នកទោសរត់រួចហ្នឹង ។

**ស៖** នៅពេលដែលលោកយាមនៅម-១៣ តើចាន់ វឿន ក៏ជាអ្នកយាមនៅម-១៣ ក្នុងពេលនោះដែរឬទេ?

**ឆ៖** អ្នកយាមដែរ ។

**ស៖** តើលោកអាចប្រាប់យើងអ្វីពីរឿងរ៉ាវ លោក ចាន់ វឿន បានទេ ជាអ្នកយាមដូចគ្នា នោះ?

**ឆ៖** ដល់អ៊ីចឹង ចាន់ វឿន ហ្នឹងឲ្យអ្នកទោសរត់រួច ហើយអ៊ីចឹងទៅ គេដកយកមកដាក់ឃុំឃាំងអ៊ីចឹងទៅ ។

**ស៖** តើគាត់បានរត់ចេញពីម-១៣ទេ គាត់រត់ចេញដោយខ្លួនឯង ឬក៏គាត់បាន គេជួយគាត់ ឲ្យគាត់រត់?

**ឆ៖** គេជួយឲ្យរត់ ខ្ញុំអីហ្នឹងប្រាប់ឲ្យរត់ បើនៅហ្នឹងខ្លាចស្លាប់ ។

**ស៖** តើលោកអាចប្រាប់យើងដូចម្តេចបានខ្លះ អំពីជនជាប់ចោទ តើគាត់មានអាកប្បកិរិយា ឬអត្តចារិកដូចម្តេចនៅ ម-១៣នោះ?

**ឆ៖** គាត់មានអត្តចរិតម៉ឺងម៉ាត់ ហ្មត់ចត់ក្នុងការងារ ។

**ស៖** ខ្ញុំនឹងអានឯកសារ D៧៨ ម្តងទៀត ហើយគេបានសួរលោកនូវសំណួរលោក ដូចខាង

ក្រោមអំពីរៀបរាប់អំពីអត្តចរិតរបស់ឌុច ជាមនុស្សម៉ឺងម៉ាត់ ដូចដែលលោកនិយាយ ហើយខ្ញុំខ្លាច លោកឆ្លើយថា ខ្ញុំខ្លាចគាត់ គឺថាគ្មានអ្នកយាមណាម្នាក់ប៉ានចូលទៅក្នុងការិយាល័យរបស់គាត់ទេ ហើយក៏មិនមានអ្នកណាម្នាក់ទាំងខ្ញុំនិយាយកំប្លែងជាមួយគាត់ទេ គាត់ជាមនុស្សហ្មត់ចត់ ពេញចិត្តនឹងការងារ គាត់ធ្លាប់ និយាយទៅកម្មាភិបាលនៅក្នុងអង្គប្រជុំទាំងអស់នោះថា "ឲ្យលាក់ការណ៍សម្ងាត់ ឲ្យលាក់ការណ៍អំពីការងារ ការសម្លាប់ និងការងារផ្សេងៗទៀត ហើយនឹងសកម្មភាពផ្សេងទៀតទាក់ទងទៅនឹងសន្តិសុខ មន្ទីរសន្តិសុខ" ហើយគាត់កាន់ គាត់ទម្លាប់ដាក់កាំភ្លើងខ្លី៥៤ជាប់ជាមួយគាត់ ហើយគាត់ -- ខ្ញុំធ្លាប់ឃើញ គាត់ជក់បារីផងដែរ ហើយខ្ញុំធ្លាប់ឮគាត់សើចខ្លាំង ពេលគាត់ប្រាជ្ញលេង ។

**ស៖** អ៊ីចឹងអ្វីទាំងអស់នេះ តើឆ្លុះបញ្ចាំងទៅការពិត ដែលលោកបានដឹង បានឃើញនូវទីនោះដែរឬទេ?

**ឆ៖** ពិត ។

**ស៖** ឌុច បាននិយាយទៅលោកថា គឺថាជាការចាំបាច់ដើម្បីលាក់ការណ៍ ដើម្បីរក្សាការសម្ងាត់ព័ត៌មានទាំងអស់នៅក្នុងមន្ទីរសន្តិសុខនោះ ជាសម្ងាត់ តើឌុច បានប្រាប់លោកអ៊ីចឹងមែនទេ?

**ឆ៖** បាន ។

**ស៖** តើថ្ងៃនេះ តើលោកនៅតែខ្លាចឌុច ដដែលដែរឬទេ?

**ឆ៖** អត់ខ្លាចទេ ។

**ស៖** តើថ្ងៃនេះ តើលោកមានការខ្មាសអៀនថា ខ្លួនលោកបានធ្វើជាអ្នកយាមនៅម-១៣នោះ លោកមានការខ្មាសអៀនទេ?

**ឆ៖** មានការខ្មាសអៀន ។

**ស៖** តើលោកអាចប្រាប់ឲ្យបានពិស្តារពីការខ្មាសអៀនហ្នឹងដែរឬទេ?

**ឆ៖** ព្រោះបានថា មានការខ្មាសអៀនឃើញអំពើហ្នឹង វាពុករលួយ ធ្វើឃាតមនុស្សអ៊ីចឹង ហើយបើយើងខ្ញុំរត់ចេញទៅខ្លាចស្លាប់ ម្ល៉េះហើយខ្ញុំអត់ប៉ានរត់ចេញ ។

**ស៖** លោកទើបតែបាននិយាយថា បើខ្ញុំយល់ច្បាស់នោះ លោកបានឃើញគេ សម្លាប់មនុស្ស តើនោះជាការពិតដែលលោកនិយាយទេ?

**ឆ៖** ដូចខ្ញុំរៀបរាប់អ៊ីចឹង ថាបើពេលបញ្ជូនទៅថ្នាក់លោកបាត់រហូតហ្នឹង ។ ទៅរៀនសូត្រ ដឹងតែទៅរៀនសូត្រ មិនដឹងទៅឯណា ស្រាប់តែបាត់មនុស្សអស់ ។

[១៦:២៧:១៨]

**ស៖** លោកបានឃើញថា គេសម្លាប់អ្នកទោស តើលោកបានឃើញដោយផ្ទាល់ភ្នែកថា ឃើញគេសម្លាប់មនុស្សដោយផ្ទាល់ភ្នែកនោះទេ?

**ឆ៖** អត់ផង ។ អត់ដែលឃើញផ្ទាល់ផង ព្រោះអាហ្នឹងមិនមែនចេះតែទៅមើលឯណា ។

**ប្រធានអង្គជំនុំ៖**

ដូចជាអស់ម៉ោងហើយ ពេលវេលា អ៊ីចឹងដល់ម៉ោងត្រូវសម្រាកនៅពេលរសៀលហើយ ហើយសូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ មានបញ្ហាអ្វីទៅ?

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមឲ្យលោកចៅក្រមរំឭកសាក្សី គាត់មិនអាចនិយាយជាមួយនរណាទាំងអស់រហូតដល់ពេលការផ្តល់សក្ខីកម្មរួច ហើយគាត់មិនអាចជួប និងជាមួយសាក្សីណាផ្សេងទៀត ។ ហើយសូមឲ្យលោកចៅក្រម ធ្វើការរំឭកគាត់អំពីបញ្ហានេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសផ្អាកសវនាការត្រឹមនេះ ហើយលើកទៅបន្តសវនាការនៅថ្ងៃស្អែក វេលាម៉ោង៩ព្រឹក ហើយលោក ចាន់ ខន ឥឡូវនេះ យើងអង្គជំនុំជម្រះផ្អាកដំណើរការស្តាប់សក្ខីកម្មលោកសិនត្រឹមនេះ ហើយឲ្យលោកត្រឡប់ទៅកាន់ទីកន្លែងវិញ ហើយស្អែកត្រឡប់មកវិញ ហើយលោកមិនត្រូវបានទាក់ទងជាមួយនឹងអ្នកណាទេ នៅក្នុងអំឡុងពេលនៃរង់ចាំ ដើម្បីធ្វើសក្ខីកម្មបន្តនេះ ហើយកិច្ចការនេះ គឺខាងអង្គភាព *WESU* គឺបានយល់ច្បាស់លាស់ហើយ ។

ដូច្នេះ គឺមន្ត្រីតុលាការសូមនាំគាត់ទៅប្រគល់ឲ្យអង្គភាព *WESU* ដើម្បីសម្របសម្រួលឲ្យគាត់ទៅនៅកន្លែងរងចាំ ដែលបានរៀបចំទុករួចហើយ ដោយឡែកអនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់ត្រឡប់មកសាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោង៩ ៕

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការផ្អាកនៅម៉ោង១៦:៣០នាទី]*